# អារម្ភកថា

ផែនការយុទ្ធសាស្ត្ររបស់ក្រសួងផែនការ *(ផយផក)* ២០០៦-២០១០ ជាផែនការយុទ្ធសាស្ត្រដំបូងរបស់ក្រសួងផែនការ រៀបចំឡើងក្នុងគោលបំណងឆ្លើយតបនឹងការខិតខំប្រឹងប្រែងនៃដំណើរការ "សុខដុមនីយកម្ម បន្សុី លទ្ធផល និង របៀបវារៈ" ដូចដែលបានលើកឡើងនៅក្នុងក្របខណ្ឌយុទ្ធសាស្ត្រសម្រាប់ការគ្រប់គ្រងកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៏។ ក្របខ័ណ្ឌយុទ្ធសាស្ត្រនេះក៏បានគូសបញ្ជាក់ពីតួនាទីស្នូលរបស់ក្រសួងផែនការ ក្នុងសកម្មភាពជាក់ស្តែងរបស់ខ្លួន ដើម្បីគាំទ្រកិច្ចខិតខំប្រឹងប្រែងរបស់រាជរដ្ឋាភិបាលក្នុងការអនុវត្តផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៏ជាតិ *(ផយអជ)* ២០០៦-២០១០ ដែលជាចក្ខុវិស័យនៃផែនការអភិវឌ្ឍន៏ជាតិតែមួយគត់សម្រាប់រយៈពេលប្រាំឆ្នាំខាងមុខ ។

ការរៀបចំ *ផយផក* បានឆ្លងកាត់ជាច្រើនដំណាក់កាលជាមួយភាគីពាក់ព័ន្ធជាច្រើន ទាំងជាមួយនាយកដ្ឋាននានារបស់ក្រសួងផែនការ និងដៃគូអភិវឌ្ឍន៏ក្រៅប្រទេសដែលជាសមាជិកនៃក្រុមការងារបច្ចេកទេសផែនការ និងការកាត់បន្ថយភាពក្រីក្រ។

*ផយផក* រៀបរាប់ពន្យល់លម្អិតអំពីសកម្មភាពសំខាន់ៗរបស់ក្រសួងផែនការ សម្រាប់រយៈពេល ០៥ឆ្នាំដែលចាំបាច់ត្រូវអនុវត្ត ។ *ផយផក* លើកឡើងពីក្របខណ្ឌពេលវេលាជាបន្តបន្ទាប់ និងតម្រូវការចាំបាច់សម្រាប់ការគាំទ្រ ដើម្បីអនុវត្តសកម្មភាពជាយុទ្ធសាស្ត្រទាំងឡាយនេះ ។ *ផយផក* នឹងត្រូវប្រើប្រាស់ជាឯកសារណែនាំយោងតែមួយគត់ មិនមែនតែក្នុងផ្ទៃក្នុងក្រសួងផែនការទេ ប៉ុន្តែមានសារៈសំខាន់ស្មើគ្នាសម្រាប់ដៃគូអភិវឌ្ឍន៏ក្រៅប្រទេសទាំងអស់ដែលបានចាប់អារម្មណ៏ក្នុងការគាំទ្រដំណើរការផែនការ ដែលផ្តោតលើការកាត់បន្ថយភាពក្រីក្រ ។

ខ្ញុំសូមអះអាងថា ក្របខ័ណ្ឌគាំទ្រមួយសម្រាប់ការអនុវត្ត *ផយផក* ត្រូវបានរៀបចំស្របជាមួយនឹងស្មារតីនៃសេចក្តីប្រកាសទីក្រុងប៉ារីសស្តីពី សុខដុមនីយកម្ម បន្សុី និងលទ្ធផល ។ ខ្ញុំសង្ឃឹមយ៉ាងមាំថា ក្របខ័ណ្ឌគាំទ្ររបស់ដៃគូអភិវឌ្ឍន៏ក្រៅប្រទេសរបស់យើង នឹងរំលេចពីវិស័យអាទិភាពនៃការគាំទ្ររបស់ខ្លួន ទៅនិងសកម្មភាពទាំងឡាយដែលបានកំណត់ក្នុង *ផយផក* ហើយនឹងត្រូវបានអនុវត្តក្នុងរបៀបសម្របសម្រួលដ៏ល្អប្រសើរមួយ ។

ថ្ងៃទី២៣ ខែកក្កដា ឆ្នាំ ២០០៧

**ឆាយ ថន**

**ទេសរដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងផែនការ**

# មាតិកា


អារម្ភកថា ............................................................................................................ i

តារាងមាតិកា ............................................................................................................ ii

**ជំពូកទី១** : សេចក្តីផ្តើម : ប្រវត្តិដើម និង ដំណើរការរៀបចំ ១

១.១ : ការរៀបចំផែនការ និង ការកាត់បន្ថយភាពក្រីក្រនៅកម្ពុជានាទសវត្សរ៍កន្លងមក ១

១.២ : យុទ្ធសាស្ត្រចតុកោណ ,ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ *(ផយអជ)* និង ផែនការមេស្ថិតិ ៣

១.៣ : សុខដុមនីយកម្ម- បន្សុី - លទ្ធផល - របៀបវារៈ ៧

១.៤ : ការរៀបចំផែនការយុទ្ធសាស្ត្ររបស់ក្រសួងផែនការ *(ផយផក)* ១១

១.៥ : ទិសដៅត្រូវអនុវត្ត ១៣

**ជំពូកទី២** : រចនាសម្ព័ន្ធ និងការទទួលខុសត្រូវ ចក្ខុវិស័យនិងបេសកម្មរបស់ក្រសួងផែនការ ១៤

២.១ : រចនាសម្ព័ន្ធ និង ការទទួលខុសត្រូវរបស់ក្រសួងផែនការ ១៤

២.២ : ចក្ខុវិស័យ និង បេសកម្មរបស់ក្រសួងផែនការ ១៥

**ជំពូកទី៣** : ឯកសារផ្សេងទៀតរបស់រាជរដ្ឋាភិបាលដែលបង្កើតឱ្យមានភារកិច្ចបន្ថែមដល់ ក្រសួងផែនការ ១៦

**ជំពូកទី៤** : មេរៀនបទពិសោធន៍ ១៩

**ជំពូកទី៥** : ទិសដៅ និងសកម្មភាពនៃ ផយផក ២៥

**ជំពូកទី៦** : សមត្ថភាព និងតម្រូវការធនធានចាំបាច់សម្រាប់អនុវត្តន៍ ផយផក ៣២

៦.១ : ធនធានមនុស្សនិងការកសាងសមត្ថភាព ៣២

៦.២ : រចនាសម្ព័ន្ធស្ថាប័ន ៣២

៦.៣ : ពត៌មាន/ចំណេះដឹងមូលដ្ឋាន ៣៣

៦.៤ : ធនធានហិរញ្ញវត្ថុ ៣៤

**ជំពូកទី៧** : ការត្រួតពិនិត្យ ផយផក ប្រចាំឆ្នាំ ៣៥


# ឧបសម្ព័ន្ធ


ឧបសម្ព័ន្ធ ១ តារាងម៉ាទ្រីស ៣៦

ឧបសម្ព័ន្ធ ២ បញ្ជីឈ្មោះអ្នកចូលរួមសិក្ខាសាលារបស់ក្រសួងផែនការ ដើម្បីកសាង *ផយផក* នៅក្រុងព្រះសីហនុ នាខែតុលា ឆ្នាំ២០០៦ ៥១

ឧបសម្ព័ន្ធ ៣ អនុក្រឹត្យលេខ៥៥ អនក្រ.បក ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងផែនការ ៥២

ឧបសម្ព័ន្ធ ៤ អង្គការលេខរបស់ក្រសួងផែនការ និង ដ្យាក្រាម ៦៣

ឧបសម្ព័ន្ធ ៥ សូចនាករតាមដានត្រួតពិនិត្យ *ផយអជ* ៦៤

ឧបសម្ព័ន្ធ ៦ ពាក្យបំព្រួញ ៦៧

# ជំពូកទី ១

# សេចក្តីផ្តើម : ប្រវត្តិដើម និងដំណើរការរៀបចំ

## ១.១ ការរៀបចំផែនការ និងការកាត់បន្ថយភាពក្រីក្រនៅកម្ពុជានាទសវត្សរ៍កន្លងមក

បន្ទាប់ពីសង្គ្រាមស៊ីវិល (ឆ្នាំ១៩៧០-១៩៧៥) និងរបបប្រល័យពូជសាសន៍កម្ពុជាប្រជាធិតេយ្យ ដែលបានអូសបន្លាយរហូតដល់ឆ្នាំ១៩៧៩ សេដ្ឋកិច្ចកម្ពុជាបានចុះខ្សោយយ៉ាងខ្លាំង ។ មូលដ្ឋានធនធានមនុស្សរបស់ប្រទេសទទួលរងនូវការបាត់បង់ជាទម្ងន់ ។ ហេដ្ឋារចនាសម្ព័ន្ធ និងរោងចក្រឧស្សាហកម្មជាច្រើនទទួលរងនូវការបំផ្លិចបំផ្លាញឬស្ថិតនៅក្នុងស្ថានភាពដ៏អាក្រក់ ។ ពុំមានសេវាសង្គម និងរដ្ឋបាលកណ្តាលទេនៅក្នុងពេលនោះ ។

ការងារស្តារនិងស្ថាបនាប្រទេសជាតិឡើងវិញ ត្រូវបានចាប់ផ្តើមជាបន្ទាន់បន្ទាប់ពីសាធារណរដ្ឋប្រជាមានិតកម្ពុជាត្រូវបានបង្កើតឡើងនៅឆ្នាំ១៩៧៩ ។ ជំនួយមនុស្សធម៌ជាបន្ទាន់ត្រូវបានទទួលពីសហគមន៍អន្តរជាតិពីឆ្នាំ ១៩៧៩-១៩៨២ ។ បន្ទាប់ពីឆ្នាំ១៩៨២ ប្រទេសកម្ពុជាទទួលបានតែជំនួយពីអតីតសហភាពសូវៀត និងពីប្រទេសជាសមាជិកអតីតក្រុមប្រឹក្សាសហប្រតិបត្តិការសេដ្ឋកិច្ចទៅវិញទៅមក ហើយមួយចំនួនតូចតែប៉ុណ្ណោះពីអង្គការទ្វេរនិងពហុភាគី និងអង្គការក្រៅរដ្ឋាភិបាល ។ កិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍ទ្រង់ទ្រាយធំទើបតែចាប់ផ្តើមបន្ទាប់ពីមានការបោះឆ្នោតជាសាកលនាឆ្នាំ១៩៩៣ ។

ទោះបីក្នុងទសវត្សរ៍ឆ្នាំ ១៩៨០ ប្រទេសកម្ពុជាស្ថិតនៅក្នុងភាពឯកោពីការធ្វើពាណិជ្ជកម្ម និងការទទួលជំនួយអន្តរជាតិ ហើយនឹងការប្រទូស្តសារាយនៅតាមព្រំដែនកម្ពុជាថៃក៏ដោយ ក៏រដ្ឋាភិបាលកម្ពុជា (សាធារណៈរដ្ឋប្រជាមានិតកម្ពុជា) បានធ្វើឱ្យមានការរីកចំរើនគួរឱ្យកត់សំគាល់ដោយខិតខំប្រឹងប្រែងខ្លួនឯងដើម្បីកសាងប្រទេសឡើងវិញ ។ ដើម្បីដឹកនាំការស្តារប្រទេសជាតិឡើងវិញ រដ្ឋាភិបាលនាពេលនោះបានចាត់តាំងក្រសួងផែនការឱ្យរៀបចំ *កម្មវិធីស្តារនិងអភិវឌ្ឍន៍សេដ្ឋកិច្ច-សង្គមកិច្ច រយៈពេលប្រាំឆ្នាំ* ចាប់ពីឆ្នាំ ១៩៨៦ ដល់ឆ្នាំ ១៩៩០ ។

*កម្មវិធីស្តារនិងអភិវឌ្ឍសេដ្ឋកិច្ច-សង្គមកិច្ចរយៈពេលប្រាំឆ្នាំលើកទី១ ១៩៨៦-១៩៩០ និងលើកទី២* ពីឆ្នាំ ១៩៩១-១៩៩៥ ត្រូវបានរៀបចំឡើងក្រោមប្រព័ន្ធសេដ្ឋកិច្ចផែនការប្រមូលផ្តុំ ។ ពតិមានដែលបានប្រើប្រាស់នៅក្នុងអំឡុងពេលនៃការរៀបចំការតាមដានត្រួតពិនិត្យនិងវាយតម្លៃវឌ្ឍនភាពនៃការអនុវត្តកម្មវិធីស្តារនិងអភិវឌ្ឍន៍សេដ្ឋកិច្ច-សង្គមកិច្ច (តាមរយៈរបាយការណ៍រយៈពេល ៣ខែ ៦ខែ និង ៩ខែ និងរបាយការណ៍ប្រចាំឆ្នាំ) ភាគច្រើនជាពតិមានរដ្ឋបាល ។

ក្រោមរាជរដ្ឋាភិបាលកម្ពុជា ដែលបានបង្កើតឡើងបន្ទាប់ពីការបោះឆ្នោតជាសាកលនៅឆ្នាំ១៩៩៣ និងរដ្ឋធម្មនុញ្ញថ្មីមួយត្រូវបង្កើតមក *ផែនការអភិវឌ្ឍន៍សេដ្ឋកិច្ច-សង្គមប្រាំឆ្នាំលើកទី១ (១៩៩៦-២០០០) និងលើក*

*ទី២ (២០០១-២០០៥)* បានប្រើប្រាស់ *កម្មវិធីស្តារនិងអភិវឌ្ឍន៍សេដ្ឋកិច្ច-សង្គមកិច្ច* ជាឯកសារគោលដ៏មានសារៈសំខាន់សម្រាប់ជំហានបន្តទៀត ។ ផ្អែកលើមូលដ្ឋានរីកចំរើន និងភាពជោគជ័យនៃការងារក្នុងអំឡុងពេលប៉ុន្មាន ឆ្នាំកន្លងមកនេះ *ផែនការអភិវឌ្ឍន៍សេដ្ឋកិច្ច-សង្គមប្រាំឆ្នាំលើកទី១* បានបង្ហាញជាលើកដំបូងនូវការធ្វើសមាហរណកម្មកម្មវិធីអភិវឌ្ឍន៍ជាតិរយៈពេលមធ្យម ទៅក្នុងបរិបទសេដ្ឋកិច្ចទីផ្សារសេរី ។ ឯកសារទាំងពីរខាងលើត្រូវបានរៀបចំឡើង ដោយមានការគាំទ្រទាំងបច្ចេកទេស និងហិរញ្ញវត្ថុពីធនាគារអភិវឌ្ឍន៍អាស៊ី ប៉ុន្តែស្ថាប័ននេះមិនបានផ្តល់ឬគាំទ្រយន្តការតាមដានត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តផែនការទាំងនេះឡើយ ។ ចក្ខុវិស័យនៃការអភិវឌ្ឍជាចំបងរបស់ផែនការអភិវឌ្ឍន៍រយៈពេលមធ្យមទាំងពីរបានផ្តោតទៅលើការកាត់បន្ថយភាពក្រីក្រតាមរយៈការជំរុញឱ្យមានកំណើនសេដ្ឋកិច្ច ប្រកបដោយចីរភាព ពី ៦ ទៅ ៧ ភាគរយក្នុងមួយឆ្នាំ និងជំរុញឱ្យមានអភិបាលកិច្ចល្អជាងមុន ។ រដ្ឋាភិបាលបានទទួលស្គាល់ពីតួនាទីដ៏សំខាន់របស់ផ្នែកឯកជនក្នុងការអភិវឌ្ឍនិងការបង្កើតការងារ ។

ផែនការទាំងនេះត្រូវដំណើរការស្របពេលជាមួយនិងកម្មវិធីវិនិយោគសាធារណៈ *(កវស)* ៣ឆ្នាំរំកិលលើកដំបូង ពីឆ្នាំ១៩៩៦ ដល់១៩៩៨ ដែលអាចជួយសម្រួលដល់ការធ្វើវិនិយោគទុនតាមការគ្រោងទុក (រួមទាំងកម្មវិធី និងគំរោងកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍) ទៅវិស័យអាទិភាព (ក្នុងចំណោមវិស័យ និងក្នុងវិស័យនិមួយៗ) ។ ដំណើរការរៀបចំ *កវស* ត្រូវបានបន្តធ្វើជារៀងរាល់ឆ្នាំចាប់តាំងពីពេលនោះមក ។ តាំងពីដំណាក់កាលចាប់ផ្តើមដំបូងថវិកាប្រចាំឆ្នាំរបស់រាជរដ្ឋាភិបាលបានបន្សុីជាមួយ *កវស* ។

បន្ថែមលើមុខងារនិងភារកិច្ចដែលមានចែងនៅក្នុងអនុក្រឹត្យលេខ ៥៥ អនក្រ.បក ក្រសួងផែនការត្រូវបានផ្តល់បន្ថែមនូវតួនាទី និងការទទួលខុសត្រូវក្នុងការតាមដាននិងវាយតម្លៃស្ថានភាពនៃភាពក្រីក្រនៅកម្ពុជា និងលើកឡើងនូវអនុសាសន៍គោលនយោបាយសម្រាប់ការកាត់បន្ថយភាពក្រីក្រ តាមរយៈការផលិតនូវឯកសារដូចជា របាយការណ៍ស្តីពីស្ថានភាពនៃភាពក្រីក្រនៅកម្ពុជាឆ្នាំ១៩៩៤, ១៩៩៧, ១៩៩៩ និងឆ្នាំ២០០៤ ដោយប្រើប្រាស់ពត៌មានពីការធ្វើអង្កេតសេដ្ឋកិច្ចសង្គមកិច្ច ដែលដឹកនាំដោយវិទ្យាស្ថានជាតិស្ថិតិ។ ទន្ទឹមនឹងនេះក៏បានរៀបចំរបាយការណ៍អភិវឌ្ឍន៍មនុស្សនៅកម្ពុជាចាប់ពីឆ្នាំ ១៩៩៨ ដល់ឆ្នាំ២០០១ ដោយសហការជាមួយកម្មវិធីអភិវឌ្ឍន៍សហប្រជាជាតិប្រចាំនៅកម្ពុជា។

ក្រៅពីផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគសាធារណៈ ក្រសួងផែនការក៏បានរៀបចំ *យុទ្ធសាស្ត្រជាតិកាត់បន្ថយភាពក្រីក្រ (យជកក)* អនុលោមតាមសំណើរបស់មូលនិធិរូបិយវត្ថុអន្តរជាតិនិងធានាគារពិភពលោក។ ដោយមានកិច្ចសហការជាមួយក្រសួងពាក់ព័ន្ធ និងដៃគូអភិវឌ្ឍន៍ក្រៅប្រទេស ក្រសួងផែនការបានរៀបចំ *យជកក ២០០៣-២០០៥* ដែលបានអនុមតិដោយរាជរដ្ឋាភិបាលកម្ពុជា នៅថ្ងៃទី២០ ខែធ្នូ ឆ្នាំ២០០២ ។ *យជកក* បានកំណត់វិស័យអាទិភាពសំខាន់ៗសម្រាប់ឱ្យកម្ពុជាសម្រេចបាន គោលដៅកាត់បន្ថយភាពក្រីក្ររបស់

រាជរដ្ឋាភិបាលកម្ពុជា ។ *យជកភ* បានអនុមតិដំណោះស្រាយមួយច្បាស់លាស់ កំណត់សកម្មភាពគាំទ្រអ្នកក្រីក្រ ដើម្បីលើកស្ទួយកម្រិតជីវភាពប្រជាជននៅតាមជនបទ ជំរុញឱកាសសម្រាប់ការងារ ធានាឱ្យសុខភាពល្អ ទទួលបានអាហារូបត្ថម្ភ និងការអប់រំកាន់តែប្រសើរជាងមុន និងដើម្បីកាត់បន្ថយភាពងាយរងគ្រោះ ។

គោលនយោបាយជាតិប្រជាជនបានរៀបចំដោយក្រសួងផែនការ ដោយប្រើប្រាស់ពត៌មានពី*ជំរឿនទូទៅនៃប្រជាជនកម្ពុជាឆ្នាំ១៩៩៨* និង*អង្កេតប្រជាសាស្ត្រនិងសុខភាពឆ្នាំ២០០០* ។ គោលនយោបាយជាតិប្រជាជនបានអនុមតិដោយរាជរដ្ឋាបាលកម្ពុជានាថ្ងៃទី១៩ ខែសីហា ឆ្នាំ២០០៣ ។ គោលដៅរួមនៃគោលនយោបាយជាតិប្រជាជន គឺដើម្បីធ្វើឱ្យមានការផ្លាស់ប្តូរក្នុងនិន្នាការប្រជាជន ដើម្បីឈានធ្វើឱ្យទំហំនៃសមាសភាព និងការបែងចែកប្រជាជន ស្របជាមួយនឹងតម្រូវការនៃការអភិវឌ្ឍប្រកបដោយនិរន្តរភាព សម្រាប់ការកាត់បន្ថយភាពក្រីក្រ និងធ្វើឱ្យប្រសើរឡើងកម្រិតជីវភាពរបស់ប្រជាជនកម្ពុជាគ្រប់រូប ។

នៅឆ្នាំ២០០៣ កម្ពុជាបានបោះមួយជំហានទៅមុខក្នុងការកំណត់ដោយខ្លួនឯង គោលដៅរយៈពេលមធ្យមនិងសូចនាករសម្រាប់តាមដានត្រួតពិនិត្យ និងវាយតម្លៃនៅថ្នាក់ជាតិសម្រាប់ឆ្នាំ២០១៥ ។ ការកំណត់នេះគឺផ្អែកលើគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍សកល *(គអសស)* ដែលបានឯកភាពនៅក្នុងសន្និសិទ្ទកំពូលរបស់អង្គការសហប្រជាជាតិស្តីពីគោលដៅសហស្សវត្សរ៍នៅឆ្នាំ២០០០ (ដែលកម្ពុជាគឺហត្ថលេខីមួយក្នុងចំណោមប្រទេសជាច្រើន) ប៉ុន្តែមានការប្រែប្រួលខ្លះពីគោលសហស្សវត្សរ៍សកលដើម្បីឱ្យស្របនិងបរិបទកម្ពុជា ។ គោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍កម្ពុជា *(គអសក)* រួមមាន ៩គោលដៅ ២៥ចំណុចដៅរួម និង១០៦ចំណុចដៅ ដែលគ្របដណ្តប់លើភាពក្រីក្រនិងភាពអត់ឃ្លានធ្ងន់ធ្ងរ សកលកម្មការអប់រំមូលដ្ឋាន ៩ឆ្នាំ សមធម៌យេនឌ័រ និងការផ្តល់អំណាចដល់ស្ត្រី មរណភាពកុមារ សុខភាពមាតា មេរោគហ៊ីវ/ជម្ងឺអេដស៍ ជម្ងឺគ្រុនចាញ់ និងជម្ងឺឆ្លងផ្សេងទៀត ស្ថេរភាពបរិស្ថាន ភាពជាដៃគូសម្រាប់ការអភិវឌ្ឍ ការកញ្ចាត់មីន និងយុទ្ធភ័ណ្ឌបន្សល់ទុកមិនទាន់ផ្ទុះ និងសង្គ្រោះជនរងគ្រោះដោយសារមីន ។

## ១.២ យុទ្ធសាស្ត្រចតុកោណ ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ និងផែនការមេស្ថិតិ

បន្ទាប់ពីបានបង្កើតរាជរដ្ឋាភិបាលថ្មីនៅខែកក្កដា ឆ្នាំ២០០៤ រាជរដ្ឋាភិបាលបានដាក់ចេញនូវយុទ្ធសាស្ត្រចតុកោណ[១] ដែលជាឧបករណ៍មួយសម្រាប់ទ្រទ្រង់ការអនុវត្ត "កម្មវិធីនយោបាយរបស់រាជរដ្ឋាភិបាលកម្ពុជាសម្រាប់និតិកាលទី៣នៃរដ្ឋសភា" ដើម្បីឈានឆ្ពោះទៅសម្រេចបាននូវការកាត់បន្ថយភាពក្រីក្រ ការអភិវឌ្ឍ

[១] យុទ្ធសាស្ត្រចតុកោណបង្ហាញពីកម្មវិធីនយោបាយរបស់រាជរដ្ឋាភិបាលដែលបានបោះឆ្នោតនៅឆ្នាំ ២០០៣ ។ យុទ្ធសាស្ត្រមានមុំបួនជ្រុងទ្រវែងដែលមានអភិបាលកិច្ចជាស្នូល ។ មុំផ្សេងទៀតផ្តោតលើក្របខណ្ឌលក្ខណៈដែលត្រូវការធ្វើយ៉ាងណាអាចអនុវត្តយុទ្ធសាស្ត្របាន ។ មុំទាំងបួនមាន: លើកកំពស់វិស័យកសិកម្ម ស្តារហេដ្ឋារចនាសម្ព័ន្ធរូបវន្ត អភិវឌ្ឍន៍វិស័យឯកជននិងបង្កើតការងារ ក៏ដូចជាការកសាងសម្ថភាព និងការអភិវឌ្ឍធនធានមនុស្ស ។

ប្រកបដោយវឌ្ឍនភាពនិងវិបុលសុខ ព្រមទាំងសុខដុមរមនានិងសុភមង្គលជូនប្រជាជនកម្ពុជា ហើយបន្ទាប់មកទៀត ត្រូវបានរៀបចំនិងដាក់ឱ្យប្រតិបត្តិនៅក្នុងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ( *ផយអជ*) ២០០៦-២០១០។ ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិត្រូវប្រើដែរ ដើម្បីអនុវត្តផែនការសកម្មភាពស្តីពីសុខដុមណីយកម្មនិងបន្សុី ។ ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ( *ផយអជ*) គឺជាផែនការអភិវឌ្ឍជាតិតែមួយដែលត្រូវបានរៀបចំឡើងដោយក្រសួងផែនការ ព្រមទាំងមានការចូលរួមនិងពិគ្រោះយោបល់យ៉ាងទូលំទូលាយពីភាគីដែលមានចំណែកពាក់ព័ន្ធនានា រួមមានក្រសួង-ស្ថាប័ន នានារបស់រាជរដ្ឋាភិបាល ដៃគូអភិវឌ្ឍន៍ក្រៅប្រទេស និងសង្គមស៊ីវិល ។ បន្ទាប់ពីទទួលការអនុម័តពីរាជរដ្ឋាភិបាល សភាជាតិ ព្រឹទ្ធសភា និងឡាយព្រហស្តលេខាដោយព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជារួចមក *ផយអជ* ត្រូវបានប្រកាសដាក់ឱ្យអនុវត្តជាផ្លូវការដោយនាយករដ្ឋមន្ត្រី នៅថ្ងៃទី ១៥ ខែសីហា ឆ្នាំ២០០៦ ។

ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ *ផយអជ* ត្រូវបានរៀបចំឡើងដោយក្រសួងផែនការ ជាឯកសារដែលខ្លឹមានលក្ខណៈជាក់លាក់ អាចវាស់វែងនិងសម្រេចបាន ប្រាកដនិយម និងមានពេលវេលាជាក់លាក់ ដោយប្រើប្រាស់យុទ្ធសាស្ត្រចតុកោណរបស់រាជរដ្ឋាភិបាលដែលមានលក្ខណៈស៊ីជម្រៅ រួមបញ្ចូលជាមួយឯកសារគោលនយោបាយជាអាទិភាពនិងឯកសារគោលជាច្រើនទៀត។ ឯកសារទាំងនេះរួមមាន ផែនការអភិវឌ្ឍន៍សេដ្ឋកិច្ច-សង្គមកិច្ច គោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍កម្ពុជា យុទ្ធសាស្ត្រជាតិកាត់បន្ថយភាពក្រីក្រ គោលនយោបាយជាតិប្រជាជន និងផែនការសកម្មភាពអភិបាលកិច្ចដែលរួមមាន: កំណែទម្រង់រដ្ឋបាលសាធារណៈ កំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈនិងគោលនយោបាយ និងយុទ្ធសាស្ត្រតាមវិស័យជាច្រើនទៀត។

*ផយអជ* ជាឯកសារតែមួយដែលដាក់បញ្ចូលនូវគោលដៅអាទិភាព និងយុទ្ធសាស្ត្ររបស់រាជរដ្ឋាភិបាលកម្ពុជា ដើម្បីកាត់បន្ថយភាពក្រីក្រឱ្យបានឆាប់រហ័ស និងធ្វើឱ្យសម្រេចបាន *គអសក* និងគោលដៅអភិវឌ្ឍន៍សេដ្ឋកិច្ច-សង្គមកិច្ច ដើម្បីជាផលប្រយោជន៍ដល់ប្រជាជនកម្ពុជាទាំងអស់ ។ ឯកសារនេះមានបំណងដើម្បីបន្សុីយុទ្ធសាស្ត្រតាមវិស័យនិងវដ្តផែនការ ក៏ដូចជាដើម្បីណែនាំដៃគូអភិវឌ្ឍន៍ក្រៅប្រទេសឱ្យធ្វើសុខដុមនីយកម្ម និងបន្សុីកិច្ចខិតខំប្រឹងប្រែងរបស់ខ្លួន ធ្វើយ៉ាងណាអាចបង្កើនប្រសិទ្ធភាពជំនួយ និងពន្លឿនការផ្ទេរធនធាន។ ទឹកប្រាក់ប្រមាណ ៣.៥០០ លានដុល្លាអាមេរិក ត្រូវបានប៉ាន់ស្មានសម្រាប់តម្រូវការក្នុងវិស័យសាធារណៈ ដើម្បីធ្វើឱ្យបានសម្រេចគោលដៅ និងចំណុចដៅ ដែលបានកំណត់ក្នុង *ផយអជ (២០០៦-២០១០)* ។

វឌ្ឍនភាពនៃការអនុវត្ត *ផយអជ* នឹងត្រូវបានតាមដានត្រួតពិនិត្យជារៀងរាល់ឆ្នាំ ។ ក្របខ័ណ្ឌការងារតាមដានត្រួតពិនិត្យ និងវាយតម្លៃការអនុវត្ត *ផយអជ* ត្រូវបានរៀបចំឡើងដោយបានពិគ្រោះយោបល់យ៉ាងជិតស្និទជាមួយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ ក្រុមប្រឹក្សាស្តារនិងនិតិសម្បទា/ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា និងក្រសួងពាក់ព័ន្ធផ្សេងទៀត ហើយត្រូវបានអនុម័តនៅខែមិថុនា ឆ្នាំ២០០៦ ។

ក្របខ័ណ្ឌការងារនេះ ត្រូវត្រួតពិនិត្យ និងរាយការណ៍ពីវឌ្ឍនភាពនៃការអនុវត្ត *ផយអជ* ជាពិសេសសូចនាករទាំង ៤៣ របស់ *ផយអជ* (សូមអានឧបសម្ព័ន្ធទី៦) ។ ការតាមដានត្រួតពិនិត្យនេះត្រូវការការផ្តល់ស្ថិតិផ្លូវការដែល អាចរកបាន និងទៀងទាត់ពេលវេលាពីវិទ្យាស្ថានជាតិស្ថិតិ និងពីក្រសួងឬស្ថាប័នពាក់ព័ន្ធនានា ។

បច្ចុប្បន្ននេះ សកម្មភាពតាមដាន *ផយអជ* មានដូចខាងក្រោម :

- ក្រុមការងារបច្ចេកទេសស្តីពីផែនការនិងកាត់បន្ថយភាពក្រីក្រត្រូវបានបង្កើត។ ក្រុមការងារនេះជួបប្រជុំជាទៀងទាត់រៀងរាល់ពីរខែម្តងដើម្បីវាយតំលៃពីវឌ្ឍនភាពនៃការអនុវត្តពីភាគីរដ្ឋាភិបាល និងដៃគូអភិវឌ្ឍន៍ក្រៅប្រទេស ។
- របាយរាយកាណ៍ដំបូងស្តីពីវឌ្ឍនភាពនៃការអនុវត្ត *ផយអជ* ត្រូវបានរៀបចំដោយក្រសួងផែនការដោយមានកិច្ចសហប្រតិបត្តិការពីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ ក្រុមប្រឹក្សាស្តារ និងនិតិសម្បទា/ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា និងក្រសួងចំនួនប្រាំផ្សេងទៀត ។
- ឯកសារទស្សនទាននៃរបាយការណ៍វឌ្ឍនភាពប្រចាំឆ្នាំនៃ *ផយអជ* ត្រូវបានពិគ្រោះយោបល់យ៉ាងជិតស្និទ និងឯកភាពយល់ព្រមពីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ និងក្រុមប្រឹក្សាស្តារនិងនិតិសម្បទា/ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ។

នៅក្នុងឆមាសទី១ នៃឆ្នាំនិមួយៗ ចាប់ពីឆ្នាំ២០០៧ ទៅ របាយការណ៍វឌ្ឍនភាពប្រចាំឆ្នាំនៃការអនុវត្ត *ផយអជ* នឹងត្រូវរៀបចំនិងដាក់ជូនរដ្ឋាភិបាលសម្រាប់ការអនុមតិ ។ របាយការណ៍វឌ្ឍនភាពប្រចាំឆ្នាំនៃការអនុវត្ត *ផយអជ* លើកដំបូងត្រូវបានរៀបចំ និងអនុម័តដោយរាជរដ្ឋាភិបាលកម្ពុជានៅខែឧសភាឆ្នាំ ២០០៧ ។ របាយការណ៍វឌ្ឍនភាពប្រចាំឆ្នាំនៃការអនុវត្ត *ផយអជ* នឹងក្លាយជាឧបករណ៍មួយដើម្បីកែតម្រូវ ឬតម្រង់ទិសជាថ្មីរបស់ *ផយអជ* សម្រាប់ឱ្យការអនុវត្តមានប្រសិទ្ធភាពខ្ពស់ ។ របាយការណ៍វឌ្ឍនភាពប្រចាំឆ្នាំនៃការអនុវត្ត *ផយអជ* នឹងជួយតម្រង់ទិសធនធាន (ទាំងរបស់រាជរដ្ឋាភិបាលនិងដៃគូអភិវឌ្ឍក្រៅប្រទេស) ទៅនឹងគោលដៅ *ផយអជ* និងផ្តល់អនុសាសន៍គោលនយោបាយពីរបៀបធ្វើឱ្យសម្រេចបាននូវវឌ្ឍនភាពបន្ថែមទៀត ក្នុងទិដ្ឋភាពផ្សេងៗនៃការអនុវត្ត *ផយអជ*។

សូចនាករ *ផយអជ* គឺជាឧបករណ៍កំណត់អាទិភាពដ៏សំខាន់ សម្រាប់កម្មវិធីការងារនៃប្រព័ន្ធស្ថិតិកម្ពុជាដែលត្រូវសម្របសម្រួលនិងដឹកនាំដោយវិទ្យាស្ថានជាតិស្ថិតិ/ក្រសួងផែនការ ។ អាទិភាពទាំងនេះមានកំណត់នៅក្នុងផែនការមេស្ថិតិនៃវិទ្យាស្ថានជាតិស្ថិតិ ដែលត្រូវបានឯកភាព និងអនុម័តពីគ្រប់ភាគីពាក់ព័ន្ធទាំងអស់កាលពីខែកញ្ញា ឆ្នាំ២០០៥ ហើយជាបន្តបន្ទាប់បានធ្វើការកែតម្រូវខ្លះៗ ដើម្បីរំលេចការប្រែប្រួលខ្លះក្នុងការធ្វើអង្កេត និងពេលវេលាជំរឿននិងថវិកា។ ក្រុមប្រឹក្សាស្ថិតិតាមរយៈវេទិកាសម្របសម្រួលស្ថិតិ និងដោយអនុវត្តតាមអនុក្រិត្យស្តីពីអង្គការចាត់តាំង និងមុខងារនៃប្រព័ន្ធស្ថិតិជាតិ ក្រុមប្រឹក្សានេះបានសម្រេចជាឯកច្ឆន្ទលើផែនការមេស្ថិតិជាលើកដំបូងនៅឯកិច្ចប្រជុំរបស់ខ្លួនកាលពីខែឧសភាឆ្នាំ២០០៧។ ផែនការមេស្ថិតិនេះត្រូវបាន

ផ្ញើរទៅទីស្តីការគណៈរដ្ឋមន្ត្រីនៅខែមិថុនា ឆ្នាំ២០០៧ ដើម្បីពិនិត្យនិងអនុម័ត ហើយបន្ទាប់មកវានឹងផ្តល់ឱ្យរដ្ឋាភិបាលនិងដៃគូអភិវឌ្ឍន៍ក្រៅប្រទេស ក្នុងការទទួលយកនូវការឯកភាពលើក្របខ័ណ្ឌការងារ សម្រាប់គាំទ្រដល់ប្រព័ន្ធស្ថិតិជាតិសំរាប់រយៈពេលមធ្យម ។ ផែនការមេស្ថិតិបង្ហាញពីដំណោះស្រាយយ៉ាងសំខាន់ចំពោះបញ្ហាស្ថិតិដែលបានកើតមានជាច្រើនទសវត្សរ៍មកហើយ ។ ហេដ្ឋារចនាសម្ព័ន្ធស្ថិតិផ្លូវការនិងសកម្មភាពគឺពុំមានទេក្នុងដើមឆ្នាំ១៩៩០ ។ ការអភិវឌ្ឍស្ថិតិផ្លូវការក្នុងទសវត្សរ៍កន្លងមក គឺធ្វើបានតិចតួច ដោយសាររាជរដ្ឋាភិបាលខ្វះខាតទុននិងមួយផ្នែកធំនាំមុខដោយភាពរកបាននៃធនធានក្រៅប្រទេស ហើយធនធានមួយភាគធំត្រូវបានផ្តត់ផ្គង់សម្រាប់ការងារប្រមូលទិន្នន័យសំខាន់ៗ ។

ទោះបីយ៉ាងណាអង្កេតថ្នាក់ជាតិមួយចំនួនត្រូវបានដឹកនាំ (ដោយមានការគាំទ្រពីអ្នកផ្តល់ជំនួយផ្សេងៗ) នឹងបានផ្តល់នូវពតិមានទិន្នន័យស្ថិតិសំខាន់ៗ ពីស្ថានភាពអភិវឌ្ឍន៍នៅកម្ពុជា ។ វិទ្យាស្ថានជាតិស្ថិតិបានដឹកនាំការធ្វើអង្កេតគ្រួសារគំរូពហុគោលដៅលើកទី១អង្កេតសេដ្ឋកិច្ចសង្គមកិច្ចកម្ពុជានៅឆ្នាំ ១៩៩៣-១៩៩៤, ១៩៩៦ បន្ទាប់មកត្រូវបន្តដោយការអង្កេតសេដ្ឋកិច្ចសង្គមកិច្ចកម្ពុជាឆ្នាំ ១៩៩៧, ឆ្នាំ១៩៩៩ និងឆ្នាំ២០០៣-២០០៤ ។ ការអង្កេតប្រចាំឆ្នាំបន្តមួយទៀតបានចាប់ផ្តើមនៅខែតុលា ឆ្នាំ ២០០៦ ដែលនឹងផ្តល់ការប៉ាន់ស្មានប្រចាំត្រីមាសសម្រាប់សូចនាករផ្សេងៗច្រើនទៀត ។ ទិន្នន័យពីការអង្កេតទាំងនេះ ត្រូវបានប្រើប្រាស់ដើម្បីគិតគូរ (ក្នុងចំណោមពតិមានផ្សេងទៀត) ពីបន្ទាត់ភាពក្រីក្រជាតិ និងស្លាបស្នាមថយចុះនៃការប្រើប្រាស់ក្នុងភាពក្រីក្រនាទសវត្សរ៍កន្លងមក ។ ជំរឿនទូទៅនូវប្រជារាស្ត្រកម្ពុជាបានដំណើរការនៅឆ្នាំ ១៩៩៨[២] បន្ទាប់មកបានរៀបចំអង្កេតពាក់កណ្តាលជំរឿននៅ ឆ្នាំ២០០៤ អង្កេតប្រជាសាស្ត្រនិងសុខភាពកម្ពុជានៅឆ្នាំ ២០០០ និងឆ្នាំ២០០៥ បានផ្តល់ ពតិមានដ៏មានតម្លៃ ស្តីពីនិន្នាការនៃការប្រើប្រាស់សេវាសុខាភិបាល និងសមិទ្ធផលសុខាភិបាល ។ ការរៀបចំរបាយការណ៍គោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍កម្ពុជា និងការបញ្ចូលការតាមដានត្រួតពិនិត្យគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍កម្ពុជាទៅក្នុងការវាយតម្លៃគោលនយោបាយជាតិ (ពិសេសតាមរយៈការតាមដាននិងត្រួតពិនិត្យផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ) បានជួយជំរុញការខិតខំប្រឹងប្រែងដើម្បីប្រមូលដំណើរការ និងរាយការណ៍ស្តីពីសូចនាករសេដ្ឋកិច្ចសង្គមកិច្ចក្នុងរបៀបសមាហរណកម្មមួយជាងមុន ក្នុងក្របខណ្ឌរយៈពេលមធ្យមនៃផែនការមេស្ថិតិ ។ ការខិតខំប្រឹងប្រែងសំខាន់ៗត្រូវបានធ្វើឡើងក្នុងរយៈពេលកន្លងមក ដើម្បីធ្វើឱ្យប្រសើរឡើងប្រព័ន្ធស្ថិតិពិសេសតាមរយៈការធ្វើឱ្យប្រសើរឡើងក្នុងការគ្រប់គ្រងរចនាសម្ព័ន្ធផ្លូវការ ការបណ្តុះបណ្តាលបុគ្គលិក ការអនុវត្តការផ្សព្វផ្សាយ និងភាពអាចទទួលបានទិន្នន័យ ។ បច្ចុប្បន្នប្រព័ន្ធស្ថិតិជាតិកម្ពុជាបានធ្វើសមាហរណកម្ម យ៉ាងល្អទៅក្នុងប្រព័ន្ធស្ថិតិតំបន់ និងអន្តរជាតិ ។

នៅតាមក្រសួង-ស្ថាប័នពាក់ព័ន្ធ ប្រព័ន្ធគ្រប់គ្រងពតិមានច្រើនបែប ដែលដំណើរការទិន្នន័យរដ្ឋបាល និង ទិន្នន័យផ្សេងៗត្រូវបានបង្កើតឡើង ។ ទាំងនេះរួមមាន ប្រព័ន្ធគ្រប់គ្រងពតិមានអប់រំ និងប្រព័ន្ធគ្រប់គ្រង

២ ជំរឿននៃប្រជាជនកម្ពុជាឆ្នាំ១៩៩៨ គឺជាជំរឿនលើកទី១ ចាប់តាំងពីជំរឿនកាលពីអតីតកាលត្រូវបានរៀបចំតាំងពីឆ្នាំ១៩៦២មកម្លេះ

ពតិមានសុខាភិបាល ត្រូវបានពង្រឹងក្នុងរយៈពេលកន្លងមក។ ការសម្របសម្រួលអន្តរប្រព័ន្ធ និងបញ្ហាការពឹងផ្អែកអ្នកផ្តល់ជំនួយចាំបាច់ត្រូវតែមានការដោះស្រាយ ។

តាមរបាយការណ៍នៅថ្នាក់ជាតិ ជាង ៨០ភាគរយ (២៦ ក្នុងចំណោម ៣២សូចនាករ) នៃសូចនាកររបស់ *គអស* យ៉ាងតិចមានទិន្នន័យចំនួនពីរ ជាទិន្នន័យនៅក្នុងអំឡុងពេលពីឆ្នាំ១៩៩០ ដល់២០០៣ ។ នៅកម្រិតអន្តរជាតិ លទ្ធភាពទទួលបានទិន្នន័យមានកម្រិតទាបប្រហែលពីរភាគបី នៃសូចនាកររបស់ *គអស* (២១ ក្នុងចំណោម ៣២ សូចនាករ) យ៉ាងហោចណាស់មានទិន្នន័យចំនួនពីរជាទិន្នន័យនៅក្នុងអំឡុងពេលដូចគ្នា ។ បច្ចុប្បន្នទិន្នន័យថ្មីៗភាគច្រើនអាចរកបាន នៅពេលដែលការអង្កេតប្រជាជនពាក់កណ្តាលជំរឿននៅឆ្នាំ២០០៤ ការអង្កេតសេដ្ឋកិច្ចសង្គមកិច្ចកម្ពុជាឆ្នាំ២០០៤ និងការអង្កេតប្រជាសាស្ត្រនិងសុខភាពកម្ពុជាឆ្នាំ២០០៥ ត្រូវបានបញ្ចប់នាពេលថ្មីៗនេះ ។ បន្ថែមលើនេះទៀត ការអភិវឌ្ឍប្រព័ន្ធស្ថិតិមានសារៈសំខាន់ណាស់ ដើម្បីបំពេញសេចក្តីត្រូវការទិន្នន័យដែលអាចជឿទុកចិត្តបាន និងទាន់ពេលវេលាដែលជាមូលដ្ឋានរបស់សូចនាករការតាមដាន *ផយអជ* ។

## ១.៣ របៀបវារៈនៃសុខដុមនីយកម្ម - បន្សុី - លទ្ធផល

ក្នុងរយៈពេលថ្មីៗកន្លងមកនេះ មានការពិភាក្សាដ៏សំខាន់មួយ និងភាពជឿនលឿនសំខាន់ៗខ្លះ ស្តីពីគោលនយោបាយ ធ្វើយ៉ាងណាដើម្បីធ្វើឱ្យប្រសើរឡើងគុណភាពនៃកិច្ចសហប្រតិបត្តការ ដើម្បីអភិវឌ្ឍន៍តាមរយៈសុខដុមនីយកម្ម (ក្នុងនោះអ្នកផ្តល់ជំនួយផ្សេងៗបានទទួលយកបែបបទរដ្ឋបាលរួមមួយ ដើម្បីកាត់បន្ថយអន្តរតម្លៃ) បន្សុី (ក្នុងនោះអ្នកផ្តល់ជំនួយបានគ្រោងការផ្តល់ជំនួយរបស់ខ្លួន ទៅតាមគោលនយោបាយ និងអាទិភាពរបស់រាជរដ្ឋាភិបាល) និងការផ្តោតលើលទ្ធផល ។ ទាំងនេះមានផលប៉ះពាល់យ៉ាងសំខាន់សម្រាប់ភ្នាក់ងាររដ្ឋាភិបាលទាំងអស់។ ការពិភាក្សានេះ ទាក់ទាញឱ្យមានការពិភាក្សាជាបន្តនៅថ្នាក់អន្តរជាតិ (ក្នុងនោះរាជរដ្ឋាភិបាលត្រូវបានដើរតួយ៉ាងសកម្មមួយ) ដែលបានចងក្រងនៅក្នុងឯកសារជាគន្លឹះពីរ នៃកិច្ចសហប្រតិបត្តការអភិវឌ្ឍន៍ របស់អង្គការសម្រាប់សហប្រតិបត្តការសេដ្ឋកិច្ចនិងអភិវឌ្ឍន៍។

ឯកសារសំខាន់ៗនៅក្នុងបរិបទនេះមានដូចខាងក្រោម :

- សេចក្តីប្រកាសនាទីក្រុងរ៉ូម ស្តីពីជំនួយប្រកបដោយប្រសិទ្ធភាព (ឆ្នាំ២០០៣) បន្ទាប់មក
- សេចក្តីប្រកាសនាទីក្រុងបារីសស្តីពីជំនួយប្រកបដោយប្រសិទ្ធភាព ភាពជាម្ចាស់ សុខដុមនីយកម្ម ការបន្សុីលទ្ធផល និងភាពជឿទុកចិត្តគ្នាទៅវិញទៅមក (ឆ្នាំ២០០៥) ។

រាជរដ្ឋាភិបាលបានស្វែងរកយ៉ាងសកម្ម ដើម្បីប្រែក្លាយការប្តេជ្ញាចិត្ត ក្នុងសេចក្តីប្រកាសពិភពលោកនៅទីក្រុងរ៉ូម និងទីក្រុងប៉ារីស ឱ្យទៅជាគោលការណ៍និងគោលនយោបាយ សម្រាប់ការគ្រប់គ្រងជំនួយប្រកបដោយប្រសិទ្ធភាព។ ឯកសារសំខាន់ៗនៅក្នុងបរិបទនេះមានៈ

- សេចក្តីប្រកាសស្តីពីសុខដុមនីយកម្ម និង បន្សុី របស់រាជរដ្ឋាភិបាលកម្ពុជា និងដៃគូរអភិវឌ្ឍន៍ក្រៅប្រទេស (ឆ្នាំ២០០៤) ។

- ផែនការសកម្មភាពរបស់រាជរដ្ឋាភិបាលស្តីពី សុខដុមនីយកម្ម និងបន្សី ( ឆ្នាំ២០០៤ ) ។
- ក្របខ័ណ្ឌយុទ្ធសាស្ត្រសម្រាប់ការគ្រប់គ្រងកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍របស់រាជរដ្ឋាភិបាលកម្ពុជា ( ឆ្នាំ ២០០៦ ) ។
- សូចនាករសម្រាប់ការតាមដានត្រួតពិនិត្យរួមគ្នាដែលបានព្រមព្រៀងគ្នារវាងរាជរដ្ឋាភិបាលកម្ពុជា និង ដៃគូអភិវឌ្ឍន៍ក្រៅប្រទេស ( ឆ្នាំ២០០៦ ) ។

សេចក្តីប្រកាសនាទីក្រុងរ៉ូម និងទីក្រុងបារីស[៣] និងរបៀបវារៈនៃសុខដុមនីយកម្ម បន្សី និង លទ្ធផល និងឯកសារពាក់ព័ន្ធផ្សេងទៀត បានបង្កើតនូវបញ្ហាប្រឈមដែលមានលក្ខណៈជារចនាសម្ព័ន្ធដូចខាងក្រោម :

- រាជរដ្ឋាភិបាលកម្ពុជាទទួលបាននូវភាពជាម្ចាស់ និងភាពជាអ្នកដឹកនាំក្នុងដាក់ចេញ និងអនុវត្តគោលនយោបាយអភិវឌ្ឍន៍ជាតិ និងក្នុងការគ្រប់គ្រងកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍ ។
- កសាងសមត្ថភាពរបស់រាជរដ្ឋាភិបាលកម្ពុជា ។
- ធ្វើសុខដុមនីយកម្ម និងតម្រង់ទិសការគាំទ្រពីដៃគូអភិវឌ្ឍន៍ក្រៅប្រទេស ។
- តម្រង់ទិសការគាំទ្ររបស់ដៃគូអភិវឌ្ឍន៍ក្រៅប្រទេស ឱ្យស្របជាមួយនឹងគោលនយោបាយរបស់រាជរដ្ឋាភិបាលកម្ពុជា (ជាពិសេសជាមួយ *ផយអជ*) ។
- ជៀសវាងគំរោងដាច់តែឯង ដែលបានអនុវត្តតាមរយៈការគ្រប់គ្រងគម្រោង/អង្គភាពគ្រប់គ្រង និងអនុវត្តគម្រោង) ទៅជាការគ្រប់គ្រងតាមវិស័យជាធំ ឬតាមប្រធានបទក្នុងនោះការគាំទ្រពីអ្នកផ្តល់ជំនួយ បានគ្រោងដោយមានការឯកភាពទៅវិញទៅមកមួយ, ដែលរដ្ឋាភិបាលដឹកនាំយុទ្ធសាស្ត្ររយៈពេលមធ្យម សម្រាប់ផ្នែកស្ថិតក្នុងសំនួរ។
- កាត់បន្ថយអន្តរតម្លៃ និងធ្វើឱ្យប្រសើរឡើងប្រសិទ្ធភាពជំនួយតាមរយៈ (១)ការបែងចែកកម្លាំងរវាងដៃគូអភិវឌ្ឍន៍ក្រៅប្រទេស និង (២) ការអនុវត្តកិច្ចសហប្រតិបត្តិការដែលបានប្រគល់ឱ្យ ។
- បង្កើនជំនួយដែលគ្មានលក្ខខ័ណ្ឌ ។
- ធ្វើឱ្យប្រសើរឡើងប្រសិទ្ធភាពនៃជំនួយបច្ចេកទេស នៅពេលមានការកាត់បន្ថយសមាមាត្រនៃជំនួយសរុបដែលត្រូវបានផ្តល់ឱ្យតាមរយៈយន្តការនេះ។
- ធ្វើឱ្យប្រសើរឡើងប្រសិទ្ធភាពនៃរចនាសម្ព័ន្ធសម្របសម្រួលជំនួយ។

**យន្តការនៃក្រុមការងារបច្ចេកទេសរបស់គណៈកម្មាធិការសម្របសម្រួលរវាងរាជរដ្ឋាភិបាល និងអ្នកផ្តល់ជំនួយ**

ដើម្បីត្រួតពិនិត្យវឌ្ឍនភាពក្នុងការអនុវត្ត ការប្តេជ្ញាចិត្តនៃសេចក្តីប្រកាសនាទីក្រុងរ៉ូម រាជរដ្ឋាភិបាលបានអនុម័ត **ផែនការសកម្មភាពស្តីពី សុខដុមនីយកម្ម និងបន្សី នៅខែធ្នូ ឆ្នាំ២០០៤**។

---

៣ ឯកសារពាក់ព័ន្ធផ្សេងទៀតរបស់រាជរដ្ឋាភិបាលកម្ពុជា រួមមាន របាយការណ៍របស់ក្រុមការងារបច្ចេកទេសស្តីពីសុខដុមនីយកម្មនិង ភាពជាដៃគូ

ការងារសំខាន់ដែលបន្តពីផែនការសកម្មភាពនេះគឺការរៀបចំ *ផយអជ* ឱ្យទៅជាឯកសារនិងផែនការអភិវឌ្ឍន៍តែមួយ ដែលនឹងត្រូវប្រើប្រាស់ជាក្របខណ្ឌការងារដើម្បីតម្រង់ទិស ចំពោះកិច្ចគាំទ្ររបស់ជំនួយអភិវឌ្ឍន៍ក្រៅប្រទេសទាំងអស់ ។

ដើម្បីធ្វើឱ្យប្រសើរឡើងការគ្រប់គ្រងក្នុងការសម្របសម្រួលជំនួយ រាជរដ្ឋាភិបាលកម្ពុជាបានបង្កើតក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ។ នៅឆ្នាំ២០០៤ រាជរដ្ឋាភិបាលកម្ពុជាបានសម្រេចបង្កើតក្រុមការងារបច្ចេកទេសចំនួន ១៧ ក្រុមនៅកម្រិតវិស័យ ហើយនៅខែមិនាឆ្នាំ២០០៥ ក្រុមការងារបច្ចេកទេសទី១៨ ស្តីពីផែនការនិងកាត់បន្ថយភាពក្រីក្រត្រូវបានបង្កើតឡើង ដើម្បីគាំទ្រដល់ការរៀបចំផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ (២០០៦-២០១០) ។ ដើម្បីធានាដល់ការសម្របសម្រួលក្នុងចំណោមក្រុមការងារបច្ចេកទេសទាំង១៨នេះ រាជរដ្ឋាភិបាលបានយល់ព្រម :

- បង្កើត "គណៈកម្មាធិការសម្របសម្រួលរវាងរាជរដ្ឋាភិបាលនិងអ្នកផ្តល់ជំនួយ" ដើម្បីផ្តល់ការណែនាំគោលនយោបាយកំណត់អាទិភាព និងដាក់ចេញវិធានការនានាដើម្បីដោះស្រាយបញ្ហាដែលលើកឡើងដោយក្រុមការងារបច្ចេកទេស ។ គណៈកម្មាធិការសម្របសម្រួលនេះ ដឹកនាំដោយទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងជាអនុប្រធានទីមួយ នៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ។ សមាជិកភាពនៃគណៈកម្មាធិការសម្របសម្រួលរវាង រាជរដ្ឋាភិបាលនិងអ្នកផ្តល់ជំនួយ រួមមានរដ្ឋមន្ត្រី ឬប្រធានស្ថាប័នរដ្ឋ ឯកអគ្គរដ្ឋទូតឬប្រធានបេសកម្មការទូត និងប្រធានស្ថាប័ន ពហុភាគី ។
- បង្កើតលេខាធិការដ្ឋានមួយដើម្បីគាំទ្រគណៈកម្មាធិការសម្របសម្រួលរវាងរាជរដ្ឋាភិបាល និងអ្នកផ្តល់ជំនួយ ។ លេខាធិការដ្ឋាននេះមានទីតាំងនៅក្រុមប្រឹក្សាអភិវឌ្ឍន៍និងនិតិសម្បទាកម្ពុជា ដែលស្ថិតនៅក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ។

កិច្ចប្រជុំរបស់គណៈកម្មាធិការសម្របសម្រួលរវាងរាជរដ្ឋាភិបាល និងអ្នកផ្តល់ជំនួយលើកទី ១ បានប្រព្រឹត្តទៅនៅថ្ងៃទី២ខែធ្នូ ឆ្នាំ២០០៤ (មុនកិច្ចប្រជុំក្រុមការងារពិគ្រោះយោបល់លើកទី៧ដែលបានប្រព្រឹត្តទៅនៅទីក្រុងភ្នំពេញនាថ្ងៃទី៦-៧ខែធ្នូ) បានព្រមព្រៀងលើសូចនាករសម្រាប់ការតាមដានត្រួតពិនិត្យរួមគ្នាក្រោមដំណើរការរបស់ក្រុមការងារពិគ្រោះយោបល់ ។ កិច្ចប្រជុំជាបន្តរបស់គណៈកម្មាធិការសម្របសម្រួល រវាងរាជរដ្ឋាភិបាល និងអ្នកផ្តល់ជំនួយ បានពិនិត្យពីវឌ្ឍនភាពនានាទាក់ទងនឹងសូចនាករសម្រាប់តាមដានត្រួតពិនិត្យដែលបានឯកភាពរួមគ្នាមកហើយ ។

*សូចនាករសម្រាប់ការតាមដានត្រួតពិនិត្យរួមគ្នាឆ្នាំ២០០៦ ដែលជាប់ពាក់ព័ន្ធផ្ទាល់ជាមួយការងារក្រសួងផែនការមានចំនួនបី គឺ:*

- សូចនាករទី១ សម្រាប់អនុវត្តនិងតាមដាន *ផយអជ* និងរៀបចំរបាយការណ៍វឌ្ឍនភាពប្រចាំឆ្នាំ ។
- សូចនាករទី២ សម្រាប់អនុវត្តក្របខណ្ឌយុទ្ធសាស្ត្រដែលបានលើកឡើងខាងលើ សម្រាប់គ្រប់គ្រងកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍ ។
- សូចនាករទី៦ សម្រាប់រៀបចំគោលនយោបាយរស់រានមានជីវិត យោងតាម *ផយអជ* (ជាពិសេសការយកចិត្តទុកដាក់លើវិស័យកសិកម្ម ដីសម្បទាន គោលនយោបាយសុវត្ថិភាពសង្គម អង្កេតប្រព័ន្ធអាហារូបត្ថម្ភ ។ល ។) ។

វេទិកាសហប្រតិបត្តការអភិវឌ្ឍកម្ពុជាដែលបានប្រព្រឹត្តទៅនៅខែមិថុនាឆ្នាំ២០០៧ បានឯកភាពគ្នាលើសូចនាករត្រួតពិនិត្យរួមសម្រាប់ឆ្នាំខាងមុខ ២០០៧-២០០៨ ។ គេបានឯកភាពគ្នាថា សូចនាករត្រួតពិនិត្យរួមនឹងត្រូវកំណត់យកតែមួយក្នុងក្រុមការងារបច្ចេកទេសមួយ ដូច្នេះសូចនាករត្រួតពិនិត្យរួមមានចំនួន ១៨ ។ សូចនាករត្រួតពិនិត្យរួមដែលបានស្នើឡើងដោយក្រសួងផែនការ ក្រោយពីបានពិគ្រោះយោបល់ជាមួយអនុប្រធានក្រុមការងារបច្ចេកទេសគឺមានដូចតទៅ: "ការអនុម័តចុងក្រោយលើផែនការយុទ្ធសាស្ត្រក្រសួងផែនការ" ។

ក្របខណ្ឌយុទ្ធសាស្ត្រសម្រាប់ការគ្រប់គ្រងកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍ (SFDCM) ដែលបានអនុម័តនៅឆ្នាំ ២០០៦ បានគូសបញ្ជាក់ជាថ្មីម្តងទៀតពីសារសំខាន់នៃ *ផយអជ* និងភាពជាម្ចាស់របស់រាជរដ្ឋាភិបាលកម្ពុជា (សូមអានក្របខណ្ឌយុទ្ធសាស្ត្រសម្រាប់ការគ្រប់គ្រងកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍ឆ្នាំ ២០០៦ ទំព័រទី៨) ។ ក្របខណ្ឌយុទ្ធសាស្ត្រនេះ អំពាវនាវទៅគ្រប់ក្រសួងពាក់ព័ន្ធទាំងអស់ (សូមមើលក្របខណ្ឌយុទ្ធសាស្ត្រសម្រាប់ការគ្រប់គ្រងកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍ឆ្នាំ២០០៦ ទំព័រទី៧ និង១០) ដើម្បី :

- ធ្វើជាម្ចាស់ ។
- ផ្តល់ភាពជាអ្នកដឹកនាំ ។
- តម្រង់ទិសនិងបន្សុំជំនួយបច្ចេកទេសពីក្រៅប្រទេស ។
- កាត់បន្ថយចំនួនគំរោង ។
- ដើម្បីចលនាទៅរកការគ្រប់គ្រងតាមកម្មវិធី (PBA), ការគ្រប់គ្រងតាមវិស័យឬតាមវិធានបទជាធំ (SWAps) ឬការគ្រប់គ្រងទូទាំងវិស័យ (SWIM) ។
- ដើម្បីកាត់បន្ថយចំនួននៃអង្គភាពគ្រប់គ្រងឬអនុវត្តគម្រោង (PMUs/PIUs) ចំនួនជំនាញការបរទេស និងការប្រើប្រាស់ជំនួយបច្ចេកទេសបរទេសមិនសមស្រប ។

ការអនុវត្ត របៀបវារៈ សុខដុមនីយកម្ម - បន្សុំ - លទ្ធផល បច្ចុប្បន្ននេះ កំពុងត្រូវបានវាយតំលៃ ដោយ:

- វេទិកាតំបន់អាស៊ីស្តីពីជំនួយប្រកបដោយប្រសិទ្ធភាព (ក្រុងម៉ានីល ខែតុលា ឆ្នាំ២០០៦) ។
- សម្ព័ន្ធអាជីវកម្ម "ការតាមដានសេចក្តីប្រកាសនាទីក្រុងប៉ារីស "(ក្រុងប៉ារីស ខែវិច្ឆិកា ឆ្នាំ២០០៦)

របៀបវារៈទាំងពីរខាងលើ ហាក់ដូចដើរតួនាទីយ៉ាងសំខាន់ (ជាពិសេសចំពោះការកែលម្អឱ្យបានល្អប្រសើរឡើងរបស់ដៃគូអភិវឌ្ឍន៍ក្រៅប្រទេស) ជាថ្មីម្តងទៀតអំពាវនាវឱ្យមានកិច្ចខិតខំប្រឹងប្រែងជាថ្មីបន្ថែមទៀត ដើម្បីផ្ទេរពីភាពជាម្ចាស់ជំនួយ ទៅជាភាពជាម្ចាស់ និងដើម្បីសម្រេចឱ្យបាននូវគោលនយោបាយរួមមួយ និង ក្របខណ្ឌកម្មវិធីតាមរយៈ :

- ការបន្សុីជំនួយរបស់ដៃគូអភិវឌ្ឍន៍ក្រៅប្រទេស ឱ្យស្របជាមួយគោលនយោបាយរបស់រាជរដ្ឋាភិបាល កម្ពុជា ។
- ការធ្វើសុខដុមនីយកម្មនៃគោលនយោបាយរបស់ដៃគូអភិវឌ្ឍន៍ក្រៅប្រទេស និងការអនុវត្ត ។
- បង្កើនការគាំទ្រផ្នែកថវិកា ។
- ជៀសវាងការជំនួសសមត្ថភាព ។
- ធ្វើប្រតិភូកម្មអំណាចទៅឱ្យការិយាល័យប្រចាំប្រទេសរបស់ដៃគូអភិវឌ្ឍន៍ក្រៅប្រទេស ។
- កែលំអការងាររបស់ក្រុមការងារបច្ចេកទេស ។

## ១.៤ ការរៀបចំផែនការយុទ្ធសាស្ត្ររបស់ក្រសួងផែនការ (ផយផក):

ឆ្លើយតបនឹងកម្មវិធីនយោបាយរបស់យុទ្ធសាស្ត្រចតុកោណ យុទ្ធសាស្ត្រអភិវឌ្ឍន៍រយៈពេលប្រាំឆ្នាំ ដែលបានលើកឡើងក្នុង *ផយអជ* និងការប្រឈមសម្រាប់ការអនុវត្តរបៀបវារៈសុខដុមនីយកម្ម-បន្សុី-លទ្ធផល ដែលបានគូសបញ្ជាក់នៅក្នុងក្របខណ្ឌ័យុទ្ធសាស្ត្រសម្រាប់ការគ្រប់គ្រងកិច្ចសហប្រតិបត្តការអភិវឌ្ឍន៍ កាលពីខែតុលា ឆ្នាំ២០០៦ ក្រសួងផែនការបានសម្រេចចិត្តតម្រង់ទិសជាថ្មីការងាររបស់ខ្លួន និងការគ្រប់គ្រងការគាំទ្រពីដៃគូអភិវឌ្ឍន៍ក្រៅប្រទេសចំពោះក្រសួងផែនការក្នុងរបៀបជាយុទ្ធវិធីមួយ ។ ជាលទ្ធផល *ផយផក* បានក្តោបយកការងារសំខាន់ៗរបស់ *ផយអជ* (រួមទាំង *គអសហ*) ហើយផែនការមេស្ថិតិ និងក្របខណ្ឌយុទ្ធសាស្ត្រសម្រាប់ការគ្រប់គ្រងកិច្ចសហប្រតិបត្តិ ការអភិវឌ្ឍន៍ត្រូវបានច្របាច់បញ្ចូលគ្នាស្របតាមយុទ្ធវិធីមួយ ។

ការផ្តោតជាសំខាន់ក្នុងការតម្រង់ទិសជាថ្មី គឺការគាំទ្រក្រសួងផែនការក្នុងដំណើរការ *ផយអជ* រួមមានការរៀបចំផែនការអភិវឌ្ឍន៍ជាតិរយៈពេលមធ្យម និងការតាមដានត្រួតពិនិត្យការអនុវត្ត *ផយអជ* ។ *ផយអជ* ដែលបានរៀបចំដោយក្រសួងផែនការក្នុងឆ្នាំ ២០០៥ ហើយត្រូវបានអនុមតិដោយរាជរដ្ឋាភិបាលនៅឆ្នាំ២០០៦ បញ្ជាក់ពីការចង់បានដើម្បី:

- ចលនាចេញពីវិធីសាស្ត្រផែនការបែបបុរាណ ហើយដាក់ជំនួសវិញនូវវិធីសាស្ត្រមួយដែលផ្តោតលើគោលដៅយុទ្ធសាស្ត្រ និងសកម្មភាព ។
- ណែនាំដំណើរការអភិវឌ្ឍន៍ទាំងមូល ធ្វើយ៉ាងណាដើម្បីប្រយុទ្ធប្រឆាំងនឹងភាពក្រីក្រ និងដើម្បីសម្រេចឱ្យបាន *គអសហ* ។

សេចក្តីត្រូវការសម្រាប់តម្រង់ទិសដៅគឺជាមេរៀនមួយ ដែលទទួលបានពីបទពិសោធន៍ដែលក្រសួងនានាបានអនុវត្តកន្លងមក ក្នុងការរៀបចំការគ្រប់គ្រងតាមវិស័យឬតាមប្រធានបទ ។ មេរៀនផ្សេងទៀតត្រូវរៀនសូត្រពីដំណើរការកែទម្រង់តាមវិស័យនៅកម្ពុជា រួមមានដូចតទៅ:

- បង្កើតក្រុមស្នូលមួយ (ឧ. ក្នុងករណីក្រសួងផែនការ មុខងារនេះត្រូវបំពេញដោយក្រុមការងារទទួលបន្ទុកផែនការយុទ្ធសាស្ត្រ) ។
- កំណត់លទ្ធផលពិតប្រាកដ (ឧ.សម្រាប់ក្រសួងផែនការ គឺតារាងម៉ាទ្រីស នៅក្នុងជំពូកទី៥) ។
- កំណត់ដំណាក់កាល ឬជំហាននៃការអនុវត្ត (ដូចដែលបានកំណត់នៅក្នុងតារាងម៉ាទ្រីស នៃផែនការយុទ្ធសាស្ត្រក្នុងជំពូក ទី៥) ។
- ផ្សព្វផ្សាយឱ្យបានទូលំទូលាយនូវសេចក្តីព្រាងផែនការយុទ្ធសាស្ត្រ (សូមមើលខាងក្រោម) ។
- ឯកភាពលើទិសដៅត្រូវអនុវត្ត (សូមមើលជំពូកទី១.៥) ។

ដើម្បីរៀបចំផែនការយុទ្ធសាស្ត្រទី១សម្រាប់ក្រសួងផែនការ ក្រសួងបានរៀបចំសិក្ខាសាលានៅថ្ងៃទី ១៨ និង ១៩ ខែតុលា ឆ្នាំ២០០៦ នៅក្រុងព្រះសីហនុ ដែលមានសិក្ខាកាមចំនួន ១៦នាក់បានចូលរួម ក្នុងនោះមានថ្នាក់ដឹកនាំរបស់ក្រសួងចំនួន ១៣នាក់ (ភាគច្រើនប្រធាន អនុប្រធាននាយកដ្ឋានមកពីអគ្គនាយកដ្ឋាន ផែនការ សិក្ខាកាមមួយនាក់តំណាងឱ្យវិទ្យាស្ថានជាតិស្ថិតិ) ហើយមានតំណាងបីនាក់មកពីក្រុមការងារបច្ចេកទេសសម្រាប់រៀបចំផែនការនិងកាត់បន្ថយភាពក្រីក្រ ជាអ្នកសម្របសម្រួល (ឧ. តំណាងពីធនាគារពិភពលោក និងអង្គការសហប្រជាជាតិ) ។

លទ្ធផលដែលលេចចេញពីការរៀបចំតារាងម៉ាទ្រីសគឺ ទិសដៅ និងសកម្មភាពដែលជាស្នូលនៃយុទ្ធសាស្ត្រនេះ (សូមអានជំពូកទី៥ និងឧបសម្ព័ន្ធទី១) ។

ក្រោយពីបានធ្វើសេចក្តីព្រាងជាច្រើនលើកច្រើនសារដោយមន្ត្រីក្រសួងផែនការមក សេចក្តីព្រាង *ផយផក* ត្រូវបានអនុម័តដោយថ្នាក់ដឹកនាំក្រសួងផែនការនៅខែកក្កដា ឆ្នាំ២០០៧ ជាផែនការយុទ្ធសាស្ត្រ និងទិសដៅត្រូវអនុវត្តសម្រាប់ក្រសួងផែនការទាំងមូល ។ ឯកសារនេះនឹងបង្ហាញជូនដល់ភាគីពាក់ព័ន្ធសំខាន់ៗ (ជាពិសេសក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ ក្រុមប្រឹក្សាស្តារនិងអភិវឌ្ឍន៍កម្ពុជា/ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា នៅក្នុងកិច្ចប្រជុំដាច់ដោយឡែកពីគ្នា) និងបង្ហាញជូនដល់ដៃគូអភិវឌ្ឍន៍ក្រៅប្រទេស នៅក្នុងសម័យប្រជុំរបស់ក្រុមការងារបច្ចេកទេសសម្រាប់រៀបចំផែនការនិងកាត់បន្ថយភាពក្រីក្រ ដែលគ្រោងនឹងធ្វើនៅខែកក្កដា ឆ្នាំ២០០៧ខាងមុខនេះ។ សេចក្តីព្រាងចុងក្រោយនៃ *ផយផក* នឹងត្រូវផ្សព្វផ្សាយដល់អ្នកដែលមានចំណែកពាក់ព័ន្ធទាំងអស់ និងត្រូវផ្សព្វផ្សាយនៅលើគេហទំព័ររបស់ក្រសួងផែនការ www.mop.gov.kh ផងដែរ ។

តំលៃពិតប្រាកដរបស់ *ផយផក* គឺជាឯកសារយោងតែមួយសម្រាប់ភាគីពាក់ពន្ធ័ទាំងអស់ ដែលចាប់អារម្មណ៍ក្នុងការកែលំអការងារផែនការ និងការកាត់បន្ថយភាពក្រីក្ររបស់កម្ពុជា ។ យើងសង្ឃឹមថា *ផយផក* នឹងជួយសំរួល ដល់ដៃគូអភិវឌ្ឍន៍ក្រៅប្រទេស រៀបចំវិធីសាស្ត្ររួមគ្នាមួយដើម្បីគាំទ្រសមត្ថភាពរាជរដ្ឋាភិបាលសម្រាប់ការរៀបចំផែនការយុទ្ធសាស្ត្រដែលផ្តោតលើភាពក្រីក្រ និងជួយចលនាការគាំទ្រសេចក្តីត្រូវការ ដើម្បីធ្វើកម្មវិធីការងារកែទម្រង់នេះ ។

## ១.៥ ទិសដៅត្រូវអនុវត្ត

ជំហានបន្ទាប់ដែលត្រូវអនុវត្តទាក់ទងនឹងការអនុវត្ត *ផយផក* ត្រូវបានកំណត់នៅក្នុងផែនទីចង្អុលផ្លូវដូចខាងក្រោម ៖

- ការងាររបស់ក្រុមការងារដែលមានស្រាប់ (ឧ.ក្រុមការងាររៀបចំគេហទំព័រ) ត្រូវបន្តការអនុវត្ត ។
- ក្រុមការងារដទៃទៀត ត្រូវតែចាប់ផ្តើមប្រតិបត្តិការងាររបស់ខ្លួន (ក្រុមការងារទទួលបន្ទុកយុទ្ធសាស្ត្រ ទំនាក់ទំនងក្រុមការងារទទួលបន្ទុកស្ថិតិ/ការតាមដាន *ផយអជ* និងវិភាគគោលនយោបាយ និងក្រុមការងារទទួលបន្ទុកការរៀបចំរបាយការណ៍វឌ្ឍនភាពប្រចាំឆ្នាំ ។ល។)
- អនុលោមតាមសេចក្តីថ្លែងការណ៍របស់ខ្លួន ដែលធ្វើនៅក្នុងកិច្ចប្រជុំរបស់ក្រុមការងារបច្ចេកទេសសម្រាប់រៀបចំផែនការនិងកាត់បន្ថយភាពក្រីក្រ ដែលបានប្រព្រឹត្តទៅនៅតែតុលាឆ្នាំ២០០៦ ដៃគូអភិវឌ្ឍន៍ខាងក្រៅ និងគាំទ្រ *ផយផក* ភ្លាមនៅពេលណាសេចក្តីព្រាង *ផយផក* ត្រូវបានបញ្ចប់និងអនុម័ត) ។ ការគាំទ្រនេះរួមមាន ការគាំទ្រផ្នែកហិរញ្ញវត្ថុ បច្ចេកទេស និងធនធានមនុស្ស ។ ដៃគូអភិវឌ្ឍន៍ក្រៅប្រទេសបានត្រៀមជួយគៀរគរធនធានបន្ថែមទៀត ពីម្ចាស់ជំនួយដទៃទៀតនៅពេលណាក្របខណ្ឌយុទ្ធសាស្ត្រ (ឧ. *ផយផក*) ត្រូវបានបញ្ចប់ ។
- ដៃគូអភិវឌ្ឍន៍ក្រៅប្រទេសបានសន្យាដែរកាលពីខែតុលា ឆ្នាំ២០០៦ ដើម្បីរៀបចំជា"ការគ្រប់គ្រងរួមគ្នាមួយ (ការគ្រប់គ្រងតាមវិស័យ ឬតាមប្រធានបទ)" ។
- ការពិនិត្យមើល *ផយផក* ឡើងវិញប្រចាំឆ្នាំ (សូមអានជំពូកទី៧) នឹងប្រព្រឹត្តទៅនៅក្នុងសម័យប្រជុំក្រុមការងារបច្ចេកទេសសម្រាប់រៀបចំផែនការនិងកាត់បន្ថយភាពក្រីក្រ នៅបណ្តាច់ឆ្នាំនិមួយៗ។
- *ផយផក* ថ្មីមួយនឹងត្រូវរៀបចំនៅឆ្នាំ២០០៩ (សម្រាប់ *ផយអជ* ថ្មីដែលនឹងចាប់ផ្តើមពីឆ្នាំ ២០១១) ។

# ជំពូកទី២

## រចនាសម្ព័ន្ធនិងការទទួលខុសត្រូវ ចក្ខុវិស័យនិងបេសកម្មរបស់ក្រសួងផែនការ

### ២.១ រចនាសម្ព័ន្ធស្ថាប័ន និង ការទទួលខុសត្រូវរបស់ក្រសួងផែនការ

យោងតាមអនុក្រឹត្យលេខ ៥៥អនក្រ.បក របស់រាជរដ្ឋាភិបាលកម្ពុជាស្តីពី "ការរៀបចំនិងមុខងាររបស់ក្រសួងផែនការ" ចុះថ្ងៃទី ២៣ ខែសីហា ឆ្នាំ ១៩៩៧ ក្រសួងផែនការមានអគ្គនាយកដ្ឋាន[៤] ចំនួនបីដូចខាងក្រោម :

- អគ្គនាយកដ្ឋានផែនការ
- វិទ្យាស្ថានជាតិស្ថិតិ និង
- អគ្គាធិការដ្ឋាន ។

បន្ថែមពីនេះទៀត ក្រសួងផែនការមានស្ថាប័ននៅក្រោមឱវាទជាច្រើនទៀត មានដូចជា:

- ខុទ្ទកាល័យរដ្ឋមន្ត្រី
- នាយកដ្ឋានបុគ្គលិក
- នាយកដ្ឋានរដ្ឋបាលទូទៅ
- នាយកដ្ឋានផ្គត់ផ្គង់ និងហិរញ្ញវត្ថុ
- នាយកដ្ឋានសវនកម្ម ត្រូវបានបង្កើតពីឆ្នាំ ២០០៦

**អគ្គនាយកដ្ឋានផែនការ** ដឹកនាំដោយអគ្គនាយក និងអគ្គនាយករងមួយចំនួន ។ អគ្គនាយដ្ឋានផែនការនេះចែកជា ៥នាយកដ្ឋាន នាយកដ្ឋាននិមួយៗដឹកនាំដោយប្រធាននាយកដ្ឋានមួយរូប និងជំនួយដោយអនុប្រធាននាយកដ្ឋានមួយចំនួនតាមតម្រូវការ :

- នាយកដ្ឋានផែនការទូទៅ
- នាយកដ្ឋានផែនការសេដ្ឋកិច្ច
- នាយកដ្ឋានផែនការសង្គមកិច្ច
- នាយកដ្ឋានផែនការវិនិយោគ និង
- នាយកដ្ឋានទំនាក់ទំនងអន្តរជាតិ

**វិទ្យាស្ថានជាតិស្ថិតិ** ដឹកនាំដោយអគ្គនាយកមួយរូប និងជំនួយដោយអគ្គនាយករងជាច្រើនរូបតាមតម្រូវការ ។ វិទ្យាស្ថានជាតិស្ថិតិ មាន៤នាយកដ្ឋាន ដែលនាយកដ្ឋាននិមួយៗដឹកនាំដោយប្រធាននាយកដ្ឋានមួយរូប និងជំនួយដោយអនុប្រធាននាយកដ្ឋានមួយចំនួនតាមតម្រូវការ :

---

[៤] សូមអានអង្គការលេខនៃក្រសួងផែនការ ក្នុងឧបសម្ព័ន្ធ៤

- នាយកដ្ឋានស្ថិតិទូទៅ
- នាយកដ្ឋានស្ថិតិសេដ្ឋកិច្ច
- នាយកដ្ឋានស្ថិតិសង្គមកិច្ច
- នាយកដ្ឋានស្ថិតិប្រជាសាស្ត្រ ជំរឿន និងអង្កេត ។

## ២.២ ចក្ខុវិស័យ និងបេសកម្មរបស់ក្រសួងផែនការ

ចក្ខុវិស័យរួម និងបេសកម្មរបស់ក្រសួងផែនការ បែងចែងដូចខាងក្រោម :

*ក្រសួងផែនការទទួលខុសត្រូវក្នុងការដឹកនាំ និងគ្រប់គ្រងការរៀបចំផែនការអភិវឌ្ឍន៍សេដ្ឋកិច្ចសង្គមកិច្ច និងមុខងារស្ថិតិ ដោយសហការជាមួយក្រសួង និងស្ថាប័នពាក់ព័ន្ធនៅក្នុងព្រះរាជាណាចក្រកម្ពុជា ។*

ចក្ខុវិស័យបន្ថែម និងបេសកម្មជាក់លាក់នៃស្ថាប័នទាំងពីររបស់ក្រសួងផែនការ (អគ្គនាយដ្ឋានផែនការ និងវិទ្យាស្ថានជាតិស្ថិតិ) ត្រូវបានកំណត់ដែរ ។

**ចក្ខុវិស័យ និងបេសកម្មរបស់អគ្គនាយកដ្ឋានផែនការ មានដូចខាងក្រោម :**

- ដឹកនាំនិងគ្រប់គ្រងការរៀបចំផែនការអភិវឌ្ឍន៍សេដ្ឋកិច្ច-សង្គមកិច្ច(ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ) ដោយសហការជាមួយក្រសួង-ស្ថាប័ន និងអាជ្ញាធរជាតិថ្នាក់ក្រោម ។
- សហការជាមួយវិទ្យាស្ថានជាតិស្ថិតិ និងស្ថាប័នដទៃ ដើម្បីវិភាគសេដ្ឋកិច្ច-សង្គមកិច្ច ម៉ាក្រូសេដ្ឋកិច្ច និងគោលនយោបាយនានាដែលទាក់ទងនឹង *ផយអជ* ។
- ត្រួតពិនិត្យនិងវាយតម្លៃលទ្ធផល និងការអនុវត្ត *ផយអជ* ដើម្បីផ្តល់អនុសាសន៍គោលនយោបាយ ។

**ចក្ខុវិស័យរបស់វិទ្យាស្ថានជាតិស្ថិតិៈ**

ចក្ខុវិស័យរបស់វិទ្យាស្ថានជាតិស្ថិតិ ត្រូវបានចែងនៅក្នុងផែនការយុទ្ធសាស្ត្ររបស់វិទ្យាស្ថានជាតិស្ថិតិឆ្នាំ២០០២-២០០៦ ។ ចក្ខុវិស័យរបស់វិទ្យាស្ថានជាតិស្ថិតិ ត្រូវពិពណ៌នាតាមរយៈគោលការណ៍ប្រាំមានជាអាទិ៍ៈ ទំនាក់ទំនងការរួមបញ្ចូល ភាពអាចរកបាន ប្រកបដោយវិជ្ជាជីវៈ និងជំនឿទុកចិត្ត ។ បន្ទាប់នេះ ជាបេសកម្មរបស់វិទ្យាស្ថានជាតិស្ថិតិ :

*វិទ្យាស្ថានជាតិស្ថិតិមានបេសកម្មសម្របសម្រួល ប្រមូលចងក្រង វិភាគ និងផ្សព្វផ្សាយស្ថិតិផ្លូវការប្រកបដោយគុណភាពខ្ពស់ ហើយទិសដៅស្ថិតិផ្លូវការគឺដើម្បីគាំទ្រដល់ការផ្តល់ពត៌មានសម្រាប់ការធ្វើសេចក្តីសំរេចចិត្ត ជជែកវែកញែក និងពិភាក្សានៅក្នុងរាជរដ្ឋាភិបាល អាជ្ញាធរខេត្តនិងឃុំ អ្នកជំនួញ និងប្រព័ន្ធឃោសនា ព្រមទាំងសហគមន៍ជាតិនិងអន្តរជាតិ ។*

# ជំពូកទី៣

## ឯកសារផ្សេងទៀតរបស់រាជរដ្ឋាភិបាល ដែលបង្កើតឱ្យមានភារកិច្ចបន្ថែមដល់ក្រសួងផែនការ

ក្រៅពីការរៀបចំឯកសារមូលដ្ឋានដែលជាសមត្ថកិច្ចរបស់ខ្លួន ដូចជាផែនការអភិវឌ្ឍន៍សេដ្ឋកិច្ចសង្គមកិច្ចរយៈពេលមធ្យម ក្រសួងផែនការបានចូលរួមក្នុងការរៀបចំឯកសារគោលនយោបាយ អភិវឌ្ឍន៍សំខាន់ៗ ជាច្រើនទៀត ។ ចាប់តាំងពីអនុក្រឹត្យលេខ ៥៥ អនក្រ.បក ត្រូវបានចូលជាធរមានក្នុងឆ្នាំ ១៩៩៧ ក្រសួងផែនការ ត្រូវបានចាត់តាំងឱ្យទទួលខុសត្រូវបន្ថែមទៀតសម្រាប់ការតាមដាន ត្រួតពិនិត្យនិន្នាការភាពក្រីក្រនៅកម្ពុជា និងរៀបចំអន្តរាគមន៍គោលនយោបាយកាត់បន្ថយភាពក្រីក្រ និងផលិតនូវឯកសារគោលនយោបាយសំខាន់ៗដូចជា ផែនការយុទ្ធសាស្ត្រជាតិកាត់បន្ថយភាពក្រីក្រ គោលនយោបាយជាតិប្រជាជន ផែនការមេស្ថិតិ និងច្បាប់ស្ថិតិ ។ល ។

ដូចបានរៀបរាប់លម្អិតខាងលើ ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ( *ផយអជ* ) ២០០៦-២០១០ គឺជាឯកសារតែមួយគត់បញ្ជាក់ពីគោលដៅនិងយុទ្ធសាស្ត្រជាអាទិភាពរបស់រាជរដ្ឋាភិបាលកម្ពុជា។ ( *ផយអជ* ) តម្រង់ទិស គោលនយោបាយសាធារណៈទាំងអស់ ឆ្ពោះទៅការកាត់បន្ថយភាពក្រីក្រ និងសម្រេចឱ្យបាននូវ *គអសក* និងគោលដៅ អភិវឌ្ឍន៍សេដ្ឋកិច្ច-សង្គមកិច្ចដទៃទៀត ដើម្បីជាផលប្រយោជន៍ដល់ប្រជាជនកម្ពុជាទាំងមូល ។ ឯកសារនេះបាន ចម្រាញ់បញ្ចូលគ្នា និងកំណត់អាទិភាពនិងការប្តេជ្ញាចិត្ត ដែលបានធ្វើក្នុងយុទ្ធសាស្ត្ររយៈពេលមធ្យមកន្លងមកថ្មីៗនេះ (ដូចជាផែនការអភិវឌ្ឍន៍សេដ្ឋកិច្ចសង្គមកិច្ចលើកទី២, ២០០១-២០០៥, យុទ្ធសាស្ត្រជាតិកាត់បន្ថយភាពក្រីក្រ *យជកក* ២០០៣-២០០៥ *គោលនយោបាយជាតិប្រជាជនឆ្នាំ២០០៣* និងរបាយការណ៍ *គអសក* ព្រមទាំងមានបំណង ធ្វើសុខដុមនីយកម្មយុទ្ធសាស្ត្រ និងវដ្តផែនការតាមវិស័យ ទៅនឹងទស្សនៈវិស័យយូរអង្វែង ក៏ដូចជាណែនាំដៃគូអភិវឌ្ឍន៍ក្រៅប្រទេសឱ្យតម្រង់ទិសនិងសុខដុមនីយកម្មនូវកិច្ចប្រឹងប្រែងរបស់ខ្លួនឆ្ពោះទៅរកប្រសិទ្ធភាពជំនួយដ៏ប្រសើរ និងការផ្ទេរធនធានខ្ពស់ជាងមុន ។ ចំណុចដៅចំនួន ៤៣ នៅក្នុងគោលដៅសំខាន់ៗ ដែលបានលើកឡើងនៅក្នុងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ មានដូចខាងក្រោម ៖

- លុបបំបាត់ភាពក្រីក្រ និងភាពអត់ឃ្លានធ្ងន់ធ្ងរ
- អភិវឌ្ឍវិស័យកសិកម្ម និងបង្កើនផលិតកម្មនិងផលិតភាពកសិកម្ម
- អនុវត្តផែនការយុទ្ធសាស្ត្រវិស័យអប់រំ
- អនុវត្តផែនការយុទ្ធសាស្ត្រវិស័យសុខាភិបាល
- អនុវត្តគោលនយោបាយប្រជាជន
- អភិវឌ្ឍជនបទឱ្យកាន់តែឿនលឿន
- ធានានិរន្តរភាពបរិស្ថាន

- ជំរុញសមភាពយេនឌ័រ
- អនុវត្តកំណែទំរង់អភិបាលកិច្ចល្អ
- ធ្វើឱ្យមាននិរន្តភាពកំណើនម៉ាក្រូសេដ្ឋកិច្ចខ្ពស់
- ធ្វើឱ្យប្រសើរឡើងការអនុវត្តថវិកា
- បង្កើនល្បឿនកំណើនឧស្សាហកម្ម
- បន្តអភិវឌ្ឍវិស័យឯកជន
- បង្កើនល្បឿនពាណិជ្ជកម្ម (ឧ. ការនាំចេញ)
- អភិវឌ្ឍវិស័យទេសចរណ៍
- ធ្វើឱ្យមានការជឿនលឿនលើវិស័យដោះមីន និងផ្តល់ជំនួយដល់ជនរងគ្រោះ
- ស្តារឡើងវិញនូវហេដ្ឋារចនាសម្ព័ន្ធរូបវ័ន្ត
- អភិវឌ្ឍវិស័យថាមពលបន្ថែមទៀត

សេចក្តីលំអិតនៃយុទ្ធសាស្ត្រ (តាមវិស័យ) ផ្សេងៗទៀតមាននៅជំពូកទី៤ នៃផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ។ ច្បាប់ស្តីពីស្ថិតិថ្មីបានអនុមតិនៅខែឧសភា ឆ្នាំ២០០៥ ។ ច្បាប់នេះផ្តល់មូលដ្ឋានច្បាប់ជាក់លាក់ដល់វិទ្យាស្ថានជាតិស្ថិតិ ដើម្បីអនុវត្តការងារហើយផ្តល់តួនាទីកាន់តែធំទូលាយក្នុងការអភិវឌ្ឍស្ថិតិផ្លូវការ និងប្រព័ន្ធស្ថិតិទាំងមូល ។ ច្បាប់នេះបានក៏បានលើកទឹកចិត្តបញ្ចូលប្រព័ន្ធស្ថិតិជាតិ ដោយធ្វើឱ្យវិទ្យាស្ថានជាតិស្ថិតិក្លាយជាអង្គភាពរៀបចំគោលនយោបាយស្ថិតិផ្លូវការជាមួយការទទួលខុសត្រូវក្នុងការសម្របសម្រួលសកម្មភាពស្ថិតិផ្លូវការ នៅលើអង្គភាពស្ថិតិទាំងអស់ជាមួយក្រសួង និងស្ថាប័ននានារបស់រាជរដ្ឋាភិបាល ។ មានអនុក្រិត្យពីរផ្សេងទៀតដែលតម្រូវឱ្យមាន ដើម្បីបំពេញឱ្យបានពេញលេញក្របខណ្ឌផ្លូវច្បាប់សម្រាប់ប្រព័ន្ធស្ថិតិជាតិៈ

១. រចនាសម្ព័ន្ធ និងមុខងាររបស់ប្រព័ន្ធស្ថិតជាតិបានអនុម័តនៅខែមករាឆ្នាំ២០០៧។ អនុក្រិត្យនេះបានកំណត់អំពីនីតិវិធីសម្រាប់ការចាត់តាំងអគ្គនាយកនៃវិទ្យាស្ថានជាតិស្ថិតិ និងក្នុងការតម្រូវឱ្យគ្រប់ក្រសួងពាក់ព័ន្ធទាំងអស់ត្រូវមានអង្គភាពស្ថិតិរបស់ខ្លួន។ ការអនុម័តឱ្យមាននូវយន្តការសម្របសម្រួលស្ថិតិជាតិ ដែលជាអង្គភាពសម្របសម្រួលរបស់ក្រុមប្រឹក្សាស្ថិតិ និងអនុគណៈកម្មការសម្របសម្រួលស្ថិតិរបស់ខ្លួន ក៏ដូចជាមានសិទ្ធិអំណាចបញ្ញត្តិទោសនានាចំពោះការផ្តល់ទិន្នន័យដោយអង្គភាពទាំងឡាយណាដែលមិនគោរពតាមការស្នើឱ្យផ្តល់ជាផ្លូវការនូវទិន្នន័យស្ថិតិ និងការធ្វើឱ្យបែកធ្លាយនូវការសម្ងាត់ ដោយបុគ្គលិកស្ថិតិដែលជាតំណាងអង្គភាពដែលបានចាត់តាំង។

២. ស្ថិតិផ្លូវការដែលបានចាត់តាំង (ឯកសារព្រាងដែលនឹងត្រូវដាក់ឱ្យអនុម័តដោយក្រុមប្រឹក្សាស្ថិតិនៅចុងឆ្នាំ២០០៧) បានចែងថា ទិន្នន័យស្ថិតិត្រូវតែផលិត និងផ្តល់ដោយក្រសួងពាក់ព័ន្ធដល់វិទ្យាស្ថានជាតិស្ថិតិ ។ អនុក្រិត្យនេះបានចែងផងដែរ អំពីគោលការណ៍នៃការចែករំលែកទិន្នន័យ

នៅកំរិតទាប បំផុតតាមលទ្ធភាពដែលអាចធ្វើបាន ទន្ទឹមនោះក៏ត្រូវគិតគូរដល់ការរក្សាការសម្ងាត់ ក៏ដូចជាការ បង្កើត ការិយាល័យផ្តល់លិខិតអនុញ្ញាត ។

ផែនការមេស្ថិតិគឺជាឯកសារយុទ្ធសាស្ត្រមួយ ដែលបានដាក់ចេញនូវទស្សនៈវិស័យ និងគោលដៅសំរាប់ប្រព័ន្ធស្ថិតិជាតិ ២០០៨-២០១៥។ ផែនការមេស្ថិតិក៏មានកំណត់ផែនការអាទិភាពរយៈពេលវែង សំរាប់ប្រព័ន្ធស្ថិតិជាតិកម្ពុជាផងដែរ។ ផែនការមេនេះគ្របដណ្តប់ទាំងស្រុងនៃប្រព័ន្ធស្ថិតិជាតិ ដែលរួមមានវិទ្យាស្ថានជាតិស្ថិតិ អង្គភាពស្ថិតិ តាមបណ្តាក្រសួងពាកក់ព័ន្ធ និងធនាគារជាតិនៃកម្ពុជា។ ផែនការមេស្ថិតគឺជាក្របខណ្ឌការងារមួយ ដែលនៅក្នុងនោះអាទិភាពតម្រូវការ និងធនធានដើម្បីសម្រេចគោលដៅ និងចក្ខុវិស័យរបស់វិទ្យាស្ថានជាតិស្ថិតិ និងប្រពន្ឋ័ស្ថិតិជាតិត្រូវបានគិតគូរ ។ ដោយប្រើប្រាស់ផែនការមេស្ថិតិជាឧបករណ៍គ្រប់គ្រងស្ថិតិមួយ ទិន្នន័យស្ថិតិ នឹងត្រូវផលិតដើម្បីបំពេញសេចក្តីត្រូវការជាអាទិភាពរបស់ប្រទេសកម្ពុជា ។

ផែនការមេស្ថិតិត្រូវបានកសាងឡើងដោយផ្អែកទៅលើការងារកន្លងមករបស់វិទ្យាស្ថានជាតិស្ថិតិ រួមមានការរៀបចំផែនការយុទ្ធសាស្ត្រប្រាំឆ្នាំ និងកម្មវិធីការងារសម្រាប់រយៈពេលប្រាំឆ្នាំខាងមុខ។ ផែនការមេនេះក៏បានបង្ហាញផងដែរអំពីការងារដែលបានអនុវត្តកន្លង តាមរយៈសិក្ខាសាលាស្តីពីការកសាងសមត្ថភាពស្ថិតិដែលរៀបចំឡើងដោយក្រសួងផែនការ និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុកាលពីខែតុលា ឆ្នាំ២០០២ ដែលមានគំរោងស្ថិតិជាអាទិភាពធំៗមួយចំនួន ត្រូវបានស្នើរឡើងដោយក្រសួង ស្ថាប័នផ្សេងៗ ធនាគារជាតិនៃកម្ពុជា និងវិទ្យាស្ថានជាតិស្ថិតិ។ ផែនការមេស្ថិតិបានផ្តល់នូវទស្សនៈយុទ្ធសាស្ត្ររយៈពេលវែង និងតម្រូវការហិរញ្ញវត្ថុរយៈពេលវែងផងដែរក្នុងការរៀបចំផែនការការងារស្ថិតិ (ផែនការរយៈពេលវែង និងជួនកាលមានរយៈពេលរហូតដល់ចំនួនជាច្រើនឆ្នាំ)។ ផែនការមេស្ថិតិមានបំណងក្លាយទៅជាឯកសារយុទ្ធសាស្ត្រសំខាន់សម្រាប់សម្រួលដល់ការសម្របសម្រួលនៃប្រព័ន្ធស្ថិតិជាតិ និងការធ្វើសុខដុមនីយកម្ម និងបន្សីការគាំទ្រពីអ្នកផ្តល់ជំនួយ។

# ជំពូកទី៤

## មេរៀននិងបទពិសោធន៍

### ៤.១ គុណវិបត្តិដែលបានពិនិត្យឃើញក្នុងដំណើរការស្ថិតិនិងផែនការៈ

ផ្អែកលើបទពិសោធន៍ពីរទសវត្សកន្លងមក ជាមួយការរៀបចំយុទ្ធសាស្ត្រអភិវឌ្ឍន៍រយៈពេលមធ្យមនិងការងារស្ថិតិ ក្រសួងផែនការបានកំណត់បញ្ហាប្រឈម ក្នុងការសម្រេចបានទិសដៅទាំងឡាយដែលបានកំណត់នៅក្នុងចក្ខុវិស័យ និងបេសសកម្មខាងលើដូចតទៅ។ គុណវិបត្តិនៃការងារកន្លងមកក្នុងការរៀបចំផែនការអភិវឌ្ឍន៍រយៈពេលមធ្យម (ឧ. ផែនការស្តារសេដ្ឋកិច្ច សង្គមកិច្ចលើក ទី១ និងទី២, ផែនការអភិវឌ្ឍន៍សេដ្ឋកិច្ចសង្គមកិច្ចលើកទី ១ និងទី២ និងផែនការជាតិកាត់បន្ថយភាពក្រីក្រ) រួមមានដូចខាងក្រោម :

- កង្វះវិធីសាស្ត្រជាក់លាក់មួយ (ដូចជា អាទិភាពមិនច្បាស់លាស់ និងខ្វះសកម្មភាពជាក់លាក់)
- គ្មានប្រព័ន្ធតាមដាន (រួមមានសូចនាករ) និងការតាមដានត្រួតពិនិត្យប្រកបដោយប្រសិទ្ធភាព
- គ្មានការកំណត់ពេលវេលាច្បាស់លាស់
- គ្មានការប៉ាន់ស្មានថវិកា និងការវិភាជន៍ធនធានច្បាស់លាស់ទៅតាមផែនការ

ក្រៅពីកង្វះខាតទាំងនេះ ឯកសារផែនការខ្លួនឯងក៏មានបញ្ហាដូចខាងក្រោម ក្នុងពេលអនុវត្តៈ

- ភាពមិនស៊ីចង្វាក់គ្នារវាងផែនការជាតិ កម្មវិធីវិនិយោគសាធារណៈ និងដំណើរការថវិកាប្រចាំឆ្នាំ
- កង្វះខាតកិច្ចប្រតិបត្តិការ (នៅក្នុងការបម្លែងយុទ្ធសាស្ត្ររយៈពេលមធ្យមទៅក្នុងផែនការសកម្មភាពប្រចាំឆ្នាំ) និងកង្វះខាតការអនុវត្តផែនការ
- បញ្ហានយោបាយ (គោលនយោបាយក្នុងប្រទេស វិបត្តិហិរញ្ញវត្ថុនៅទ្វីបអាស៊ី ។ល។)

ទីបញ្ចប់បញ្ហាដែលកើតមានឡើងក្នុងការអនុវត្តយុទ្ធសាស្ត្រជាតិ ឆ្លុះបញ្ចាំងឱ្យឃើញពីគុណវិបត្តិក្នុងការកសាងសមត្ថភាពនៃស្ថាប័នផ្សេងៗ (ក្រសួងផែនការ, ភ្នាក់ងារនិងក្រសួងផ្សេងៗរបស់រដ្ឋាភិបាល និងដៃគូអភិវឌ្ឍន៍ក្រៅប្រទេស) និងបញ្ហាទំនាក់ទំនងរវាងស្ថាប័នទាំងនេះ។ បញ្ហាសមត្ថភាពស្ថាប័នទាំងនេះ ខ្លះពាក់ព័ន្ធទៅនឹងបញ្ហាមុខមាត់រវាងស្ថាប័នរដ្ឋាភិបាលជាធំ ខ្លះពាក់ព័ន្ធទៅនឹងឥរិយាបទនៃដៃគូអភិវឌ្ឍន៍ក្រៅប្រទេសហើយដៃគូអភិវឌ្ឍន៍ក្រៅប្រទេសខ្លះគឺសំខាន់សម្រាប់តែក្រសួងផែនការៈ

- កង្វះធនធានស្នូល កន្លងមកជាមួយហិរញ្ញវត្ថុមានកំណត់ពីថវិកាជាតិរដ្ឋាភិបាល ក្រសួងផែនការបានក្លាយទៅជាពឹងផ្អែកទុនទាំងស្រុង ពីដៃគូអភិវឌ្ឍន៍ក្រៅប្រទេស ដែលជាធម្មតាបានទទួលយកក្នុងរូបភាពនៃទំនាក់ទំនងទ្វេភាគីមិនបានសម្របសម្រួល និងគម្រោងដែលផ្អែកលើអ្នកផ្តល់ជំនួយតែម្នាក់។

ទាំងអស់នេះបានកំរិតការអភិវឌ្ឍសមត្ថភាពភាពជាម្ចាស់ និងការកសាងសមត្ថភាពស្ថាប័នរបស់ក្រសួងផែនការ ។

- ការធ្វើទំនាក់ទំនង និងសហប្រតិបត្តិការមិនបានល្អរវាង ក្រសួងផែនការ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងគណៈកម្មាធិការស្តារនិងអភិវឌ្ឍន៏កម្ពុជានៃក្រុមប្រឹក្សាអភិវឌ្ឍន៏កម្ពុជា ដែលជាលទ្ធផលនៃការទាក់ទងមិនបានល្អរវាង (១) យុទ្ធសាស្ត្រជាតិ, (២)ផែនការតាមវិស័យនិងថ្នាក់ក្រោមជាតិ (ការគ្រប់គ្រងជាធំលើវិស័យ, ផែនការប្រតិបត្តការប្រចាំឆ្នាំ ។ល។) (៣)ការគ្រប់គ្រងចំណាយសាធារណៈ ។
- នៅក្នុងក្រសួងផែនការ ទំនាក់ទំនងនិងការធ្វើសមាហរណកម្មរវាងអគ្គនាយកផែនការនិងវិទ្យាស្ថានជាតិស្ថិតិតែងតែមិនសូវជិតស្និតខ្លាំង ។ មួយផ្នែកដោយសារផ្នែកទាំងពីរនៃក្រសួងផែនការត្រូវបានគាំទ្រដោយគម្រោងផ្សេងៗ ដែលហិរញ្ញប្រទានដោយអ្នកផ្តល់ជំនួយខុសៗគ្នា ដូច្នេះការសម្របសម្រួលមិនសូវមានប្រសិទ្ធភាពជាងអ្វីដែលបានគិត ។
- ជារឿយៗតែងតែខ្វះខាតការទំនាក់ទំនង ការសម្របសម្រួលឬការផ្សាភ្ជាប់រវាងដៃគូអភិវឌ្ឍន៏ក្រៅប្រទេសចំពោះការគាំទ្រអ្វីដែលខ្លួនត្រូវផ្តល់ទៅក្រសួងផែនការ និងតើគេត្រូវផ្តល់ឱ្យក្រសួងផែនការរបៀបណា ។ សព្វថ្ងៃការងាររបស់ក្រសួងផែនការស្ទើរតែទាំងអស់មានការងារផែនការ និងការកាត់បន្ថយភាពក្រីក្រ (ក៏ដូចជាការងារប្រមូលទិន្នន័យស្ថិតិ និងការអភិវឌ្ឍសមត្ថភាពស្ថិតិ) ត្រូវបានធ្វើឡើងដោយមានការគាំទ្រពីអ្នកផ្តល់ជំនួយ (ដូចជាការផ្តល់ទុន និងជំនាញការអន្តរជាតិ )។ ដំណោះស្រាយមួយចំណែកម្តងៗ ដូចនេះតែងតែផ្តល់លទ្ធផលឱ្យអ្នកផ្តល់ជំនួយនាំមុខក្នុងការងាររបស់ក្រសួងផែនការ និងតែងតែខំប្រឹងប្រគួតប្រណាំងនឹងសេចក្តីត្រូវការលើធនធានមនុស្សដែលមានកំរិត ។ ដោយប្រើប្រាស់ដំណោះស្រាយតាមគម្រោងមួយ និងអង្គភាពអនុវត្តគម្រោងក្នុងការគាំទ្រអង្គភាពដោយឡែកមួយរបស់ក្រសួងផែនការ សម្រាប់ការសម្រេចអ្វីមួយដែលចាត់ទុកថាមានសារៈសំខាន់ទាំងចំពោះខ្លឹមសារ ពេលវេលា វិធីសាស្ត្រ និងដំណោះស្រាយនៃសកម្មភាព[៥] ដៃគូអភិវឌ្ឍន៏ក្រៅប្រទេសបានបង្ការការធ្វើសមាហរណកម្មបណ្តោយនៃមុខងាររបស់ក្រសួងផែនការ និងបានបន្ថយការអភិវឌ្ឍរយៈពេលយូរអង្វែងភាពជាម្ចាស់របស់រដ្ឋាភិបាល និងយុទ្ធសាស្ត្រចក្ខុវិស័យ

[៥] ឧទាហរណ៏ដែលមានការចាប់អារមណ៏ខ្លាំងមួយនៃបញ្ហានេះ បានកើតមានឡើងនៅពេលដែលដៃគូពីរគាំទ្រក្រសួងផែនការស្របគ្នាក្នុង ការរៀបចំផែនការរយៈពេលមធ្យម (ផែនការអភិវឌ្ឍន៏សេដ្ឋកិច្ច-សង្គមកិច្ចលើកទី២ និងយុទ្ធសាស្ត្រជាតិកាត់បន្ថយភាពក្រីក្រ) សូមអាន វេទិកាអង្គការក្រៅរដ្ឋាភិបាល ការវាយតំលៃភ្លាមៗពីដំណើរការនៃ *យជកក* នៅកម្ពុជា : ធានាគារពីរ ដំណើរការពីរ ឯកសារពីរ ភ្នំពេញ ខែកញ្ញា ឆ្នាំ២០០១) (http:www.ngoforum.or.kh/Development/Docs/PRSP/default.htm) ។ ផែនការមេស្ថិតិក៏បានបញ្ចូលក្នុង ឯកសារ យោងដែរ ដើម្បីបង្ហាញជាឧទាហរណ៏នៃវិធីសាស្ត្រមិនសហការរបស់ដៃគូអភិវឌ្ឍន៏ក្រៅប្រទេស ក្នុងកិច្ចអភិវឌ្ឍស្ថិតិក្នុងពេលកន្លងទៅ ។

របស់ក្រសួងផែនការ ។ ដោយធ្វើរបៀបនេះ បានជួយធ្វើឱ្យថយក្រោយការអភិវឌ្ឍសមត្ថភាពក្រសួងផែនការ ។

- មន្ត្រីនៃក្រសួងផែនការបានពឹងផ្អែកយ៉ាងខ្លាំងលើប្រាក់ឧបត្ថមពីដៃគូអភិវឌ្ឍន៍ក្រៅប្រទេស សម្រាប់ឱ្យមានប្រាក់កម្រៃគ្រប់គ្រាន់ ។ នេះបង្កើតឱ្យមានការលើកទឹកចិត្ត ដើម្បីធ្វើការងារសម្រាប់ផលប្រយោជន៍គម្រោងរបស់ដៃគូអភិវឌ្ឍន៍ ជាជាងសម្រាប់ពង្រីកចក្ខុវិស័យនៃការផ្លាស់ប្តូរយុទ្ធសាស្ត្រ (របស់ក្រសួងផែនការ ឬរាជរដ្ឋាភិបាល) ។
- មន្ត្រីក្រសួងផែនការខ្វះសមត្ថភាពក្នុងការវិភាគគោលនយោបាយនិងវិភាគភាពក្រីក្រ និងមុខងារបច្ចេកទេសផ្សេងទៀត ។ ជាថ្មីម្តងទៀត នេះបង្ហាញទាំងធនធានស្នួល របស់រាជរដ្ឋាភិបាលមិនបានអភិវឌ្ឍន៍ និងកង្វះយុទ្ធសាស្ត្រគ្រប់គ្រងធនធានមនុស្សក្នុងមន្ត្រីរាជការស៊ីវិល ប៉ុន្តែក៏ឆ្លុះបញ្ចាំងដែរពីការដែលមិនបានសម្របសម្រួលគ្នា ភាពដាច់មុខ និងដំណោះស្រាយនាំមុខដោយអ្នកផ្តល់ជំនួយទៅនឹងការបណ្តុះបណ្តាលដែលនាំមុខភាគច្រើនដោយការគាំទ្រពីដៃគូអភិវឌ្ឍន៍ក្រៅប្រទេសក្នុងពេលកន្លងមក ។

## ៤.២ មេរៀននិងបទពិសោធន៍ដែលបានដកស្រង់សម្រាប់អនាគត

ផ្អែកលើបទពិសោធន៍នេះ ក្រសួងផែនការបានដកស្រង់នូវមេរៀនជាច្រើនសម្រាប់ការវិវត្តទៅអនាគតនៃប្រព័ន្ធផែនការកម្ពុជា និងតួនាទីរបស់ខ្លួនជាអ្នកសម្របសម្រួលក្នុងប្រព័ន្ធផែនការនោះ ។ ដើម្បីធ្វើឱ្យបានល្អប្រសើរជាងពេលកន្លងមក ការផ្តល់និងសេចក្តីត្រូវការចាំបាច់ទាំងនេះ ត្រូវតែដាក់ទៅក្នុងការអនុវត្តឱ្យមានប្រសិទ្ធភាព ដោយតួអង្គពាក់ព័ន្ធទាំងអស់ ។

១. ក្រសួងផែនការ ត្រូវផ្តោតលើអាទិភាពចំពោះធនធានរបស់ខ្លួនដែលមានកម្រិត ។ *ផយផក* មានទិសដៅជួយតម្រង់ទិសការងាររបស់ក្រសួងផែនការ ក្នុងផ្លូវជាយុទ្ធសាស្ត្រមួយ ។

២. បន្ថយការពឹងផ្អែកប្រាក់ខែឧបត្ថម្ភលើដៃគូអភិវឌ្ឍន៍ក្រៅប្រទេស (និងចៀសវាងការលើកទឹកចិត្តខុសពីភាពដើមដែលបង្កើតឡើង) ។ កម្មវិធីកំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និងការកែទម្រង់រដ្ឋបាលសាធារណៈនិងមន្ត្រីរាជការស៊ីវិល ចាំបាច់ត្រូវតែអនុវត្តធ្វើយ៉ាងណាឱ្យមន្ត្រីផែនការមានប្រាក់កំរៃគ្រប់គ្រាន់ ។

៣. មានសេចក្តីត្រូវការជាប្រចាំមួយ សម្រាប់ធ្វើឱ្យមានកិច្ចសហការគ្នាជិតស្និទរវាង អគ្គនាយកដ្ឋានផែនការ និងវិទ្យាស្ថានជាតិស្ថិតិ ដើម្បីធានាថាអង្គភាពទាំងពីរនេះ បំពេញឱ្យគ្នាទៅវិញទៅមកប្រកបដោយប្រសិទ្ធភាព ។ ការសហការគ្នាជិតស្និទនេះ គឺជាតម្រូវការចាំបាច់ ដើម្បីធានាថាការងារស្ថិតិរបស់វិទ្យាស្ថានជាតិស្ថិតិ ផ្តល់នូវទិន្នន័យត្រូវការសម្រាប់ត្រួតពិនិត្យ និងវាយតម្លៃ

វឌ្ឍនភាពឆ្ពោះទៅរកគោលដៅនិងចំណុចដៅរបស់ *ផយអជ* ដោយប្រើប្រាស់សូចនាករដែលបានកំណត់នៅក្នុង *ផយអជ* ។

៤. មានសេចក្តីត្រូវការដែរឱ្យមានកិច្ចសហការគ្នាជិតស្និទរវាង អគ្គនាយកដ្ឋានផែនការនិងតួសំខាន់ផ្សេងទៀត (ដូចជាក្រសួងពាក់ពន្ធ័ ថ្នាក់ក្រោមជាតិ និងដៃគូអភិវឌ្ឍន៍ក្រៅប្រទេស) ដើម្បីធានាការ វត្ត និងតាមដានត្រួតពិនិត្យ *ផយអជ* ។

៥. ពាក់ពន្ធ័នឹងវិទ្យាស្ថានជាតិស្ថិតិ មានតម្រូវការមួយ (ដូចបានបញ្ជាក់នៅក្នុងផែនការមេស្ថិតិ) សម្រាប់ការធ្វើឱ្យប្រសើរឡើង ការសម្របសម្រួលស្ថិតិរវាងវិទ្យាស្ថានជាតិស្ថិតិ ធនាគារជាតិកម្ពុជា និងក្រសួងពាក់ពន្ធ័ ។ លើកទឹកចិត្តធនាគារជាតិកម្ពុជា និងក្រសួងពាក់ពន្ធ័ ឱ្យប្រើប្រាស់សមត្ថភាពរបស់វិទ្យាស្ថានជាតិស្ថិតិ ចុះទៅមូលដ្ឋានសម្រាប់ការអង្កេតរបស់អង្គភាពទាំងនោះ ធ្វើដូចនេះ សមត្ថភាពរបស់វិទ្យាស្ថានជាតិស្ថិតិនឹងត្រូវពង្រឹង ហើយប្រសិទ្ធភាពនៃសកម្មភាពស្ថិតិរបស់រាជាណាចក្រកម្ពុជានឹងបានកែលម្អក្នុងពេលជាមួយគ្នា (បញ្ហាប្រឈមនេះបានរំលេចរួចហើយនៅក្នុងសេចក្តីប្រកាសនៃច្បាប់ស្ថិតិថ្មី) ។

៦. កិច្ចសហប្រតិបត្តការ និងការសម្របសម្រួលរវាង ដៃគូអភិវឌ្ឍន៍ក្រៅប្រទេសត្រូវការកែលម្អជាបន្ទាន់ ។ ក្នុងពេលកន្លងមក កង្វះខាតកិច្ចសហប្រតិបត្តការខ្លះរបស់អ្នកផ្តល់ជំនួយគឺជាកត្តាសំខាន់មួយដែលនាំទៅរកការលេចឡើង ឬធ្វើឱ្យក្រសួងផែនការមានបញ្ហាជាច្រើន ។ យ៉ាងហោចណាស់ក៏មានតម្រូវការមួយ សម្រាប់ការផ្លាស់ប្តូរពត៌មានដ៏មានប្រសិទ្ធភាព ដើម្បីចៀសវាងការជាន់គ្នា ឬក៏បុកគ្នារវាងការគាំទ្រដោយភាគីខុសៗគ្នា។ ក្នុងស្មារតីនៃភាពជាដៃគូដ៏ស្មោះត្រង់ ដៃគូអភិវឌ្ឍន៍ក្រៅប្រទេស មានបំណងជួយគាំទ្រដល់ក្រសួងផែនការមិនថាអគ្គនាយកដ្ឋានផែនការ ឬវិទ្យាស្ថានជាតិស្ថិតិ ឬក៏ទាំងពីរត្រូវការដើម្បីចូលរួមក្នុងវេទិការរួមគ្នា (ពិសេសក្រុមការងារបច្ចេកទេសផែនការនិងការកាត់បន្ថយភាពក្រីក្រ) នៅពេលមានការលើកជាសំណើគម្រោងឬការពិនិត្យឡើងវិញការគាំទ្រទៅក្រសួងផែនការ ។ ក្រសួងផែនការត្រូវតែអាចធ្វើបាន ដើម្បីជួយឱ្យការស្នើឡើង ឬការពិនិត្យឡើងវិញ ត្រូវបានបង្ហាញនៅក្នុងក្រុមការងារបច្ចេកទេស ។ សេចក្តីប្រាថ្នាដ៏ខ្លាំងគឺគ្រប់ ដៃគូអភិវឌ្ឍន៍ក្រៅប្រទេសទាំងអស់ដែលកំពុងធ្វើការជាមួយក្រសួងផែនការត្រូវការធ្វើការជាមួយក្រសួងដើម្បីឯកភាពផ្តល់ជំនួយបច្ចេកទេសនិងហិរញ្ញវត្ថុទៅលើផែនការមួយរបស់ក្រសួងផែនការ ដែលមានលក្ខណៈទូលំទូលាយ ហើយដែលបានរំលេចអាទិភាពទាំងឡាយនៅក្នុងផែនការយុទ្ធសាស្ត្ររបស់ក្រសួងផែនការ ចំណែកអាទិភាពលម្អិតមាននៅក្នុងឯកសារគាំទ្រ (ឧ.ផែនការ មេស្ថិតិ *ផយអជ* ។ល។) នៅពេលតម្លៃនៃផែនការសកម្មភាពនេះត្រូវបាន រៀបចំដៃគូអភិវឌ្ឍន៍ក្រៅប្រទេសនឹងសម្របសម្រួល ដើម្បីបន្សុីការគាំទ្ររបស់ខ្លួន ធ្វើយ៉ាងណាដើម្បី

បំពេញគំលាតក្នុងកន្លែងអាទិភាព ។ កន្លងមកនិងស្របជាមួយការប្តេជ្ញាចិត្ត ដែលបានធ្វើនៅក្រោមកម្មវិធី សុខដុមនីយកម្ម និងបន្សុី ដៃគូអភិវឌ្ឍន៍ក្រៅប្រទេស ត្រូវធ្វើអន្តរកម្មពីភាពឯករាជ្យនៃអង្គភាពអនុវត្តគម្រោង ទៅជាតាមរយៈគម្រោងដែលមានអ្នកផ្តល់ជំនួយច្រើន ឬការរៀបចំកិច្ចសហប្រតិបត្តការដើម្បីដាក់ទុនរួមជាមួយគ្នា ។

៧. ការអភិវឌ្ឍសមត្ថភាពវិភាគគោលនយោបាយក្នុងក្រសួងផែនការ (ពិសេសអគ្គនាយកដ្ឋានផែនការ) ក៏មានសារៈសំខាន់ដូចការអភិវឌ្ឍទិន្នន័យស្ថិតិមូលដ្ឋានដែរ ។ សមត្ថភាពវិភាគគោលនយោបាយគឺមានសារៈសំខាន់សម្រាប់មន្ត្រីក្រសួងផែនការ ដើម្បីវិភាគទិន្នន័យ រាយការណ៍ពីការអនុវត្ត *ផយអជ* និងរៀបចំផ្តល់អនុសាសន៍លើគោលនយោបាយពាក់ពន្ធ័ ។ ក្របខ័ណ្ឌអភិវឌ្ឍន៍សមត្ថភាពមួយត្រូវតែរៀបចំឡើង ដោយផ្អែកលើសេចក្តីត្រូវការរបស់ក្រសួងផែនការ (ឧ. ជាមួយការបណ្តុះបណ្តាលដែលកំពុងត្រូវការ និងមិនមែនជាការផ្គត់ផ្គង់នាំមុខទេ) ។ សកម្មភាពបណ្តុះបណ្តាលត្រូវតែជាប្រពន្ធ័ និងតាមក្របខណ្ឌការងារ ជាជាងការផ្តល់ឱ្យជារបៀបមួយចំណែកម្តងៗ ។ ការបណ្តុះបណ្តាលក្នុងការងារឃើញថាជារបៀបដ៏ល្អប្រសើរក្នុងការផ្តល់ការបណ្តុះបណ្តាល ។

៨. ការពឹងផ្អែកលើហិរញ្ញប្រទានរបស់អ្នកផ្តល់ជំនួយ គឺមិនមែនជាយុទ្ធសាស្ត្រសមស្របទេ សម្រាប់អភិវឌ្ឍន៍សមត្ថភាពស្ថាប័នស្ថិតិស្ទួល និងយុទ្ធសាស្ត្រជាតិ ។ ការងារក្រសួងផែនការ (និងរបស់រាជរដ្ឋាភិបាលជាទូទៅ) មិនគួរណាត្រូវនាំមុខដោយទុនដែលអាចរកបានសម្រាប់សកម្មភាពដោយឡែក ប៉ុន្តែគួរផ្តោតលើអាទិភាពជាយុទ្ធសាស្ត្ររបស់ក្រសួងផែនការ (និងរបស់រាជរដ្ឋាភិបាល) ។ ការងាររបស់ក្រសួងផែនការ (និងរបស់រាជរដ្ឋាភិបាលជាទូទៅ) ត្រូវការរំលេចពីអាទិភាពរបស់ប្រទេស និងមិនមែនរំលេចពីអាទិភាពរបស់ដៃគូអភិវឌ្ឍន៍ក្រៅប្រទេសទេ ។ សេចក្តីត្រូវការនេះសម្រាប់ភាពជាដៃគូពិត បាននាំមុខដោយរដ្ឋាភិបាលគឺជាការត្រឹមត្រូវ សម្រាប់ចំណេះដឹង និងផែនការពេលវេលារបាយការណ៍ ការអង្កេត ឬជំរឿន ។ ដៃគូអភិវឌ្ឍន៍ក្រៅប្រទេសគួរធ្វើសុខដុមនីយកម្ម និងបន្សុីការគាំទ្ររបស់ខ្លួនទៅនឹងអាទិភាពរបស់ក្រសួងផែនការ (រាជរដ្ឋាភិបាល) ហើយរៀបចំនិងឯកភាពលើដំណោះស្រាយរួមមួយ ដើម្បីជួយគាំទ្រដល់ក្រសួងផែនការ ជាជាងធ្វើតាមការគ្រប់គ្រង ឬកម្មវិធីរបស់ស្ថាបន័ផ្ទាល់ខ្លួន ។ ទាំងនេះនឹងជួយ ចៀសវាងដល់សកម្មភាពត្រួតគ្នា ឬជាន់លើគ្នា ដែលតែងតែកើតមានឡើងក្នុងពេលកន្លងមក ។

## ៤.៣ វឌ្ឍនភាពទទួលបានកន្លងមកក្នុង *ផយអជ*

ឯកសារ *ផយអជ* ខ្លួនឯងបានរំលេចនិងបញ្ចូលមេរៀនមួយចំនួនដែលបានកំណត់ខាងលើ ។ គួរកត់សម្គាល់ថា *ផយអជ* គឺជាផែនការទី ១ ដែលផ្តល់:

- ការគ្រប់គ្រងដែលមានការផ្តោតការយកចិត្តទុកដាក់ (រួមមានអាទិភាពច្បាស់លាស់និងសកម្មភាពជាក់ លាក់) ។
- ក្របខណ្ឌតាមដានត្រួតពិនិត្យមួយ (ដែលរួមមានសូចនាករជាក់លាក់) ដែលនឹងប្រើប្រាស់សម្រាប់តាមដានបន្ត ហើយបើសិនចាំបាច់ត្រូវធ្វើការត្រួតពិនិត្យជារៀងរាល់ឆ្នាំ (ឧ. នៅក្នុងក្របខណ្ឌនៃការរៀបចំរបាយការណ៍ប្រចាំឆ្នាំស្តីពីវឌ្ឍនភាពនៃការអនុវត្ត *ផយអជ*) ។
- មានការកំណត់ពេលវេលាច្បាស់លាស់ ។
- មានការបង្ហាញច្បាស់លាស់ស្តីអំពីធនធានដែលត្រូវការ ។

ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិក៏រួមបញ្ចូលផងដែរនូវ :

- ភាពចាំបាច់ដើម្បីធ្វើសុខដុមនីយកម្មនៃកម្មវិធីវិនិយោគសាធារណៈនិងដំណើរការថវិកាឱ្យស្របជាមួយ *ផយអជ* ។
- ភាពចាំបាច់ដើម្បីអនុវត្ត *ផយអជ* (ដែលបានតាមដាននៅក្នុងក្របខណ្ឌនៃការរៀបចំរបាយការណ៍ប្រចាំឆ្នាំ ស្តីពីវឌ្ឍនភាពរបស់ *ផយអជ* ។
- ភាពចាំបាច់ដើម្បីធ្វើឱ្យប្រសើរឡើងកិច្ចសហប្រតិបត្តការ និងការធ្វើទំនាក់ទំនង រវាងក្រសួងផែនការ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា/ក្រុមប្រឹក្សាស្តារនិងអភិវឌ្ឍន៍កម្ពុជាក៏ដូចជារវាងរដ្ឋាភិបាល និងដៃគូអភិវឌ្ឍន៍ក្រៅប្រទេស
- ការប្តេជ្ញាចិត្តអនុវត្ត *ផយអជ* ដោយឥតគិតអំពីអាទិភាពផ្សេងៗទៀត នៅក្នុងគោលនយោបាយក្នុងប្រទេស ឬអន្តរជាតិ ។

ម្យ៉ាងទៀត ឯកសារ *ផយអជ* បានបង្ហាញផងដែរថា មានតម្រូវការទៅអនាគតឱ្យមានការរៀបចំការអនុវត្តល្អិតល្អន់ *ផយអជ* លើកទី ១។ ផែនការយុទ្ធសាស្ត្ររបស់ក្រសួងផែនការ មានបំណងផ្តល់វិភាគទានដ៏សំខាន់មួយទៅនឹងដំណើរការដែលកំពុងប្រព្រឹត្តទៅ។ ជាពិសេស *ផយផក* មានបំណងក្លាយទៅជាក្របខណ្ឌការងារមួយ ដែលនៅក្នុងនោះសមត្ថភាពស្ថាប័នផែនការអាចត្រូវបានពង្រឹងក្នុងផ្លូវមួយដែលក្រសួងផែនការអាចអភិវឌ្ឍន៍ដើម្បីការពារភាពដឹកនាំរបស់រដ្ឋាភិបាល នៅក្នុងដំណោះស្រាយដែលផ្អែកលើភាពជាអ្នកដឹកនាំពិតប្រាកដដើម្បីផែនការ ការកាត់បន្ថយភាពក្រីក្រ និងការបង្កើតស្ថិតិផ្លូវការ ។

# ជំពូកទី៥

# ទិសដៅ និងសកម្មភាព

ផែនការយុទ្ធសាស្ត្ររបស់ក្រសួងផែនការ ( *ផយផក*) នេះបានដាក់ចេញនូវផែនការអាទិភាពរយៈពេលមធ្យមសម្រាប់ការងារកម្ពុជា ក្នុងការរៀបចំផែនការ ការកាត់បន្ថយភាពក្រីក្រ និងស្ថិតិ ។ ផ្អែកលើគោលនយោបាយ និងយុទ្ធសាស្ត្រដែលបានរៀបរាប់ខាងលើ យើងសាកល្បងធ្វើសំយោគនិងកំណត់អាទិភាពកិច្ចការទាំងអស់នេះ ទៅក្នុងទិសដៅ ចំណុចដៅ និងសកម្មភាពជាក់លាក់។

អាទិភាពខ្ពស់បំផុតរបស់ក្រសួងផែនការមានពីរគឺ:

១. សម្រាប់អគ្គនាយកដ្ឋានផែនការ អាទិភាពខ្ពស់បំផុតគឺ**ការអនុវត្តផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ**។

២. សម្រាប់វិទ្យាស្ថានជាតិស្ថិតិ (យោងតាមផែនការមេស្ថិតិ) អាទិភាពខ្ពស់បំផុតគឺរក្សាស្ថិតិសេដ្ឋកិច្ច-សង្គមកិច្ច និងប្រជាសាស្ត្រដែលមានស្រាប់ និងធ្វើឱ្យប្រសើរឡើងគុណភាព និងភាពទៀតទាត់ពេលវេលារបស់វា ។

ទិសដៅស្នូលនៃ *ផយផក* គឺជាម៉ាទ្រីសដែលភ្ជាប់នៅឧបសម្ព័ន្ធទី១ ។ ម៉ាទ្រីសនេះរួមមានទិសដៅ ចំណុចដៅ និងសកម្មភាពសម្រាប់ឆ្នាំថ្មីនិមួយៗ ។ ម៉ាទ្រីសបានបង្ហាញអំពីក្របខណ្ឌពេលវេលាជាបន្តបន្ទាប់ ភាពជាដៃគូនិងការប៉ាន់ស្មានថវិកាផងដែរ ។

***ជាសង្ខេប ម៉ាទ្រីសមានទិសដៅ ៨ និងចំណុចដៅ ១៩ ព្រមទាំងសកម្មភាពសំខាន់ៗជាង ៦០*** ។ លក្ខណៈ សំខាន់ៗនៃម៉ាទ្រីសនោះគឺ :

**១. ដើម្បីធានាការអនុវត្ត *ផយអជ* និងវឌ្ឍនភាពឆ្ពោះទៅរក *គអសក*** គឺជាទិសដៅទី១របស់ក្រសួងផែនការ។ ចំណុច ដៅទាំង៥ ដែលទាក់ទងនឹងទិសដៅនេះមានដូចតទៅ :

- ការផ្សព្វផ្សាយ *ផយអជ* និងការអភិវឌ្ឍពត៌មាន និងធនធានទំនាក់ទំនងរបស់ក្រសួងផែនការ ។
- ការធ្វើសុខដុមនីយកម្មជាបន្តបន្ទាប់នៃយុទ្ធសាស្ត្រតាមវិស័យផែនការនៅថ្នាក់ក្រោមជាតិនិងផែនការ និងគោលនយោបាយអន្តរវិស័យជាមួយអាទិភាព *ផយអជ* ។
- ការសម្រេចឱ្យបានល្អប្រសើរជាបន្តបន្ទាប់ ភាពស៊ីសង្វាក់គ្នានៃដំណើរការវិភាជន៍ធនធាននិងលទ្ធផល (វិដ្ឋថវិកា ក្របខណ្ឌចំណាយរយៈពេលមធ្យម *កវស* និង ជំនួយអភិវឌ្ឍន៍ក្រៅប្រទេស ) ឱ្យស្របជាមួយអាទិភាព *ផយអជ* ។
- កំណត់តំបន់ក្រីក្រ និងគ្រួសារក្រីក្រ ដើម្បីធានាថាធនធានដែលបានបំរុង សម្រាប់កាត់បន្ថយភាពក្រីក្រដោយផ្ទាល់ ត្រូវបានបែងចែកដោយមានប្រសិទ្ធភាពខ្ពស់និងផ្តល់ផលល្អ ។

- ការអភិវឌ្ឍសមត្ថភាពរបស់មន្ត្រីក្រសួងផែនការ ដើម្បីកំណត់អាទិភាព និងបញ្ជ្រាបបញ្ហាយេនឌ័រទៅក្នុងផែនការ និងសមធម៌យេនឌ័រក្នុងការអនុវត្ត *ផយអជ* ។

*សកម្មភាពជាបន្តបន្ទាប់ដែលត្រូវការដើម្បីធ្វើឱ្យសម្រេចទិសដៅនិងចំណុចដៅមានដូចខាងក្រោម:*

- អភិវឌ្ឍនិងអនុវត្តការផ្សព្វផ្សាយ *ផយអជ* និងយុទ្ធសាស្ត្រទំនាក់ទំនង ។
- អភិវឌ្ឍ និងថែរក្សាគេហទំព័ររបស់ក្រសួងផែនការ/ *ផយអជ* គេហទំព័រ ។
- សហការជាមួយក្រសួង និងស្ថាប័នពាក់ព័ន្ធនានា ដើម្បីធ្វើសេចក្តីព្រាងយុទ្ធសាស្ត្រតាមវិស័យថ្មី ឬបន្សុីយុទ្ធសាស្ត្រតាមវិស័យដែលមានស្រាប់ឱ្យស្របជាមួយអាទិភាពរបស់ *ផយអជ* ។
- សហការជាមួយអាជ្ញាធរថ្នាក់ក្រោមជាតិ ដើម្បីបន្សុីដំណើរការផែនការ និងផែនការទាំងឡាយ (ក្នុងនោះមាន ទិសដៅ ចំណុចដៅ អាទិភាព សកម្មភាព ធនធាន) ឱ្យស្របជាមួយ *គអសក* និង *ផយអជ* ការទំនាក់ទំនងទាំងនេះត្រូវធ្វើតាមរយៈការវិភាគស្ថានភាពនៅថ្នាក់ខេត្ត ការកំណត់អាទិភាព ការតំណត់តម្លៃ ការផ្គត់ផ្គង់ទិន្នន័យតាមដានសមស្រប ។ល។
- ពង្រឹងភាពជាអ្នកដឹកនាំ និងភាពជាដៃគូរបស់ក្រសួងផែនការជាមួយភាគីពាក់ពន្ធ័ ដើម្បីអនុវត្តផែនការវិនិយោគអាហារូបត្ថម្ភកម្ពុជា ។
- កំណត់តួនាទី និងការទទួលខុសត្រូវដើម្បីរៀបចំផែនការវិនិយោគអាហារូបត្ថម្ភកម្ពុជា (២០០៨-២០១២) ។
- កសាងទំនាក់ទំនងជិតស្និទជាមួយកម្មវិធីកំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ។
- ផ្តល់បទបង្ហាញដល់គណៈកម្មាធិការរដ្ឋសភា ស្តីអំពីសំណើសម្រាប់ការផ្សារភ្ជាប់រវាង ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និង *ផយអជ* ។
- ប្រើប្រាស់ការរៀបចំ *កវស* ដើម្បីបន្សុី *កវស* របស់ក្រសួង និង អាទិភាពរបស់ *ផយអជ* ។
- សហការជាមួយក្រសួងហិរញ្ញវត្ថុ ធ្វើយ៉ាងណាដើម្បីកំណត់ពេលវេលាចាប់ផ្តើមសុខដុមនីយកម្មសំរាប់ការបញ្ជូនថវិកា និង *កវស/ក្របខណ្ឌចំណាយរយៈពេលមធ្យម* ។
- ធានាថាការប្តេជ្ញាចិត្តធ្វើឱ្យមានការផ្សារភ្ជាប់រវាង *ផយអជ-កវស* ត្រូវបានឆ្លុះបញ្ចាំងក្នុងការបែងចែកថវិកា ។
- បង្កើតលក្ខណៈវិនិច្ឆ័យសំរាប់ការធ្វើសុខដុមនីយកម្ម និងកំណត់បទដ្ឋាន និងនីតិវិធីសម្រាប់កំណត់អត្តសញ្ញាណគ្រួសារក្រីក្រ តាមបណ្តាខេត្តដែលមានគំរោងសាកល្បង ។
- បន្ទាប់មកទៀតពង្រីកការគ្របដណ្តប់នូវកម្មវិធីសម្រាប់ការកំណត់អត្តសញ្ញាណគ្រួសារក្រីក្រ ។
- ជំរុញការអភិវឌ្ឍកម្មវិធីផ្តល់សេវាសង្គមដល់គ្រួសារក្រីក្រដែលបានកំណត់ ។
- អភិវឌ្ឍស្ថាប័ន និងដំណើរការនានាសម្រាប់កំណត់គោលដៅតាមភូមិសាស្ត្រ ។
- ជំរុញការបញ្ជ្រាបយេនឌ័រនៅក្នុងប្រព័ន្ធផែនការ ។

- អភិវឌ្ឍសមត្ថភាពដើម្បីបញ្ជ្រាបយេនឌ័រនៅក្នុងប្រព័ន្ធផែនការ ដោយធ្វើការបណ្តុះបណ្តាលជាបន្ត បន្ទាប់ពីកម្រិតជាតិទៅកំរិតវិមជ្ឈការ ។
- រៀបចំ និងអនុវត្តផែនការសកម្មភាពបញ្ជ្រាបយេនឌ័រ ។

**២. តាមដាន និងវាយតំលៃពីវឌ្ឍនភាពឆ្ពោះទៅរកការអនុវត្ត *ផយអជ* និងលទ្ធផលនៃ *ផយអជ/គអសក***

គឺជាទិសដៅទី២នៃ *ផយផក* ។ មានចំណុចដៅសំខាន់ចំនួន៣នៅក្រោមទិសដៅនេះ :

- ប្រមូល វិភាគ និងរាយការណ៍ពីពត៌មានស្តីពីការអនុវត្ត *ផយអជ* និងលទ្ធផលនៃ *ផយអជ/ គអសក*
- រៀបចំរបាយការណ៍ចាំបាច់ ដែលត្រូវការសម្រាប់ដំណើរការត្រួតពិនិត្យជាអន្តរជាតិ ដោយផ្អែកលើទិន្នន័យត្រួតពិនិត្យ *ផយអជ* និងអំពីទម្រង់របាយការណ៍ និង
- កសាងសមត្ថភាពបុគ្គលិកក្រសួងផែនការ ដើម្បីធានាការអនុវត្តនិងតាមដានត្រួតពិនិត្យ *ផយអជ* ប្រកប ដោយប្រសិទ្ធភាពខ្ពស់ ។

*ដើម្បីសម្រេចទិសដៅ និងចំណុចដៅខាងលើ បានទាមទារនូវសកម្មភាពដូចខាងក្រោមនេះ :*

- ធ្វើឱ្យប្រសើរឡើង និងអនុវត្តក្របខណ្ឌតាមដានត្រួតពិនិត្យ *ផយអជ* ដោយសហការជាមួយវិទ្យាស្ថានជាតិស្ថិតិនិងក្រសួង/ស្ថាប័នពាក់ព័ន្ធ ( ធ្វើការជាមួយក្រុមការងារបច្ចេកទេសដែលទទួលខុសត្រូវរៀងៗ ខ្លួន) ។
- ដឹកនាំការវាយតំលៃ *ផយអជ/គអសក* និងវិភាគគោលនយោបាយ ។
- បញ្ចូលការតាមដានត្រួតពិនិត្យស្នូល និងការវាយតម្លៃ/វិភាគប្រចាំឆ្នាំ ដែលបានជ្រើសរើសក្នុងរបាយការណ៍វឌ្ឍនភាព *ផយអជ* ប្រចាំឆ្នាំ
- ពង្រឹងសមត្ថភាពរដ្ឋាភិបាលដើម្បីតាមដានវាយតំលៃ និងរាយការណ៍អំពីការអនុវត្ត និងលទ្ធផលរបស់ *ផយអជ* និងផែនការសកម្មភាពដទៃទៀត ។
- ធានាថា របាយការណ៍វឌ្ឍនភាពប្រចាំឆ្នាំនៃ *ផយអជ* អាចប្រើប្រាស់ជារបាយការណ៍សម្រាប់ប្រទេសដែលមានការអភិវឌ្ឍតិចតួចបំផុត (ការប្តេជ្ញាចិត្តរបស់រដ្ឋាភិបាល ក្រោមកិច្ចព្រមព្រៀងទីក្រុងប្រ៊ុសសែល) និងរបាយការណ៍ *គអស* ។
- ចូលរួមការងារវិភាគជាតិដទៃទៀតដែលធ្វើដោយភាគីមានចំណែកផ្សេងទៀត ( ឧ. របាយការណ៍ពីការអភិវឌ្ឍន៍មនុស្សកម្ពុជា
របាយការណ៍របស់ធនាគារពិភពលោកដាក់ជូនវេទិកាសហប្រតិបត្តការអភិវឌ្ឍន៍កម្ពុជា (CDCF)
របាយការណ៍ស្តីពីស្ថានភាពប្រជាជនលើពិភពលោក ។ល។ ) ។
- កែលំអសមត្ថភាពមន្ត្រីនៃក្រសួងផែនការក្នុងផ្នែកវិភាគម៉ាក្រូសេដ្ឋកិច្ច ភាពក្រីក្រ និងប្រធានបទផ្សេងៗទៀត (សហការជាមួយវិទ្យាស្ថានជាតិស្ថិតិ និងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ) ។

- រៀបចំបណ្តុះបណ្តាលអ្នកបណ្តុះបណ្តាលបន្តនៅកម្រិតជាតិស្តីពីការកំណត់អត្តសញ្ញាណគ្រួសារក្រីក្រ
- អភិវឌ្ឍសមត្ថភាពមន្ត្រីក្រសួងផែនការ ក្រសួងពាក់ព័ន្ធ និងមន្ត្រីតាមខេត្ត/ក្រុង (តាមរយៈការបណ្តុះបណ្តាល ។ល ។) ដើម្បីបន្សីយុទ្ធសាស្ត្រតាមវិស័យនិងផែនការថ្នាក់ក្រោមជាតិជាមួយ *ផយអជ*។
- ផ្តល់ការកសាងសមត្ថភាពដល់ប្រព័ន្ធធ្វើផែនការ ដែលមានទិសដៅកាត់បន្ថយភាពក្រីក្រនៅថ្នាក់ខេត្ត/ស្រុក (ឱ្យស្របតាម *ផយអជ*) ។

៣. **ដើម្បីធានាថាក្រសួងផែនការនិងអ្នកពាក់ពន្ធ័របស់ខ្លួនអនុវត្តសកម្មភាពទាំងឡាយ ដែលបានទាមទារក្រោមរបៀបវារៈសុខដុមនីយកម្ម បន្សី និងលទ្ធផល** គឺជាទិសដៅទីពារបស់ក្រសួងផែនការ ។ ចំណុចដៅនេះគឺធានាថា ធនធានរបស់រដ្ឋាភិបាលនិងអ្នកផ្តល់ជំនួយ ដែលបានធ្វើវិភាជន៍ទៅឱ្យក្រសួងផែនការ ត្រូវស្របតាមអាទិភាពនៃ *ផយអជ* ។

*សកម្មភាពដែលត្រូវការដើម្បីសម្រេចទិសដៅ និងចំណុចដៅមានដូចតទៅ :*

បំពេញការប្តេជ្ញាចិត្តនៅក្រោមផែនការសកម្មភាពរបស់ក្រុមការងារបច្ចេកទេសសម្រាប់រៀបចំផែនការនិងកាត់បន្ថយ ភាពក្រីក្រ និងមុខងាររបស់ក្រសួងផែនការដែលបានកំណត់នៅក្នុងសេចក្តីប្រកាសស្តីពី សុខដុមណីយកម្ម បន្សី និងលទ្ធផល និងផែនការ សកម្មភាព ។

៤. **រៀបចំផែនការយុទ្ធសាស្ត្រអភិវឌ្ឍជាតិ ២០១១-២០១៥ ប្រកបដោយគុណភាពខ្ពស់ ទាន់ពេលវេលា** គឺជាទិសដៅទី៤ នៃផែនការយុទ្ធសាស្ត្ររបស់ក្រសួងផែនការ ។ វាមានចំណុចដៅ ចំនួន ២ គឺ :

- តម្រង់ទិសសកម្មភាពក្រសួងផែនការ ឆ្ពោះទៅរកមុខងារ *ផយអជ* ក្នុងអំឡុងពេលនៃការអនុវត្តផែនការយុទ្ធសាស្ត្ររបស់ក្រសួងផែនការ និង
- អនុមតិផែនការយុទ្ធសាស្ត្រអភិវឌ្ឍជាតិ ២០១១-២០១៥ នៅចុងឆ្នាំ២០១០ ។

*សកម្មភាពជាបន្តបន្ទាប់ទាំងឡាយដែលត្រូវអនុវត្តដើម្បីសំរេចទិសដៅ និងចំណុចដៅមាន :*

- ជាបន្តបន្ទាប់បន្សីសកម្មភាពរបស់ក្រសួងផែនការឱ្យបានច្បាស់លាស់ជាមួយមុខងាររបស់ *ផយអជ* ។
- ពង្រឹងកិច្ចសហប្រតិបត្តិការអន្តរជាតិនៅក្នុងក្រសួងផែនការ ។
- ធ្វើឱ្យប្រសើរឡើងការត្រួតពិនិត្យ *ផយផក* ប្រចាំឆ្នាំ និង
- កំណត់តួនាទី ការទទួលខុសត្រូវ កម្មវិធីនៃដំណើរការ ធនធាន (ធនធានមនុស្ស ការអភិវឌ្ឍសមត្ថភាពផ្សេងទៀតរបស់មន្ត្រីក្រសួងផែនការ ជំនួយបច្ចេកទេសត្រូវផ្តល់) ដែលត្រូវការ សម្រាប់ការរៀបចំផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិបន្ទាប់ទៀត ។ ធានាថារាល់ធនធានចាំបាច់ទាំងអស់នឹងកំណត់ឱ្យបានច្បាស់លាស់ជាមុន ដើម្បីធ្វើឱ្យការរៀបចំ *ផយអជ* ២០១១-២០១៥ ប្រព្រឹត្តទៅទាន់ពេលវេលា និងមានប្រសិទ្ធភាព ។

**៥. ពង្រឹងដំណើរការផែនការអភិវឌ្ឍន៍មូលដ្ឋាន គឺជាទិសដៅទី៥** នៃផែនការយុទ្ធសាស្ត្ររបស់ក្រសួងផែនការ ។ វាមានចំណុចដៅ ចំនួន៣ គឺ :

- ធ្វើឱ្យប្រសើរឡើងសមត្ថភាពនៃមន្ត្រីផែនការខេត្ត
- ធ្វើឱ្យប្រសើរឡើងសមត្ថភាពនៃមន្ត្រីផែនការស្រុក
- ពង្រឹងសមត្ថភាពនៃក្រុមការងារថ្នាក់ជាតិអំពីដំណើរការផែនការមូលដ្ឋាន

*សកម្មភាពដែលត្រូវការដើម្បីសម្រេចទិសដៅ និងចំណុចដៅមានដូចតទៅ :*

- ផ្តល់ការណែនាំស្តីពីដំណើរការផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ខេត្ត/ក្រុង
- អនុវត្តការគ្រប់គ្រងទិន្នន័យមូលដ្ឋានឃុំ/សង្កាត់
- រៀបចំនិងវិភាគស្ថានភាពឃុំ/សង្កាត់ និងស្ថានភាពខណ្ឌ/ស្រុក
- គាំទ្រការរៀបចំផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ឃុំ/សង្កាត់ និងកម្មវិធីវិនិយោគឃុំ/សង្កាត់
- គ្រប់គ្រងផែនការអភិវឌ្ឍន៍ទិន្នន័យមូលដ្ឋានឃុំ/សង្កាត់
- គាំទ្រនិងរៀបចំដំណើរការសិក្ខាសាលាសមាហរណកម្មស្រុក
- ត្រួតពិនិត្យនិងវាយតម្លៃការអនុវត្តដំណើរការផែនការខេត្ត និងដំណើរការផែនការឃុំ/សង្កាត់
- ផ្តល់ការណែនាំផែនការអភិវឌ្ឍន៍ឃុំ/សង្កាត់
- វិភាគស្ថានភាពឃុំ/សង្កាត់
- ចូលរួមនិងគាំទ្រដំណើរការផែនការឃុំ/សង្កាត់
- លើកកម្ពស់សមត្ថភាពក្រុមការងារជាតិស្តីពីទស្សនទាននៃការអនុវត្តល្អក្នុងដំណើរការផែនការមូលដ្ឋាន
- ធ្វើឱ្យប្រសើរឡើង និងគាំទ្រការរៀបចំនិងដំណើរការអនុវត្តផែនការនៅមូលដ្ឋាន
- សហការជាមួយភាគីពាក់ពន្ធ័ដើម្បីគាំទ្រគោលនយោបាយខេត្ត/ក្រុងនិងឃុំ/សង្កាត់ ជាមួយបរិបទវិមជ្ឈការ និងវិសហមជ្ឈការ ។

**៦. បង្កើតឱ្យមានការសម្របសម្រួលមួយនិងធ្វើឱ្យប្រសើរឡើងប្រពន្ធ័ស្ថិតិជាតិ**

គឺជាទិសដៅទី៦នៃផែនការយុទ្ធសាស្ត្រ របស់ក្រសួងផែនការទិសដៅនេះមានចំណុចដៅ២:

- ធ្វើឱ្យប្រសើរឡើងការគ្រប់គ្រងស្ថិតិ
- ធ្វើឱ្យប្រសើរឡើងការសម្របសម្រួលតាមរយៈប្រពន្ធ័ស្ថិតិជាតិ

*សកម្មភាពដែលត្រូវការដើម្បីសម្រេចទិសដៅ និងចំណុចដៅមានដូចតទៅ :*

- ក្របខណ្ឌច្បាប់ស្ថិតិត្រូវបានអនុម័ត និងមានលក្ខណៈយ៉ាងល្អិតល្អន់
- ក្រុមប្រឹក្សាស្ថិតិ និងគណៈកម្មាធិការសម្របសម្រួលស្ថិតិជួបប្រជុំក្នុងអំឡុង៦ខែ និង៣ខែម្តង ដើម្បីសម្របសម្រួលបទដ្ឋាន និងគោលការណ៍ច្បាប់នានា

## ៧. ធានាឱ្យបាននូវសេវាស្ថិតិជាតិទាន់ពេលវេលា ភាពអាចទាក់ទង និងការទទួលខុសត្រូវ

គឺជាទិសដៅទី៧ នៃផែនការយុទ្ធសាស្ត្ររបស់ក្រសួងផែនការ ហើយចំណុចដៅគឺដើម្បីធ្វើឱ្យកាន់តែប្រសើរនូវវិសាលភាព សេវាស្ថិតិរបស់វិទ្យាស្ថានជាតិស្ថិតិ និងការកំណត់និយមន័យដើម្បីបំពេញតម្រូវការក្នុងការរៀបចំរបាយការណ៍ថ្នាក់ជាតិ ។

*សកម្មភាពដែលត្រូវការដើម្បីសម្រេចទិសដៅ និងចំណុចដៅមានដូចតទៅ :*

- ទិន្នន័យជំរឿនឆ្នាំ ២០០៨ និងលទ្ធផលរបស់វានឹងត្រូវផ្សព្វផ្សាយយ៉ាងទូលំទូលាយ តាមរយៈប្រព័ន្ធ គេហទំព័រ CDROM និងតាមសៀវភៅកំរងស្ថិតិ
- បន្តដំណើរការរៀបចំការអង្កេតគ្រួសារ ដោយធ្វើការប៉ាន់ស្មានលើចំណាយប្រើប្រាស់គ្រួសារដើម្បីកសាងគណនេយ្យជាតិ និងប៉ាន់ស្មានខ្សែបន្ទាត់នៃភាពក្រីក្រប្រចាំឆ្នាំ
- បោះពុម្ពផ្សាយគណនេយ្យជាតិប្រចាំត្រីមាស
- បោះពុម្ពផ្សាយការប៉ាន់ស្មានអត្រាភាពក្រីក្រប្រចាំឆ្នាំ
- កសាងសន្ទស្សន៍ថ្លៃផលិតផលកសិកម្ម និងផលិតករ
- អនុវត្តជំរឿនទូទៅនូវប្រជាជនឆ្នាំ ២០០៨
- អនុវត្តការអង្កេតសេដ្ឋកិច្ច សង្គមកិច្ចកម្ពុជា រាល់៥ឆ្នាំម្តង
- អនុវត្តការអង្កេតសហគ្រាស
- អនុវត្តការអង្កេតប្រជាសាស្ត្រ និងសុខភាពឆ្នាំ ២០១០
- ដំណើរការជំរឿនកសិកម្ម

## ៨. ធ្វើឱ្យប្រសើរឡើងនូវការផ្តល់ព័ត៌មាន និងបង្កើនការប្រើប្រាស់ស្ថិតិផ្លូវការ

គោលដៅទី៨នេះ មានចំណុចដៅចំនួនពីរ:

- ធ្វើឱ្យប្រសើរនូវលទ្ធភាពទទួលបានស្ថិតជាតិផ្លូវការ
- ធ្វើឱ្យប្រសើរឡើងការយល់ដឹងអំពីស្ថិតិផ្លូវការ និងការប្រើប្រាស់របស់វា ព្រមទាំងការអនុវត្ត ដ៏ទូលំទូលាយ សម្រាប់ការរៀបចំគោលនយោបាយ ការកំណត់គោលដៅ និងអាទិភាពសំខាន់ៗ នានា

*សកម្មភាពដែលត្រូវការដើម្បីសម្រេចទិសដៅ និងចំណុចដៅមានដូចតទៅ :*

- បង្កើតមជ្ឈមណ្ឌលរក្សាទិន្នន័យស្ថិតិជាតិ
- លទ្ធភាពទទួលបានទិន្នន័យស្ថិតិតាមរយៈប្រព័ន្ធដំណើរការផ្នែកទន់ (SuperStar) ទាន់ពេលវេលាស្តីពីការវិភាគកំរិតមីក្រូឬតាមរយៈ CAMInfo និងការផ្សព្វផ្សាយមីក្រូទិន្នន័យ ឬតាមរយៈមជ្ឈមណ្ឌលអ្នកប្រើប្រាស់ទិន្នន័យជាដើម

- ធ្វើឱ្យប្រសើរឡើងការផ្សព្វផ្សាយមេតាទិន្នន័យ (Metadata) និងរបាយការណ៍តាមរយៈការកែទម្រង់គេហទំព័រវិទ្យាស្ថានជាតិស្ថិតិ តាមរយៈការបង្កើនទទ្ធភាពទទួលបានស្ថិតិជាតិផ្លូវការ
- ពង្រីកបណ្តាញផ្ទៃក្នុងស្ថិតិជាក់ស្តែងរបស់វិទ្យាស្ថានជាតិស្ថិតិ ជាមួយអង្គភាពស្ថិតិតាមក្រសួងពាក់ព័ន្ធ ដើម្បីផ្តល់លទ្ធភាពទទួលបានបណ្តាញអ៊ីនធើណែត ដើម្បីអាចទទួលបានទិន្នន័យស្ថិតិពីមជ្ឈមណ្ឌលរក្សាទិន្នន័យស្ថិតិជាតិ
- បណ្តុះបណ្តាលជាមួយផ្នែកខាងក្រៅតាមរយៈយន្តការអភិវឌ្ឍន៍ជាមួយក្រសួងពាក់ព័ន្ធ និងអង្គការមិនមែនរដ្ឋាភិបាលនានាស្តីពីការប្រើប្រាស់ប្រភពទិន្នន័យ CamInfo Verion 3 និងតាមយេះប្រភពទិន្នន័យ SuperSTAR
- កសាងសមត្ថភាពបុគ្គលិកនិងបណ្តុះបណ្តាល តាមរយៈអង្គភាពវិភាគស្ថិតិ ដែលមាននៅក្នុងវិទ្យាស្ថានជាតិស្ថិតិ

# ជំពូកទី៦

## តម្រូវការសមត្ថភាព និងធនធានចាំបាច់សម្រាប់ការអនុវត្ត *ផយផក*

ដើម្បីអនុវត្ត *ផយផក* ក្រសួងផែនការត្រូវការសមត្ថភាព និងធនធានគ្រប់គ្រាន់ : ក្នុងនេះមានធនធានមនុស្ស (ចំនួនមន្ត្រីត្រឹមត្រូវ និងសមស្រប ចម្រុះដោយជំនាញបច្ចេកទេស មានរចនាសម្ព័ន្ធស្ថាប័នគ្រប់គ្រាន់ មូលដ្ឋានពតិមាន/ចំណេះដឹងមូលដ្ឋានល្អទៅនឹងគោលនយោបាយមូលដ្ឋាន។

### ៦.១ ការអភិវឌ្ឍធនធានមនុស្ស និងសមត្ថភាព

ការអភិវឌ្ឍធនធានមនុស្ស និងសមត្ថភាពស្ថាប័ន គឺជាអាទិភាពមួយរបស់រាជរដ្ឋាភិបាលកម្ពុជា។ ទាក់ទងនឹងផ្នែកនេះ អនុសាសន៍ត្រូវបានផ្តល់ដូចខាងក្រោម :

- ត្រូវរៀបចំការគ្រប់គ្រងធនធានមនុស្សមួយមានប្រសិទ្ធភាពជាងមុន ។
- រៀបចំ និងឯកភាពអំពីក្របខណ្ឌអភិវឌ្ឍន៍សមត្ថភាព ។

ចំពោះក្រសួងផែនការនេះមានន័យថា :

- **ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ កំណែទម្រង់រដ្ឋបាលសាធារណៈនិងមន្ត្រីស៊ីវិល** ចាំបាច់ត្រូវតែអនុវត្ត ធ្វើយ៉ាងណាឱ្យមន្ត្រីក្រសួងផែនការអាចទទួលបានប្រាក់បៀវត្សរ៍គ្រប់គ្រាន់ (ហើយមិនយូរនឹងលែងមានការពឹងផ្អែកលើការឧបត្ថម្ភបន្ថែមពីដៃគូអភិវឌ្ឍន៍ក្រៅប្រទេសទៀត) ។
- **លេខាធិការដ្ឋាន *ផយអជ*** ដែលមិនទាន់បានបង្កើតជាក្រុមមួយដែលមានមូលដ្ឋានចំណេះដឹង ចាំបាច់ត្រូវពង្រឹង (ទាំងការរៀបចំរចនាសម្ព័ន្ធស្ថាប័ន និងទាំងសមត្ថភាពផ្សាភ្ជាប់ការតាមដានត្រួតពិនិត្យ និងការវិភាគគោលនយោបាយ) ធ្វើយ៉ាងណាអាចដើរតួនាទីខ្លួនឯងដ៏សំខាន់ក្នុងការអនុវត្ត និងតាមដាន ត្រួតពិនិត្យដំណើរការនៃ *ផយអជ* ។
- **ក្របខណ្ឌ័អភិវឌ្ឍសមត្ថភាព** គួរត្រូវបានរៀបចំដោយផ្តោតលើតម្រូវការរបស់ក្រសួងផែនការ (ឧ. តម្រូវការលើការបណ្តុះបណ្តាល និងមិនមែនការផ្គត់ផ្គង់នោះទេ) ហើយសកម្មភាពបណ្តុះបណ្តាល គួរតែត្រូវបានផ្តល់/គាំទ្រតាមរយៈដំណោះស្រាយរួម (ដែលគាំទ្រដោយអ្នកផ្តល់ជំនួយ) ជាជាង ការបណ្តុះបណ្តាលមួយចំណែកម្តងៗ ។
- ម្យ៉ាងទៀត **ការបណ្តុះបណ្តាលក្នុងការងារ** គឺជាវិធីសាស្ត្រដ៏ប្រសើរបំផុតក្នុងការផ្តល់ការបណ្តុះបណ្តាល។

## ៦.២ រចនាសម្ព័ន្ធស្ថាប័ន

យោងតាម *ផយផក* ក្រសួងផែនការអាចផ្លាស់ប្តូរអង្គការលេខខ្លះ ដើម្បីជួយឱ្យក្រសួងផែនការ ផ្តោតលើការងាររបស់ខ្លួនប្រសើរជាងមុន ដូចជា :

- លេខាធិការដ្ឋាន *ផយអជ* ត្រូវការរចនាសម្ព័ន្ធប្រសើរមួយ និងការចាត់តាំងទទួលខុសត្រូវដ៏រឹងមាំ។
- ក្រុមការងារបច្ចេកទេសស្តីពីផែនការនិងកាត់បន្ថយភាពក្រីក្រ ត្រូវការដើម្បីទម្លាប់ទៅនឹង គោលការណ៍ណែនាំស្តីពីមុខងារនិងតួនាទីរបស់ក្រុមការងារបច្ចេកទេស ដែលបានដាក់ចុះដោយសេចក្តីសម្រេចរបស់រាជរដ្ឋាភិបាលកម្ពុជាកាល ពីខែកុម្ភៈឆ្នាំ ២០០៧។
- រចនាសម្ព័ន្ធរងនៃក្រុមការងារបច្ចេកទេសស្តីពីផែនការនិងកាត់បន្ថយភាពក្រីក្រ កំពុងផ្តោតលើបញ្ហាជាក់លាក់ (ឧ. ការបង្កើតនិងថែរក្សាគេហទំព័រក្រសួងផែនការ ការរៀបចំយុទ្ធសាស្ត្រទំនាក់ទំនងមួយរបស់ *ផយអជ* ការអភិវឌ្ឍដំណោះស្រាយរួមមួយចំពោះការគាំទ្រ ពីដៃគូអភិវឌ្ឍន៍ក្រៅប្រទេស ។ល។ ហើយការផ្តល់ពតិមានត្រឡប់ ទៀងទាត់ដល់ក្រុមការងារស្នូលផែនការ និងកាត់បន្ថយភាពក្រីក្រ ត្រូវបានបង្កើតនិងគ្រប់គ្រង។ ក្រុមគេហទំព័រគួរដើរតួជាឧទាហរណ៍។

ក្រៅពីក្រសួងផែនការ ដៃគូអភិវឌ្ឍន៍ក្រៅប្រទេស គួរផ្លាស់ប្តូរវិធីសាស្ត្រសហប្រតិបត្តិការរបស់ខ្លួន ហើយផ្តល់ការគាំទ្រដល់ *ផយផក* ដោយប្តូរចេញពីដំណោះស្រាយម្តងបន្តិចៗជារបៀបទ្វេភាគី ឆ្ពោះទៅដំណោះស្រាយតាមកម្មវិធីរួមមួយ (ដូចទៅនឹងដំណោះស្រាយផ្អែកលើវិស័យជាធំ ឬភាពជាដៃគូតាមប្រធានបទ ដើម្បីសម្រេចបាន ទិដ្ឋភាពផ្សេងៗនៃកិច្ចសហប្រតិបត្តការ រវាងរដ្ឋាភិបាលនិងដៃគូអភិវឌ្ឍន៍ក្រៅប្រទេស)។

ដំណោះស្រាយរួមមួយ គួរមានលក្ខណៈជាបេសកកម្មរួម ការងារវិភាគរួម ការគ្រប់គ្រងរួមមូលនិធិរួម និងការគ្រប់គ្រង ការតាមដានរួម និងការធ្វើរបាយការណ៍រួម (សម្រាប់សេចក្តីលម្អិតសូមអានរបៀបវារៈសុខដុមនីយកម្ម បន្សីនិងលទ្ធផល និងសូចនាកររបស់វា និងព្រមទាំងក្រមដែលបានព្រមព្រៀងរួចហើយ ដោយដៃគូអភិវឌ្ឍក្រៅប្រទេសមួយចំនួន)។

## ៦.៣ មូលដ្ឋានពត៌មាន/ចំណេះដឹង

ក្រសួងផែនការ (ពិសេសវិទ្យាស្ថានជាតិស្ថិតិ) មិនត្រឹមតែទទួលខុសត្រូវទិន្នន័យមួយចំនួនធំប៉ុណ្ណោះទេ ប៉ុន្តែដើម្បីទំនាក់ទំនងទិន្នន័យនេះទៅនឹងបណ្តាញមួយនៃអ្នកដែលត្រូវការប្រើប្រាស់ទាំងនៅក្នុងក្រសួងផែនការ និងរាជរដ្ឋាភិបាលកម្ពុជា ព្រមទាំងជាមួយសង្គមស៊ីវិល និងសាធារណជនទូទៅ និងសហគមន៍អ្នកផ្តល់ជំនួយ ។ ដើម្បីធ្វើឱ្យបានល្អពេញលេញមុខងារនេះ ក្រសួងផែនការត្រូវការៈ

- ការទទួលបានល្អសេវាអ៊ីនធឺណែត

- ការតភ្ជាប់បណ្តាញកុំព្យូទ័រឬអ៊ីនធឺណែតហើយមានដំណើរការល្អដែលអាចជួយដល់មន្ត្រីផែនការមានភាពងាយស្រួលក្នុងការទំនាក់ទំនងការងារល្អប្រសើរជាងមុន ។
- គេហទំព័ររបស់ក្រសួងផែនការមួយ ដែលផ្តល់ពត៌មានថ្មីៗជាប្រចាំដល់សាធារណៈជនទូទៅ ។

គេហទំព័រថ្មីមួយរបស់ក្រសួងផែនការត្រូវបង្កើត និងដាក់ឱ្យដំណើរការតាំងពីពាក់កណ្តាលឆ្នាំ២០០៧ ក៏ប៉ុន្តែការគប់គ្រងនិងការថែទាំគេហទំព័រនឹងទាមទារឱ្យមានការយកចិត្តទុកដាក់យ៉ាងខ្លាំង រួមទាំងការបញ្ចូលពត៌មាន (ពត៌មានត្រូវធ្វើបច្ចុប្បន្នភាពជាប្រចាំ) ។ បញ្ហាទទួលបានសេវាអ៊ិនធឺណែតមួយល្អប្រសើរ និងការបង្កើតប្រភេទអ៊ិនធឺណែតរបស់ក្រសួងផែនការ ឬរបស់រាជរដ្ឋាភិបាលនៅតែជាតម្រូវការដែលត្រូវតែជំនះឱ្យបាន ។

## ៦.៤ ធនធានហិរញ្ញវត្ថុ

ការរៀបចំផែនការថវិកាដែលបានធ្វើនៅក្នុងក្របខណ្ឌនៃការរៀបចំ *ផយផក* មានទឹកប្រាក់សរុបចំនួន ២៨,៣៩០,៥០០ដុល្លាអាមេរិក សម្រាប់អនុវត្ត *ផយផក* (រួមគ្រប់សកម្មភាពទាំងអស់) ។ ធនធានទាំងនេះនឹងត្រូវគៀរគរចេញ ពីថវិការបស់រាជរដ្ឋាភិបាល និងការគាំទ្ររបស់ដៃគូអភិវឌ្ឍក្រៅប្រទេស ។ ការអនុវត្ត *ផយផក* នឹងមិនត្រឹមតែ ពឹងផ្អែកលើការមានធនធានទាំងនេះប៉ុណ្ណោះទេ តែថែមទាំងពឹងលើសមត្ថភាពក្នុងការបន្សុំធនធានទាំងនេះទៅនឹងអាទិភាពដែលបានលើកឡើងនៅក្នុង *ផយផក* ផងដែរ ។ កន្លងមកការគាំទ្រមកក្រសួងផែនការ និងការរៀបចំផែនការនិងកាត់បន្ថយភាពក្រីក្រ ភាគច្រើនត្រូវបានផ្តល់បន្តិចម្តងៗ និងជាដំណាក់ៗតាមរយៈឧបករណ៍ចម្រុះមួយ (ឧ. តាមរយៈថវិកាជាតិ ប្រាក់កញ្ចី ជំនួយឥតសំណង ជំនួយបច្ចេកទេស) ដែលភាគច្រើនមិនបានសម្របសម្រួលល្អ ។ ទៅអនាគតសង្ឃឹមថា ការផ្តល់មូលនិធិរួមនឹងកើតមានឡើងក្នុងក្របខ័ណ្ឌការងារនៃដំណោះស្រាយរួមមួយរបស់អ្នកផ្តល់ជំនួយ ។ ដំណោះស្រាយរបៀបនេះ នឹងជួយកាត់បន្ថយអន្តរតម្លៃ និងដើម្បីចៀសវាងការខ្វះចន្លោះ និងការជាន់គ្នា ។ ដើម្បីអនុវត្ត *ផយផក* ត្រូវការការគាំទ្រសម្ភារៈបរិក្ខាគ្រប់គ្រាន់ និងមធ្យោបាយដឹកជញ្ជូនផងដែរ ។

ក្រៅពីតម្រូវការហិរញ្ញវត្ថុនៃ *ផយផក* ក៏នៅមានបញ្ហាប្រឈមដ៏ធំចំពោះការអនុវត្ត *ផយអជ* ។ តាមការប៉ាន់ស្មាន ទឹកប្រាក់ចំនួន ៣៥០០លានដុល្លា នឹងត្រូវការសម្រាប់វិស័យសាធារណៈក្នុងអំឡុងឆ្នាំ ២០០៦-២០១០ ដើម្បីធ្វើឱ្យសម្រេចនូវគោលដៅ និងចំណុចដៅ ដែលបានចែងក្នុង *ផយអជ* ។

# ជំពូកទី៧

## ការត្រួតពិនិត្យឡើងវិញប្រចាំឆ្នាំនៃ *ផយផក*

ក្រសួងផែនការទទួលស្គាល់ថា វាមានសារសំខាន់ណាស់ដើម្បីធ្វើការតាមដាន និងត្រួតពិនិត្យមើលឡើងវិញ ជាទៀងទាត់អំពីការអនុវត្ត *ផយផក* ដោយធ្វើការប្រៀបធៀបទៅនឹងទិសដៅ និងចំណុចដៅនានា ដើម្បីធានាថាការអនុវត្ត *ផយផក* បានដំណើរការកន្លងដូចដែលបានគិតទុក និងតាមល្បឿនដែលចង់បាន ។ ដូចនេះត្រូវតែមានការប្រជុំប្រចាំឆ្នាំ ដើម្បីពិនិត្យមើលឡើងវិញលើការអនុវត្ត *ផយផក* ។

ការរៀបចំការប្រជុំពិនិត្យមើលប្រចាំឆ្នាំ *ផយផក* នឹងត្រូវរៀបចំដោយក្រសួងផែនការ ។ អ្នកចូលរួមសំខាន់ក្នុងការប្រជុំពិនិត្យមើលប្រចាំឆ្នាំ *ផយផក* គឺឧត្តមមន្ត្រីពីអគ្គនាយកផែនការ និងវិទ្យាស្ថានជាតិស្ថិតិ និងតំណាងពីដៃគូអភិវឌ្ឍន៍ក្នុងក្រុមស្នូលនៃក្រុមការងារបច្ចេកទេសផែនការនិងការកាត់បន្ថយភាពក្រីក្រ ។ ការប្រជុំ នឹងត្រូវផ្អែកលើរបាយការណ៍វឌ្ឍនភាពដែលរៀបចំដោយក្រសួងផែនការ ។ ទិសដៅនឹងត្រូវធ្វើដើម្បីពិនិត្យមើលឡើងវិញ *ផយផក* ធ្វើយ៉ាងណាដើម្បីឱ្យក្រសួងផែនការនិងភាគីទាំងអស់អាចៈ

- វាយតម្លៃពីវឌ្ឍនភាព ។
- កំណត់ពីឧបស័គ្គ ។
- ផ្តល់លទ្ធភាពឱ្យអ្នកពាក់ព័ន្ធ (ក្រសួងផែនការ និងអ្នកពាក់ពន្ធ័) ដើម្បីតម្រែតម្រង់ឱ្យស្របនឹង *ផយផក* និងកំណត់អាទិភាពនៅពេលណាចាំបាច់ ។
- ដើម្បីរៀបចំផែនការការងារ និងផែនការថវិកាប្រចាំឆ្នាំ ។

នៅពេលដ៏ឆាប់ ដំណោះស្រាយរួមមួយរបស់អ្នកផ្តល់ជំនួយត្រូវបានបង្កើតឡើង ពេលនោះ *ផយផក* នឹងការគាំទ្ររួមរបស់អ្នកផ្តល់ជំនួយ នឹងត្រូវបានពិនិត្យឡើងវិញជាមួយគ្នា ធ្វើយ៉ាងណាឱ្យការពិនិត្យឡើងវិញរួមគ្នាតាមវិស័យ (ឧ. ផែនការនិងកាត់បន្ថយភាពក្រីក្រ) នឹងត្រូវធ្វើឡើងប្រចាំឆ្នាំ ។

# ឧបសម្ព័ន្ធ

***ឧបសម្ព័ន្ធ ១***

## តារាងម៉ាទ្រីស

| គោលដៅ/ចំណុចដៅ | សកម្មភាព | ពេលវេលាអនុវត្ត | | | | | ថវិកាប៉ាន់ស្មាន (ដុល្លា) |
|---|---|---|---|---|---|---|---|
| | | ២០០៦ | ២០០៧ | ២០០៨ | ២០០៩ | ២០១០ | |
| **គោលដៅទី១ : ធានាការអនុវត្ត *ផយអជ* និងធ្វើឱ្យមានភាពជឿនលឿន ដើម្បីឈានទៅសម្រេចបាន *កអសក*** | | | | | | | |
| **ចំណុចដៅទី១ : ផ្សព្វផ្សាយ ផយអជ និងបង្កើតឱ្យមានប្រភព ពត៌មាន និងការទំនាក់ទំនង នៅក្រសួងផែនការ** | **១.១ រៀបចំនិងអនុវត្តយុទ្ធសាស្ត្រសម្រាប់ផ្សព្វផ្សាយ *ផយអជ* និងយុទ្ធសាស្ត្រទំនាក់ទំនង** | | | | | | |
| | ▪ បោះពុម្ពផ្សាយ *ផយអជ* ទាំងមូលនិងសង្ខេប | ✓ | | | | | ៦០,០០០ |
| | ▪ រៀបចំយុទ្ធសាស្ត្រសម្រាប់ផ្សព្វផ្សាយ *ផយអជ* និងការទំនាក់ទំនង នៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ | ✓ | ✓ | ✓ | | | ៧,០០០ |
| | ▪ ផ្សព្វផ្សាយ *ផយអជ* នៅថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ | ✓ | ✓ | | | | ៧៦,០០០ |
| | ▪ ធានាថា របាយការណ៍វឌ្ឍនភាពប្រចាំឆ្នាំស្តីពី *ផយអជ* អាចប្រើប្រាស់ក្នុងនាម ជារបាយការណ៍ប្រទេសអភិវឌ្ឍន៍តិចតួចបំផុត (ការសន្យារបស់រាជរដ្ឋាភិបាល កម្ពុជា ក្រោមកិច្ចព្រមព្រៀងប្រ៊ុសសែល) និងរបាយការណ៍គោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍ (សូមមើល ៧.១) | | ✓ | ✓ | ✓ | ✓ | ២,០០០ |
| | ▪ រៀបចំ សំភារៈបរិក្ខានិងឯកសារ សម្រាប់ផ្សព្វផ្សាយ *ផយអជ* ដោយផ្តោតជាពិសេស លើបញ្ហាប្រជាជន សុខភាពបន្តពូជ យេនឌ័រ និងយុវ័យ ដល់ប្រជា ពលរដ្ឋទូទៅ និង សាធារណៈជនតាមរយៈទូរទស្សន៍ វិទ្យុ សារពតិមាន សៀវភៅបត់ និងសៀវភៅតូច | | | | | | |
| | ▪ រៀបចំសំភារបរិក្ខាស្តីពី *គអសក/ផយអជ/ភាពក្រីក្រ* ដើម្បីគាំទ្រដល់ ទិវា ផ្សេងៗនៅថ្នាក់ជាតិ រួមទាំងទិវាលុបបំបាត់ភាពក្រីក្រ ។ (សៀវភៅតូច និងសៀវភៅបត់) | | | ✓ | ✓ | ✓ | ៤,០០០ |

| គោលដៅ/ចំណុចដៅ | សកម្មភាព | ពេលវេលាអនុវត្ត | | | | | ថវិកាប៉ាន់ស្មាន (ដុល្លា) |
|---|---|---|---|---|---|---|---|
| | | ២០០៦ | ២០០៧ | ២០០៨ | ២០០៩ | ២០១០ | |
| | ▪ ផ្សព្វផ្សាយ *ផយអជ/គអសក* ដល់និស្សិត អង្គការក្រៅរដ្ឋាភិបាល និងសង្គម ស៊ីវិល តាមរយៈ វេទិកាសាធារណៈ រួមទាំងការពិភាក្សាជាមួយនិស្សិត និង យុវជន ដោយផ្អែកលើ ឯកសារនិង គោលនយោបាយដែលទាក់ទងនឹង *គអសក ផយអជ និង*ភាពក្រីក្រ | | ✓ | | | | ៧,០០០ |
| | ▪ អនុវត្តការផ្សព្វផ្សាយ *គអសក/ផយអជ* នៅថ្នាក់ក្រោមជាតិ ជាមួយនិងកិច្ច សហប្រតិបត្តិការ ជាមួយសង្គមស៊ីវិល/អង្គការក្រៅរដ្ឋភិបាល | | ✓ | | | | ៧,០០០ |
| | ▪ រៀបចំការត្រៀមផ្សព្វផ្សាយ *គអសក/ផយអជ* នៅថ្នាក់ខេត្ត និងរៀបចំយុទ្ធសាស្ត្រ ផ្សព្វផ្សាយ ទំនាក់ទំនង និងការអនុវត្ត ក៏ដូចជាឧបករណ៍ ផ្សេងៗគ្នាសម្រាប់ ផ្សព្វផ្សាយ *គអសក/ផយអជ* នៅថ្នាក់ខេត្ត ។ | | | ✓ | ✓ | | ៨០,០០០ |
| | **១.២ រៀបចំ និងដំណើរការ គេហទំព័រអគ្គនាយកដ្ឋានផែនការ/ក្រសួងផែនការ** | | | | | | |
| | ▪ រៀបចំ និងចុះកិច្ចសន្យាជាមួយក្រុមហ៊ុនឯកជន ស្តីពីការរៀបចំ និងគ្រប់គ្រងគេហទំព័ អគ្គនាយកដ្ឋានផែនការ ក្រសួងផែនការ | ✓ | ✓ | | | | ៩,២០០ |
| | ▪ បណ្តុះបណ្តាលដល់មន្ត្រីក្រសួងផែនការ/សមាជិកលេខាធិការដ្ឋាន *ផយអជ* ពីជំនាញធ្វើបច្ចុប្បន្នភាព គេហទំព័រ និងការគ្រប់គ្រងបរិក្ខា | | ✓ | ✓ | ✓ | ✓ | ៤,១០០ |
| | ▪ ដំណើរការ គ្រប់គ្រង និងធ្វើបច្ចុប្បន្នភាពគេហទំព័រអគ្គនាយកដ្ឋាន ផែនការ/ក្រសួងផែនការ | | ✓ | ✓ | ✓ | ✓ | ៦,២០០ |
| **ចំណុចដៅទី២ ៖ ពង្រឹងការបន្សីវវាងផែនការយុទ្ធសាស្ត្រតាម វិស័យ ផែនការយុទ្ធសាស្ត្រនៅ ថ្នាក់ក្រោមជាតិ និងគោលនយោ បាយនិងផែនការ អន្តរវិស័យ ជា មួយនឹងអាទិភាពនៃ *ផយអជ* ។** | **២.១ សហការជាមួយក្រសួង-ស្ថាប័នពាក់ព័ន្ធ ក្នុងការរៀបចំសេចក្តីព្រាង យុទ្ធសាស្ត្រថ្មីតាមវិស័យ ឬបន្សីយុទ្ធសាស្ត្រតាមវិស័យដែលមានស្រាប់ ជាមួយ ផយអជ** | | | | | | |
| | ▪ ទំនាក់ទំនងជាមួយក្រសួងពាក់ព័ន្ធ តាមរយៈក្រុមការងារបច្ចេកទេស (ជាពិសេស ជាមួយវិស័យ អាទិភាព *ផយអជ*) ដើម្បីកំណត់អាទិភាព (ដូចជា ការអភិវឌ្ឍ ដោយផ្តោតលើ ការកាត់បន្ថយភាព ក្រីក្រ ក្នុងយុទ្ធសាស្ត្រតាមវិស័យ) | | ✓ | ✓ | ✓ | | ៧,០០០ |
| | ▪ ធានាធ្វើឱ្យស្របគ្នា តាមរយៈការផ្តល់ការណែនាំ ការរៀបចំកិច្ចប្រជុំ/សិក្ខាសាលា លំហូរពត៌មាន ។ល។ | | | ✓ | ✓ | ✓ | ១៥,០០០ |

| គោលដៅ/ចំណុចដៅ | សកម្មភាព | ពេលវេលាអនុវត្ត | | | | | ថវិកាប៉ាន់ស្មាន (ដុល្លា) |
|---|---|---|---|---|---|---|---|
| | | ២០០៦ | ២០០៧ | ២០០៨ | ២០០៩ | ២០១០ | |
| | ▪ ផ្តល់ទិន្នន័យសមស្រមសម្រាប់ការតាមដានត្រួតពិនិត្យ និងវាយតម្លៃ ពីក្រសួង-ស្ថាប័ន ពាក់ព័ន្ធ និងមន្ទីរផែនការខេត្ត | | ✓ | ✓ | ✓ | ✓ | ១២,០០០ |
| | ▪ កសាងសមត្ថភាពដល់មន្ត្រីក្រសួងផែនការ ក្រសួងពាក់ព័ន្ធ និងខេត្ត (តាមរយៈ ការបណ្តុបណ្តាល ។ល ។) ដើម្បីបំពេញលក្ខខ័ណ្ឌការងារតាមដាន ត្រួតពិនិត្យ និងវាយតម្លៃខាងលើ | | | ✓ | ✓ | ✓ | ១១០,០០០ |
| | **២.២ ធ្វើការជាមួយគណៈកម្មាធិការអភិវឌ្ឍន៍ជនបទខេត្ត ដើម្បីបន្ស៊ីផែនការ (គោលដៅ ចំណុចដៅ អាទិភាព សកម្មភាព ធនធាន) ជាមួយ គអសក និង ផយអជ តាមរយៈការវិភាគពីស្ថានភាពខេត្ត កំណត់អាទិភាព កំណត់ចំណាយ ផ្តល់ទិន្នន័យសមស្របសម្រាប់ការតាមដាន ។ល ។** | | | | | | |
| | ▪ រៀបចំការណែនាំស្តីពីការវិភាគស្ថានភាពខេត្ត ការកំណត់អាទិភាព និង ទិន្នន័យ ចាំបាច់ សម្រាប់ការតាមដាន និងផ្តល់ការបណ្តុះបណ្តាលដល់អ្នករៀបចំ ផែនការស្រុកនិងខេត្ត | | | ✓ | ✓ | ✓ | ៨៥,០០០ |
| | ▪ ផ្តល់ការគាំទ្រដល់កិច្ចប្រជុំ និងសិក្ខាសាលានានានៅថ្នាក់ខេត្ត ស្តីពីការរៀបចំ ផែនការ ដោយផ្អែកលើ *ផយអជ* | | | ✓ | ✓ | ✓ | ៨០,០០០ |
| | ▪ រៀបចំការសិក្សាសមស្រប និងរៀបចំរបាយការណ៍វឌ្ឍនភាពពីការអនុវត្ត *គអសក* នៅថ្នាក់ក្រោមជាតិ នៅខេត្តជ្រើសរើសមួយចំនួន | | | ✓ | ✓ | ✓ | ១៥០,០០០ |
| | ▪ គាំទ្រដល់អង្គការក្រៅរដ្ឋាភិបាល ដើម្បីផ្តល់របាយការណ៍ស្តីពីលទ្ធភាពធ្វើ អន្តរាគមន៍ដែលមានជះឥទ្ធិពលឆាប់រហ័ស សម្រាប់ការសម្រេចឱ្យបាន *គអសក/ផយអជ* នៅថ្នាក់ក្រោមជាតិ | | | | ✓ | ✓ | ២,០០០ |
| | ▪ គាំទ្រដល់ការកសាងសមត្ថភាពដល់ប្រព័ន្ធផែនការដែលឆ្ពោះទៅរកការកាត់ បន្ថយភាពក្រីក្រនៅថ្នាក់ខេត្ត និងស្រុក (យោងតាម *ផយអជ*) | | | ✓ | ✓ | ✓ | ១២,០០០ |
| | **២.៣ ពង្រឹងភាពដឹកនាំ និងភាពជាដៃគូជាមួយអ្នកមានចំណែកពាក់ពន្ធ័ ដើម្បីអនុវត្ត ផែនការវិនិយោគអាហារូបត្ថម្ភកម្ពុជា** | | | | | | |
| | ▪ ធ្វើបច្ចុប្បន្នភាពជាប្រចាំ និងរៀបចំរបាយការណ៍វឌ្ឍនភាពប្រចាំឆ្នាំ ស្តីពីការអនុវត្តផែនការវិនិយោគអាហារូបត្ថម្ភកម្ពុជា (២០០៣-២០០៧) | ✓ | ✓ | | | | ៤,០០០ |

| គោលដៅ/ចំណុចដៅ | សកម្មភាព | ពេលវេលាអនុវត្ត | | | | | ថវិកាប៉ាន់ស្មាន (ដុល្លា) |
|---|---|---|---|---|---|---|---|
| | | ២០០៦ | ២០០៧ | ២០០៨ | ២០០៩ | ២០១០ | |
| | ▪ បញ្ចូលសូចនាករសំខាន់ៗនៃផែនការវិនិយោគអាហារូបត្ថម្ភកម្ពុជា ២០០៣-២០០៧ ដែលសំរេចបាន ទៅក្នុងរបាយការណ៍វឌ្ឍនភាពប្រចាំឆ្នាំ ផយអជ | | ✓ | | | | |
| | **២.៤ កំណត់តួនាទី និងការទទួលខុសត្រូវ ដើម្បីរៀបចំផែនការវិនិយោគអាហារូបត្ថម្ភកម្ពុជាលើកទី២ (២០០៨-២០០១៣)** | | | | | | |
| | ▪ កៀរគរការគាំទ្រផ្នែកបច្ចេកទេសនិងហិរញ្ញវត្ថុរបស់ដៃគូអភិវឌ្ឍន៍ដើម្បីរៀបចំនិងអនុវត្ត ផែនការ វិនិយោគអាហារូបត្ថម្ភកម្ពុជាទី២ (២០០៨-២០១២) | ✓ | ✓ | ✓ | ✓ | ✓ | ២០០,០០០ |
| | ▪ ដឹកនាំការរៀបចំផែនការវិនិយោគអាហារូបត្ថម្ភកម្ពុជាលើកទី២ (២០០៨-២០១២) ដោយមាន កិច្ចសហការជាមួយក្រសួងពាក់ព័ន្ធ និង ដៃគូអភិវឌ្ឍន៍ ក្រៅប្រទេស | | ✓ | | | | |
| | ▪ ធ្វើបច្ចុប្បន្នភាពជាប្រចាំ និងរៀបចំរបាយការណ៍វឌ្ឍនភាពប្រចាំឆ្នាំ ស្តីពីការអនុ វត្ត ផែនការវិនិយោគ អាហារូបត្ថម្ភកម្ពុជាលើកទី២ (២០០៨-២០១៣) | | | ✓ | ✓ | ✓ | ៦,០០០ |
| **ចំណុចដៅទី៣ : ធានាធ្វើឱ្យមានសង្គតភាពដំណើរការវិភាជន៍ប្រភពធនធាន (ថវិកាប្រចាំឆ្នាំ ក្រប ខ័ណ្ឌថវិការយៈពេលមធ្យម បឡ៊ី និងធ្វើឱ្យស្រប គ្នារវាង *ករស* នឹង ជំនួយអភិវឌ្ឍន៍ក្រៅប្រទេស) ជា មួយនឹងអាទិភាពនៃ *ផយអជ* ។** *(រួមការងារនិងសហការទទួលខុសត្រូវជាមួយ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋសភាជាតិ និង ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា)* | **៣.១ បង្កើតការងារឱ្យបានជិតស្និតជាមួយកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ** | | | | | | |
| | ▪ សំណើសុំឱ្យក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ/ក្រុមការងារបច្ចេកទេសស្តីពី ការគ្រប់គ្រងហិរញ្ញ វត្ថុសាធារណៈ បង្ហាញពី PFMRP | | ✓ | ✓ | ✓ | ✓ | ៥,០០០ |
| | ▪ រៀបចំឱ្យមានតំណាង លេខាធិការដ្ឋាន *ផយអជ* នៅក្នុង *ក្រុមការងារបច្ចេក ទេសដើម្បីការគ្រប់គ្រង ហិរញ្ញវត្ថុសាធារណៈ* | | ✓ | ✓ | ✓ | ✓ | ៥,០០០ |
| | **៣.២ ផ្តល់បទបង្ហាញស្តីពី ការភ្ជាប់រវាង ផយអជ និងការគ្រប់គ្រងហិរញ្ញ វត្ថុសាធារណៈ ដល់គណៈកម្មាធិការរដ្ឋសភា** | | | | | | |
| | ▪ ធ្វើការជាមួយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុដើម្បីរៀបចំសំណើសំរាប់ ការភ្ជាប់រវាង ផយអជ និងការគ្រប់គ្រងហិរញ្ញ វត្ថុសាធារណៈ | | | ✓ | ✓ | ✓ | ៣,០០០ |
| | ▪ ធ្វើបទបង្ហាញស្តីពី ការភ្ជាប់រវាង ផយអជ និងការគ្រប់គ្រងហិរញ្ញ វត្ថុសាធារណៈ ដល់គណៈកម្មាធិការរដ្ឋសភា | | | ✓ | ✓ | ✓ | |

| គោលដៅ/ចំណុចដៅ | សកម្មភាព | ពេលវេលាអនុវត្ត | | | | | ថវិកាប៉ាន់ស្មាន (ដុល្លា) |
|---|---|---|---|---|---|---|---|
| | | ២០០៦ | ២០០៧ | ២០០៨ | ២០០៩ | ២០១០ | |
| | **៣.៣ ចាប់ផ្ដើម រៀបចំ *កវស* បន្សុីជាមួយអាទិភាពរបស់ ក្រសួង និង ផយអជ ពីខែមករា ឆ្នាំ២០០៧ ទៅ។** | | | | | | |
| | ▪ ផ្ដល់ការណែនាំស្ដីពី ការអនុវត្ត *កវស* ដល់ក្រសួងពាក់ព័ន្ធ | ✓ | ✓ | ✓ | ✓ | ✓ | ៥០០ |
| | ▪ សហការជាមួយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ផ្ដល់ពត៌មានដល់ក្រសួងពាក់ព័ន្ធពីដើម្បីដំណើរការរៀបចំ *កវស* ។ | ✓ | ✓ | ✓ | ✓ | ✓ | ៥០០ |
| | ▪ សហការជាមួយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា និង ក្រសួងពាក់ព័ន្ធ បង្កើតគម្រោងសាវនកម្ម ដើម្បីតាមដានការអនុវត្ត *កវស* ។ | ✓ | ✓ | ✓ | ✓ | ✓ | ៥០០ |
| | ▪ បោះពុម្ពផ្សាយ *កវស* ។ | ✓ | ✓ | ✓ | ✓ | ✓ | ១៥,០០០ |
| | **៣.៤ ចាប់ផ្ដើមធ្វើការជាមួយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ក្នុងការធ្វើឱ្យស្របគ្នាពីពេលវេលាធ្វើការងារ ក្នុងផ្នែកផ្ដល់ថវិកា និងការបញ្ចូល កវស/ក្របខ័ណ្ឌនៃការចំណាយ រយៈពេលមធ្យម** | | | | | | |
| | ▪ រៀបចំការបណ្ដុះបណ្ដាលស្ដីពី ការកំណត់អាទិភាពអន្តរវិស័យ ការបន្សុីជាមួយ អាទិភាព *គអសក/ផយអជ* និងការចំណាយ | | ✓ | ✓ | ✓ | ✓ | ១០,០០០ |
| | ▪ គាំទ្រដល់ការកំណត់អត្តសញ្ញាណនិងអាទិភាពរបស់ ក្រសួងសេដ្ឋកិច្ចនិង ហិរញ្ញវត្ថុ និងក្រសួងពាក់ព័ន្ធ | | ✓ | ✓ | ✓ | ✓ | ៥០០ |
| | ▪ ពិនិត្យមើលឡើងវិញដំណើរការនិងមធ្យោបាយរៀបចំផែនការថវិកា និងធ្វើ ឱ្យស្របគ្នាជាមួយ នឹងការអនុវត្ត | | ✓ | ✓ | ✓ | ✓ | ៥,០០០ |
| | **៣.៥ ដោយផ្អែកលើការកែសម្រួលដំណើរការរៀបចំ *កវស* ធានាថា រាល់ការសន្យានានាដែលមានចែងក្នុង *ផយអជ-កវស* ត្រូវបានវិភាជន៍ថវិកាឱ្យសម្រាប់ឆ្នាំ២០០៨** | | | | | | |
| | ▪ ភ្ជាប់អាទិភាពនិងការប៉ាន់ស្មានចំណាយ ជាមួយមធ្យោបាយនៃការរៀបចំ ផែនការថវិកា (បន្តពីសកម្មភាពក្រោមចំណុច ៣.៤ ខាងលើ) | | ✓ | ✓ | ✓ | ✓ | |
| **ចំណុចដៅទី៤ : ផ្ដោតការយក ចិត្តទុកដាក់លើតំបន់និងគ្រួសារ ក្រីក្រ ដើម្បី** | **៤.១ បង្កើតនីតិវិធី និងលក្ខខ័ណ្ឌការងារឯកភាពនិងស្របគ្នា ដើម្បីការកំណត់អត្តសញ្ញាណគ្រួសារក្រីក្រ នៅខេត្តដែលបានជ្រើសរើសសាកល្បង** | | | | | | |
| | ▪ បង្កើតនីតិវិធី និងលក្ខខ័ណ្ឌការងារឯកភាពនិងស្របគ្នា ដើម្បីការកំណត់អត្ត-សញ្ញាណគ្រួសារក្រីក្រ | ✓ | ✓ | | | | ១,០០០ |

| គោលដៅ/ចំណុចដៅ | សកម្មភាព | ពេលវេលាអនុវត្ត | | | | | ថវិកាប៉ាន់ស្មាន (ដុល្លា) |
|---|---|---|---|---|---|---|---|
| | | ២០០៦ | ២០០៧ | ២០០៨ | ២០០៩ | ២០១០ | |
| **ធានា ឱ្យធនធាន ដែលបានប្រើប្រាស់ ទទួលបាន ផលល្អ និងមាន ប្រសិទ្ធភាព ខ្ពស់បំផុត ។** | រួមទាំងណែនាំដល់អ្នកអនុវត្តន៏ដែលមិនមែនរដ្ឋាភិបាល | | | | | | |
| | ▪ បង្កើតប្រព័ន្ធកុំព្យូទ័រ នៅអគ្គនាយកដ្ឋានផែនការ ក្រសួងផែនការ សម្រាប់ គ្រប់គ្រងទិន្នន័យស្ដីពីការកំណត់អត្តសញ្ញាណគ្រួសារក្រីក្រ | | ✓ | | | | ១០០,០០០ |
| | ▪ បង្កើនចំណេះដឹង ដល់អ្នកផ្ដល់សេវាកម្ម ស្ដីពីវិធីសាស្ត្រកំណត់អត្តសញ្ញាណ គ្រួសារក្រីក្រ និងជំរុញការប្រើប្រាស់បញ្ជីឈ្មោះគ្រួសារក្រីក្រសម្រាប់គោល ដៅផ្សេងៗ ។ | ✓ | ✓ | ✓ | ✓ | ✓ | ១០,០០០ |
| | **៤.២ ពង្រីកកម្មវិធីកំណត់អត្តសញ្ញាណគ្រួសារក្រីក្រឱ្យបានទូលំទូលាយ** | | | | | | |
| | ▪ រៀបចំយុទ្ធសាស្ត្រក្រសួងផែនការ ដើម្បីពង្រីកវិធីសាស្ត្រទៅអនុវត្តឱ្យបានទូលំទូលាយនៅ ខេត្តផ្សេងៗ ទៀត ។ | | | ✓ | | | ១០,០០០ |
| | ▪ រៀបចំសំណើរបស់ក្រសួងផែនការ ដើម្បីស្វែងរកប្រភពធនធានពីអ្នកផ្ដល់ជំនួយ និងរដ្ឋាភិបាល ដើម្បីពង្រីកគោលដៅសកម្មភាពទៅគ្រួសារឱ្យបានច្រើនទៀត ។ | | ✓ | ✓ | | | ០ |
| | ▪ ពង្រីកគោលដៅកំណត់អត្តសញ្ញាណគ្រួសារក្រីក្រឱ្យបាន ៥ខេត្ត និងធ្វើបច្ចុប្បន្នភាពបញ្ជីគ្រួសារក្រីក្រប្រចាំឆ្នាំ | | | ✓ | ✓ | ✓ | ៥,០០០,០០០ |
| | **៤.៣ ជំរុញកម្មវិធីបង្វែការអភិវឌ្ឍសង្គមឆ្ពោះទៅរកគ្រួសារក្រីក្រ ។** | | | | | | |
| | ▪ រៀបចំសិក្ខាសាលា បង្ហាញពីចំណេះដឹងពីវិធីសាស្ត្រទាក់ទងនឹងការវិនិយោគ ដែលមានគោលដៅផ្ដល់សេវាសង្គម | | | ✓ | ✓ | | ១៥,០០០ |
| | ▪ គាំទ្រដល់ការអភិវឌ្ឍកម្មវិធីផ្ដល់សេវាសង្គម សម្រាប់អ្នកក្រីក្រ | | | ✓ | ✓ | ✓ | ៥,០០០ |
| | ▪ រៀបចំគោលនយោបាយជាតិស្ដីពីកម្មវិធីបង្វែសង្គមសម្រាប់អ្នកក្រីក្រ និងជំរុញ | | | | ✓ | ✓ | ១០,០០០ |

| គោលដៅ/ចំណុចដៅ | សកម្មភាព | ពេលវេលាអនុវត្ត | | | | | ថវិកាប៉ាន់ស្មាន (ដុល្លា) |
|---|---|---|---|---|---|---|---|
| | | ២០០៦ | ២០០៧ | ២០០៨ | ២០០៩ | ២០១០ | |
| | ការប្រើប្រាស់ថវិការបស់រដ្ឋាភិបាលសម្រាប់ការអនុវត្ត | | | | | | |
| | **៤.៤ រៀបចំស្ថាប័ននិងដំណើរការ សម្រាប់គោលដៅភូមិសាស្ត្រ ។** | | | | | | |
| | ▪ រៀបចំផែនទីភាពក្រីក្រថ្មីនៅកម្រិតស្រុកនៅឆ្នាំ២០១០ ដោយផ្អែកលើលទ្ធផល ជំរឿន២០០៨ និងអង្កេតសេដ្ឋកិច្ចសង្គមកិច្ច ឆ្នាំ២០០៩ | | | | | ✓ | ២,០០០,០០០ |
| **ចំណុចដៅទី៥ : អភិវឌ្ឍសមត្ថភាពក្រសួងផែនការ ដើម្បីផ្ដល់ អាទិភាព និងបញ្ជ្រាបបញ្ហា យេនឌ័រទៅក្នុងផែនការ និង បញ្ចូលសមភាពយេឌ័រទៅក្នុងការអនុវត្ត *ផយអជ* ។** | **៥.១ ជំរុញការបញ្ជ្រាបយេនឌ័រទៅក្នុងប្រព័ន្ធផែនការ ។** | | | | | | |
| | ▪ គាំទ្រដល់កិច្ចប្រជុំជាប្រចាំរបស់ក្រុមការងារយេនឌ័ររបស់ក្រសួងផែនការ | ✓ | ✓ | ✓ | ✓ | ✓ | ៥,០០០ |
| | ▪ ជំរុញការបញ្ជ្រាបយេនឌ័រទៅក្នុងវដ្ដការរៀបចំផែនការ | ✓ | ✓ | ✓ | ✓ | ✓ | |
| | **៥.២ កសាងសមត្ថភាព ដើម្បីបញ្ជ្រាបយេនឌ័រទៅក្នុងប្រព័ន្ធផែនការ ដោយរៀបចំវគ្គបណ្ដុះបណ្ដាលពីថ្នាក់ជាតិ ដល់ថ្នាក់មូលដ្ឋាន** | | | | | | |
| | ▪ បណ្ដុះបណ្ដាលដល់អ្នកបណ្ដុះបណ្ដាលបន្ត ដល់សមាជិកក្រុមការងារបញ្ជ្រាបយេនឌ័រ | | ✓ | ✓ | ✓ | ✓ | ៦,០០០ |
| | ▪ ផ្ដល់ការបណ្ដុះបណ្ដាលពីចំណេះដឹងយេនឌ័រដល់មន្ត្រីក្រសួងផែនការ | | ✓ | ✓ | ✓ | ✓ | ៤,០០០ |
| | ▪ ផ្ដល់ការបណ្ដុះបណ្ដាលពីចំណេះដឹងយេនឌ័រទៅមន្ត្រីផែនការថ្នាក់ក្រោមជាតិ ។ | | | ✓ | ✓ | ✓ | ៤០,០០០ |
| | **៥.៣ រៀបចំ និងអនុវត្តផែនការសកម្មភាពបញ្ជ្រាបយេនឌ័រ ។** | | | | | | |
| | ▪ រៀបចំសកម្មភាពបញ្ជ្រាបយេនឌ័រ | | ✓ | | | | ៣០,០០០ |
| | ▪ អនុវត្តន៍សកម្មភាពបញ្ជ្រាបយេនឌ័រ | | | ✓ | ✓ | ✓ | |
| **គោលដៅទី២ : តាមដានត្រួតពិនិត្យ និងវាយតម្លៃ ភាពជឿនលឿននៃការអនុវត្ត*ផយអជ* និងបណ្ដាលទ្ធផលនៃ*ផយអជ/គអសក*** | | | | | | | |
| **ចំណុចដៅទី៦ : ពត៌មានស្ដីពីការ** | **៦.១ សហការជាមួយវិទ្យាស្ថានជាតិស្ថិតិ ក្រសួង-ស្ថាប័នពាក់ព័ន្ធ និងក្រុមការងារបច្ចេកទេស កែសម្រួលនិងអនុវត្តក្របខ័ណ្ឌការងារតាមដានត្រួតពិនិត្យនិងវាយតម្លៃនៃការអនុវត្ត *ផយអជ*** | | | | | | |

| គោលដៅ/ចំណុចដៅ | សកម្មភាព | ពេលវេលាអនុវត្ត | | | | | ថវិកាប៉ាន់ស្មាន (ដុល្លា) |
|---|---|---|---|---|---|---|---|
| | | ២០០៦ | ២០០៧ | ២០០៨ | ២០០៩ | ២០១០ | |
| **អនុវត្ត *ផយអជ* និងលទ្ធផលនៃ *ផយអជ/ ឥអសក* ត្រូវបានប្រមូល វិភាគ និងរាយការណ៍ពេញលេញ និងទាន់ពេល ។ (ធ្វើការ តាមរយៈការរាយការណ៍ ជាប្រចាំពីក្រសួងនិងស្ថាប័នដែលពាក់ព័ន្ធ និងជាមួយ វិទ្យាស្ថានជាតិស្ថិតិ) ។** | ▪ បង្កើតយន្តការសម្រាប់ការតាមដានត្រួតពិនិត្យប្រភពធនធានដើម្បីឱ្យស្របគ្នាជាមួយនឹង អាទិភាពនៃ *ផយអជ* តាមរយៈកិច្ចសហប្រតិបត្តិការយ៉ាងជិតស្និទ្ធរវាងស្ថាប័នស្នូលទាំង៤ (ក្រសួងផែនការ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ក.អ.ក/គ.ជ.នា និងឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ) | | ✓ | ✓ | ✓ | ✓ | ៥,០០០ |
| | ▪ ពិនិត្យមើលឡើងវិញ របាយការណ៍ពីក្រសួង-ស្ថាប័នពាក់ព័ន្ធ ធៀបនឹងអាទិភាពនៃ *ផយអជ* ដើម្បីតាមដានត្រួតពិត្យពីវឌ្ឍនភាពនៃការអនុវត្ត *ផយអជ* ដោយផ្ដោតលើសកម្មភាពនិងស្ថានភាពទានទាក់ទងនឹសូចនាករសំខាន់ៗ | | ✓ | ✓ | ✓ | ✓ | ៤,០០០ |
| | ▪ សម្របសម្រួលជាមួយស្ថាប័នដែលមានចំណែកពាក់ព័ន្ធទាំងអស់ ដើម្បីធានាការបានប្រភព ធនធានដែលបានសន្យាដល់ការអនុវត្តបណ្ដាសកម្មភាពអាទិភាពនៃ *ផយអជ* | | ✓ | ✓ | ✓ | ✓ | |
| | ▪ ផ្ដួចផ្ដើមឱ្យមានកិច្ចទំនាក់ទំនងការងារឱ្យកាន់តែជិតស្និទ្ធថែមទៀតរវាងស្ថាប័នផែនការថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិក្នុងការចែករំលែកពត៌មាន ទិន្នន័យ របាយការណ៍ និងសកម្មភាព បណ្ដុះបណ្ដាល | | ✓ | ✓ | ✓ | ✓ | ៧,០០០ |
| | ▪ រៀបចំសិក្ខាសាលានិងកិច្ចប្រជុំស្ដីពីការតាមដានត្រួតពិនិត្យការអនុវត្ត *ផយអជ* (រួមទាំងការតាមដានត្រួតពិនិត្យការអនុវត្ត *ផយអជ* នៅថ្នាក់ខេត្តផងដែរ) | | ✓ | ✓ | ✓ | ✓ | ៨០,០០០ |
| | **៦.២ រៀបចំការវិភាគគោលនយោបាយ និងវាយតម្លៃ *ផយអជ/ឥអសក*** | | | | | | |
| | ▪ រៀបចំកម្មវិធី develop schedule of rotating thematic / Goal-specific modules (ឧ. របាយការណ៍វឌ្ឍនភាពប្រចាំឆ្នាំ ក្នុងផ្នែកសុខាភិបាល ២០០៧ លទ្ធផលអង្កេតសុខភាពនិងប្រជាសាស្ត្រ ឆ្នាំ២០០៥ របាយការណ៍វឌ្ឍនភាពប្រចាំឆ្នាំស្ដីពីនិន្នាការប្រជាសាស្ត្រ ឆ្នាំ២០០៩ លទ្ធផលជំរឿន ឆ្នាំ២០០៨ ស្ថានភាពនៃភាពក្រីក្រ/របាយការណ៍វឌ្ឍនភាព ប្រចាំឆ្នាំស្ដីពី *ឥអសក* កែសម្រួលឆ្នាំ២០០៩ លទ្ធផលអង្កេតសេដ្ឋកិច្ច សង្គមកិច្ចកម្ពុជាឆ្នាំ ២០០៨) ក្នុងរបាយការណ៍វឌ្ឍនភាពប្រចាំឆ្នាំ (ផ្ដោតលើ ១. បញ្ហាដែលរួម បញ្ចូលពីទិន្នន័យតាមដាន វាយតម្លៃពីភាពពុំមានវឌ្ឍនភាព ២. ទិន្នន័យលម្អិត ដែលអាចមានពី អង្កេត ជំរឿន នៅក្នុងបណ្ដាឆ្នាំកន្លងមក ៣. រួមបញ្ចូលបញ្ហា ប្រឈមនានា) | | | | | | |

| គោលដៅ/ចំណុចដៅ | សកម្មភាព | ពេលវេលាអនុវត្ត | | | | | ថវិកាប៉ាន់ស្មាន (ដុល្លា) |
|---|---|---|---|---|---|---|---|
| | | ២០០៦ | ២០០៧ | ២០០៨ | ២០០៩ | ២០១០ | |
| | ▪ ធ្វើការសិក្សាវាយតម្លៃ ពីផលប៉ះពាល់នៃគោលនយោបាយមួយចំនួនបន្ថែម ទៀត ដែលទាក់ទង នឹងការអនុវត្ត *ផយអជ* បើសិនជាការចាំបាច់ សហការ ជាមួយដៃគូអភិវឌ្ឍន៍ក្រៅប្រទេស រៀបចំបោះពុម្ពផ្សព្វផ្សាយរបាយការណ៍ និងសេចក្តីសង្ខេបពីគោលនយោបាយ ដើម្បីគាំទ្រការផ្តល់ពតិមានដល់ការរៀបចំគោលនយោបាយ | | ✓ | ✓ | ✓ | ✓ | ១២,០០០ |
| | **៦.៣ បញ្ចូលការតាមដានត្រួតពិនិត្យសំខាន់ៗ (៦.១) និងការវិភាគ/ការវាយតម្លៃ (៦.២) ទៅក្នុងរបាយការណ៍វឌ្ឍនភាពប្រចាំឆ្នាំ** | | | | | | |
| | ▪ គាំទ្រដល់កិច្ចប្រជុំ/សិក្ខាសាលាស្តីពីរបាយការណ៍វឌ្ឍនភាពប្រចាំឆ្នាំ នៃ *ផយអជ* | | ✓ | ✓ | ✓ | ✓ | ៤០,០០០ |
| | ▪ បោះពុម្ពផ្សាយរបាយការណ៍វឌ្ឍនភាពប្រចាំឆ្នាំស្តីពី *ផយអជ* | | ✓ | ✓ | ✓ | ✓ | ៦០,០០០ |
| **ចំណុចដៅទី៧ : កំណត់ពេលវេលានៃការផ្តល់របាយការណ៍ ដែលតម្រូវសម្រាប់ ដំណើរការតាម ដានត្រួតពិនិត្យអន្តរជាតិ ដោយផ្អែកលើទិន្នន័យនៃ ការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃ *ផយអជ* និង ទម្រង់នៃរបាយការណ៍** | **៧.១ ធានាថា របាយការណ៍វឌ្ឍនភាពប្រចាំឆ្នាំស្តីពី *ផយអជ* អាចប្រើប្រាស់ក្នុងនាមជារបាយការណ៍ប្រទេសអភិវឌ្ឍន៍តិចតួចបំផុត (ការសន្យារបស់រាជរដ្ឋាភិបាលកម្ពុជាក្រោមកិច្ចព្រមព្រៀង ប្រ៊ុសសែល) និងរបាយការណ៍គោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍** | | | | | | |
| | ▪ រៀបចំរបាយការណ៍ស្តីពី *ប្រទេសមានការអភិវឌ្ឍន៍តិច* ដោយផ្អែកលើរបាយការណ៍វឌ្ឍនភាពប្រចាំឆ្នាំស្តីពី *ផយអជ* | | ✓ | ✓ | ✓ | ✓ | |
| | ▪ ចូលរួមប្រជុំ សិក្ខាសាលាស្តីពី *ប្រទេសមានការអភិវឌ្ឍន៍តិច* | | ✓ | ✓ | ✓ | ✓ | |
| | **៧.២ អគ្គនាយកដ្ឋានផែនការ ក្រសួងផែនការ រួមចំណែកក្នុងការងារវិភាគថ្នាក់ជាតិចំបងៗមួយចំនួន ដែលបានរៀបចំដោយស្ថាប័នពាក់ព័ន្ធ ផ្សេងទៀត** | | | | | | |
| | ▪ របាយការណ៍ពីការអភិវឌ្ឍធនធានមនុស្សជាតិ | | ✓ | ✓ | ✓ | ✓ | ៣០,០០០ |
| | ▪ របាយការណ៍របស់ធនាគារពិភពលោក ទៅកិច្ចប្រជុំ CDCF | | ✓ | ✓ | ✓ | ✓ | |
| | ▪ សេចក្តីថ្លែងការជាសាកល ស្តីពីរបាយការណ៍ប្រជាជនពិភពលោក | | ✓ | ✓ | ✓ | ✓ | |

| គោលដៅ/ចំណុចដៅ | សកម្មភាព | ពេលវេលាអនុវត្ត | | | | | ថវិកាប៉ាន់ស្មាន (ដុល្លា) |
| --- | --- | --- | --- | --- | --- | --- | --- |
| | | ២០០៦ | ២០០៧ | ២០០៨ | ២០០៩ | ២០១០ | |
| **ចំណុចដៅទី៨ : កសាងសមត្ថភាព ដល់មន្ត្រីក្រសួងផែនការ (សមាជិកលេខាធិការដ្ឋាន *ផយអជ* និង មន្ត្រីអគ្គនាយកដ្ឋានផែនការ ដើម្បីធានាការ អនុវត្ត និងការតាមដានត្រួតពិនិត្យនិង វាយតម្លៃ *ផយអជ* ឱ្យមានប្រសិទ្ធភាព មន្ត្រីវិទ្យាស្ថានជាតិស្ថិតិ) តាមរយៈ សិក្ខាសាលា និងការបណ្តុះបណ្តាល ក្នុងការងារ** | **៨.១ ធ្វើឱ្យប្រសើរឡើងសមត្ថភាពរបស់មន្ត្រីក្រសួងផែនការ ក្នុងការវិភាគម៉ាក្រូសេដ្ឋកិច្ចនិងភាពក្រីក្រ និងកម្មវត្ថុផ្សេងទៀត** | | | | | | |
| | ▪ បណ្តុះបណ្តាលទាំងក្នុងនិងក្រៅស្តីពី ការវិភាគម៉ាក្រូសេដ្ឋកិច្ចនិងភាពក្រីក្រ និងការបង្កើតផែនការ | | ✓ | ✓ | ✓ | ✓ | ៥០០,០០០ |
| | ▪ លើកកំពស់សមត្ថភាពមន្ត្រីក្រសួងផែនការពីការត្រួតពិនិត្យនិងវាយតំលៃ របាយការណ៍ ការអនុវត្ត *ផយអជ* និងវាយតំលៃគោលនយោបាយផលប៉ះពាល់ តាម រយៈការសិក្សាតាមមូលដ្ឋាន | ✓ | ✓ | ✓ | ✓ | ✓ | ៦០០,០០០ |
| | **៨.២ រៀបចំការបណ្តុះបណ្តាលដល់អ្នកបណ្តុះបណ្តាលបន្តស្តីពីការកំណត់អត្តសញ្ញាណគ្រួសារក្រីក្រ និងបណ្តុះបណ្តាលពីប្រព័ន្ធកុំព្យូទ័រ សម្រាប់គ្រប់គ្រងទិន្នន័យស្តីពីគ្រួសារក្រីក្រ** | | | | | | |
| | ▪ បណ្តុះបណ្តាលដល់អ្នកបណ្តុះបណ្តាលបន្តដល់មន្ត្រីក្រសួងផែនការស្តីពីការកំណត់ អត្តសញ្ញាណគ្រួសារក្រីក្រ | ✓ | ✓ | | | | ៥,០០០ |
| | ▪ បណ្តុះបណ្តាលដល់អ្នកបណ្តុះបណ្តាលបន្តស្តីពីការគ្រប់គ្រងប្រព័ន្ធទិន្នន័យកុំព្យូទ័រ គ្រួសារក្រីក្រ | | ✓ | ✓ | ✓ | ✓ | ៥,០០០ |
| | **៨.៣ រៀបចំការបណ្តុះបណ្តាលមន្ត្រីក្រសួងផែនការ ក្រសួងពាក់ព័ន្ធ និងមន្ត្រីខេត្ត (តាមរយៈការបណ្តុះបណ្តាល ។ល។) ដើម្បីបន្សុីយុទ្ធសាស្ត្រតាមវិស័យ ទៅនឹង *ផយអជ* (សូមមើល ២.១)** | | | | | | |
| | ▪ បណ្តុះបណ្តាលស្តីពី *អភិក្រមគ្រប់គ្រងទូទាំងវិស័យ* ដល់ក្រសួងផែនការ ក្រសួង-ស្ថាប័នពាក់ព័ន្ធ មន្ត្រីថ្នាក់ខេត្តដើម្បីបន្សុីយុទ្ធសាស្ត្រតាមវិស័យជាមួយ *ផយអជ* | | ✓ | ✓ | ✓ | ✓ | ១២០,០០០ |
| **គោលដៅទី៣ : ធានាឱ្យសកម្មភាពរបស់ក្រសួងផែនការនិងដៃគូ ដំណើរការទៅតាមការទាមទាររបស់អ្នកប្រើប្រាស់ ការបន្សុី ធ្វើឱ្យស្របគ្នា និងទទួលបានលទ្ធផលល្អ** | | | | | | | |
| **ចំណុចដៅទី៩ : ធានាថា ការធ្វើវិភាជន៍ ថវិកាជាតិ និងធនធានជំនួយ** | **៩.១ សន្សាយ៉ាងពេញលេញតាម *ក្រមការងារបច្ចេកទេសស្តីពីការរៀបចំផែនការនិងការកាត់បន្ថយភាពក្រីក្រ* និងតួនាទីរបស់ក្រសួងផែនការ ដែលបានកំណត់ក្នុង *ផែនការសកម្មភាព និងសុខដុមណីយកម្ម* របស់រាជរដ្ឋាភិបាលកម្ពុជា** | | | | | | |

| គោលដៅ/ចំណុចដៅ | សកម្មភាព | ពេលវេលាអនុវត្ត | | | | | ថវិកាប៉ាន់ស្មាន (ដុល្លា) |
|---|---|---|---|---|---|---|---|
| | | ២០០៦ | ២០០៧ | ២០០៨ | ២០០៩ | ២០១០ | |
| **ទៅក្រសួងផែនការ ស្របគ្នាជាមួយនឹងអាទិភាព *ផយអជ*** | ▪ រៀបចំផែនការយុទ្ធសាស្ត្ររបស់ក្រសួងផែនការ | ✓ | ✓ | ✓ | ✓ | ✓ | ១៥,០០០ |
| | ▪ បន្សីប្រភពធនធាន ទៅនឹងការអនុវត្ត *ផយអជ* | | ✓ | ✓ | ✓ | ✓ | ១,០០០ |
| | ▪ រៀបចំរបាយការណ៍ដើម្បីចូលរួមក្នុង គណៈកម្មាធិការសម្របសម្រួលរវាង រដ្ឋាភិបាលនិងដៃគូអភិវឌ្ឍន៍ ។ | | ✓ | ✓ | ✓ | ✓ | ២,០០០ |
| | ▪ សម្របសម្រួលក្រុមការងារបច្ចេកទេសសម្រាប់ រៀបចំផែនការនិងការកាត់បន្ថយភាពក្រីក្រ ។ | | ✓ | ✓ | ✓ | ✓ | |
| | ▪ សហប្រតិបត្តិការណ៍អនុវត្ត *សូចនាករត្រួតពិនិត្យរួម* នៃក្រុមការងារបច្ចេកទេស សម្រាប់រៀបចំផែនការនិងការកាត់បន្ថយភាពក្រីក្រ | | ✓ | ✓ | ✓ | ✓ | |
| **គោលដៅទី៤ : រៀបចំ *ផយអជ* *២០១១-២០១៥* ទៅតាមពេលវេលាកំណត់សមស្រប** | | | | | | | |
| **ចំណុចដៅទី១០ : រៀបចំសកម្មភាពក្រសួងផែនការ ឆ្ពោះទៅមុខងារ របស់ *ផយអជ* ក្នុងអំឡុងពេល នៃការអនុវត្តផែនការយុទ្ធសាស្ត្ររបស់ក្រសួងផែនការ** | **១០.១ ធ្វើការបន្សីជាថ្មីបណ្តុំសកម្មភាពរបស់ក្រសួងផែនការ ជាមួយតួនាទីរបស់ *ផយអជ*** | | | | | | |
| | ▪ លុបចេញសកម្មភាពទាំងឡាយណាដែលពុំមានជាអាទិភាពរបស់ *ផយអជ* | | | | ✓ | ✓ | |
| | ▪ អភិវឌ្ឍសមត្ថភាព ដើម្បីអនុវត្តសកម្មភាពទាំងឡាយណាដែលមានសារសំខាន់ ដល់ *ផយអជ* ហើយពេលបច្ចុប្បន្ននេះ ពុំបានដំណើរការក្នុងអគ្គនាយកដ្ឋាន ផែនការ ក្រសួងផែនការ (ឧ. សហការជាមួយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ កសាងសមត្ថភាពដើម្បីវិភាគក្របខ័ណ្ឌម៉ាក្រូសេដ្ឋកិច្ចដែលស្របគ្នានឹង *ផយអជ*) | | | ✓ | ✓ | ✓ | |
| | ▪ ប៉ាន់ស្មានលទ្ធផលការអនុវត្ត *ផយអជ ២០០៦-២០១០* និងរៀបចំ *ផយអជ ២០១១-២០១៥* | | | | ✓ | ✓ | |
| | ▪ ប្រជុំរៀបចំ *ផយអជ ២០១១-២០១៥* | | | | ✓ | ✓ | ២០,០០០ |
| | ▪ រៀបចំសិក្ខាសាលផ្តល់យោបល់លើ *ផយអជ ២០១១-២០១៥* | | | | ✓ | ✓ | ៦០,០០០ |

| គោលដៅ/ចំណុចដៅ | សកម្មភាព | ពេលវេលាអនុវត្ត | | | | | ថវិកាប៉ាន់ស្មាន (ដុល្លា) |
|---|---|---|---|---|---|---|---|
| | | ២០០៦ | ២០០៧ | ២០០៨ | ២០០៩ | ២០១០ | |
| | **១០.២ ពង្រឹងយន្តការសហប្រតិបត្តិការអន្តរជាតិក្នុងក្រសួងផែនការ** | | | | | | |
| | ▪ ពិនិត្យឡើងវិញនូវសហប្រតិបត្តការទ្វេនិងពហុភាគី និងផ្តល់នូវអនុសាសន៍គោលនយោបាយ | | ✓ | ✓ | ✓ | ✓ | |
| | **១០.៣ ត្រួតពិនិត្យប្រចាំឆ្នាំ ពីការអនុវត្តផែនការយុទ្ធសាស្ត្រក្រសួងផែនការ** | | | | | | |
| | ▪ ពិនិត្យមើលលទ្ធផលប្រចាំឆ្នាំរបស់ *ផយផក* | | | ✓ | ✓ | ✓ | ៤៤,០០០ |
| **ចំណុចដៅទី១១ : *ផយអជ* ត្រូវបានឡាយព្រហស្តលេខា ដោយព្រះករុណាព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា នៅចុងខែធ្នូ ឆ្នាំ២០១០** | **១១.១ បង្កើតតួនាទី ការទទួលខុសត្រូវ កម្មវិធីនៃដំណើរការ និងធនធាន (ធនធានមនុស្ស ការអភិវឌ្ឍសមត្ថភាពផ្សេងទៀតក្នុងក្រសួងផែនការ ជំនួយបច្ចេកទេស) ដែលចាំបាច់សម្រាប់ការរៀបចំ *ផយអជ* លើកក្រោយ (ការរៀបចំ *ផយអជ* នឹងចាប់ផ្តើមនៅពាក់កណ្តាលឆ្នាំ២០០៨)** | | | | | | |
| | ▪ បង្កើតតួនាទី ការទទួលខុសត្រូវ កម្មវិធីនៃដំណើរការ និងធនធាន (ធនធានមនុស្ស ការអភិវឌ្ឍសមត្ថភាពផ្សេងទៀតក្នុងក្រសួងផែនការ ជំនួយបច្ចេកទេស) ដែលចាំបាច់សម្រាប់ការរៀបចំ *ផយអជ* លើកក្រោយ | | | | ✓ | ✓ | |
| | ▪ បោះពុម្ពផ្សាយ *ផយអជ ២០១១-២០១៥* | | | | | ✓ | ៦៥,០០០ |
| | ▪ សិក្ខាសាលាផ្សព្វផ្សាយ *ផយអជ ២០១១-២០១៥* | | | | | ✓ | ១៥,០០០ |
| **គោលដៅទី៥ : លើកកំពស់ការធ្វើផែនការអភិវឌ្ឍន៍មូលដ្ឋាន** | | | | | | | |
| **ចំណុចដៅទី១២ : *ធ្វើឱ្យប្រសើរនូវសមត្ថភាពមន្ត្រីផែនការខេត្ត*** | **១២.១**ផ្តល់ការណែនាំស្តីពីដំណើរការផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ ដល់ខេត្ត-ក្រុង | ✓ | ✓ | ✓ | ✓ | ✓ | |
| | **១២.២** លើកកំពស់សមត្ថភាពដល់មន្ត្រីផែនការខេត្ត-ក្រុងស្តីពីការគ្រប់គ្រងទិន្នន័យមូលដ្ឋានឃុំ/សង្កាត់ | ✓ | ✓ | ✓ | ✓ | ✓ | ១៥០,០០០ |
| | **១២.៣** លើកកំពស់សមត្ថភាពដល់មន្ត្រីផែនការខេត្ត-ក្រុងស្តីពីការរៀបចំនិងវិភាគឃុំ/សង្កាត់ និងស្ថានភាពខ័ណ្ឌ/ស្រុក | ✓ | ✓ | ✓ | ✓ | ✓ | ៨១,០០០ |
| | **១២.៤** លើកកំពស់សមត្ថភាពដល់មន្ត្រីផែនការខេត្ត-ក្រុងស្តីពីការគាំទ្រការរៀបចំផែនការយុទ្ធសាស្ត្រអភិវឌ្ឍ ឃុំ/សង្កាត់ | ✓ | ✓ | ✓ | ✓ | ✓ | ១៥០,០០០ |

| គោលដៅ/ចំណុចដៅ | សកម្មភាព | ពេលវេលាអនុវត្ត | | | | | ថវិកាប៉ាន់ស្មាន (ដុល្លា) |
|---|---|---|---|---|---|---|---|
| | | ២០០៦ | ២០០៧ | ២០០៨ | ២០០៩ | ២០១០ | |
| | **១២.៥** លើកកំពស់សមត្ថភាពដល់មន្ត្រីផែនការខេត្ត-ក្រុងស្តីពីការ គ្រប់គ្រងផែនការអភិវឌ្ឍន៍ទិន្នន័យ មូលដ្ឋានឃុំ/សង្កាត់ | ✓ | ✓ | ✓ | ✓ | ✓ | |
| | **១២.៦** លើកកំពស់សមត្ថភាពដល់មន្ត្រីផែនការខេត្ត-ក្រុងស្តីពីការគាំទ្រនិងរៀបចំដំណើរការសិក្ខាសាលាសមាហរណកម្មស្រុក | ✓ | ✓ | ✓ | ✓ | ✓ | ១៥០,០០០ |
| | **១២.៧** លើកកំពស់សមត្ថភាពដល់មន្ត្រីផែនការខេត្ត-ក្រុងស្តីពីការត្រួតពិនិត្យនិងវាយតម្លៃការអនុវត្តដំណើរការផែនការខេត្ត និងដំណើរការផែនការឃុំ/សង្កាត់ | ✓ | ✓ | ✓ | ✓ | ✓ | ១៦០,០០០ |
| **ចំណុចដៅទី១៣ :** ***លើកកំពស់សមត្ថភាព មន្ត្រីផែនការស្រុក*** | **១៣.១** ផ្តល់ការណែនាំផែនការអភិវឌ្ឍន៍ឃុំ/សង្កាត់ | ✓ | ✓ | ✓ | ✓ | ✓ | |
| | **១៣.២** វិភាគស្ថានភាពឃុំ/សង្កាត់ | ✓ | ✓ | ✓ | ✓ | ✓ | |
| | **១៣.៣** ចូលរួមនិងគាំទ្រដំណើរការផែនការឃុំ/សង្កាត់ | ✓ | ✓ | ✓ | ✓ | ✓ | ១៥០,០០០ |
| **ចំណុចដៅទី១៤ :** ***ពង្រឹងមត្ថភាព ក្រុមការងារថ្នាក់ជាតិស្តីពីដំណើរការផែនារមូលដ្ឋាន*** | **១៤.១** លើកកំពស់សមត្ថភាពក្រុមការងារជាតិស្តីពីទស្សនាទាននៃការអនុវត្តល្អក្នុងដំណើរការផែនការមូលដ្ឋាន | ✓ | ✓ | ✓ | ✓ | ✓ | ៤០,០០០ |
| | **១៤.២** ធ្វើឱ្យប្រសើរឡើងនិងគាំទ្រការរៀបចំនិងដំណើរការអនុវត្តផែនការមូលដ្ឋាន | ✓ | ✓ | ✓ | ✓ | ✓ | ១២០,០០០ |
| | **១៤.៣** សហការជាមួយភាគីពាក់ព័ន្ធដើម្បីគាំទ្រគោលនយោបាយខេត្ត/ក្រុង និងឃុំ/សង្កាត់ជាមួយបរិបទវិមជ្ឈការ និងវិសហមជ្ឈការ | ✓ | ✓ | ✓ | ✓ | ✓ | |
| **គោលដៅទី ៦: សម្របសម្រួល និងធ្វើឱ្យប្រសើរឡើងនូវប្រព័ន្ធស្ថិតិជាតិ និងសមត្ថភាពស្ថាប័នវិទ្យាស្ថានជាតិស្ថិតិ** | | | | | | | |
| **គោលដៅទី ១៥:** ***ពង្រឹងអភិបាលកិច្ចស្ថិតិ*** | **១៥.១** បរិយាយ និងអនុម័តក្របខណ្ឌបទប្បញ្ញត្តិស្ថិតិ | ✓ | ✓ | | | | ៨០០,០០០ |
| | ▪ អនុក្រឹត្យស្ថិតិផ្លូវការដែលបានចាត់តាំង ឯកភាពដោយក្រុមប្រឹក្សាស្ថិតិ ជូនគណៈរដ្ឋមន្ត្រីធ្វើការអនុម័ត | ✓ | ✓ | | | | |
| | ▪ អង្គភាពស្ថិតិនៅតាមបណ្តាក្រសួងប្រតិបត្តិតាមស្ថិតិផ្លូវការដែលបានចាត់តាំង ហើយផ្ញើជូនវិទ្យាស្ថានជាតិស្ថិតិ | ✓ | ✓ | ✓ | | | |
| | ▪ រៀបចំនីតិវិធីការពារការសម្ងាត់នៃទិន្នន័យ និងប្តឹងអ្នកដែលមិនបានផ្តល់ ទិន្នន័យផ្លូវការតាមការស្នើសុំ | ✓ | ✓ | ✓ | | | |

| គោលដៅ/ចំណុចដៅ | សកម្មភាព | ពេលវេលាអនុវត្ត | | | | | ថវិកាប៉ាន់ស្មាន (ដុល្លា) |
|---|---|---|---|---|---|---|---|
| | | ២០០៦ | ២០០៧ | ២០០៨ | ២០០៩ | ២០១០ | |
| ***គោលដៅទី ១៦: ធ្វើឱ្យប្រសើរឡើងនូវការ សម្របសម្រួលទូទាំងប្រព័ន្ធស្ថិតិ*** | **១៦.១** ប្រជុំក្រុមប្រឹក្សាស្ថិតិរៀងរាល់ ៦ ខែម្តង និងគណៈកម្មាធិការសម្របសម្រួលស្ថិតិរៀងរាល់ ៣ ខែម្តង និងសម្របសម្រួលបទដ្ឋាន និងនីតិវិធី | ✓ | ✓ | ✓ | ✓ | ✓ | ១០,០០០ |
| | ▪ រៀបចំបទដ្ឋានស្ថិតិជាតិ និងការផ្សព្វផ្សាយ និងបើកទូលាយក្នុងការពិគ្រោះ ជាមួយអ្នកផ្តល់ទិន្នន័យ និងអ្នកប្រើប្រាស់ទិន្នន័យ | ✓ | ✓ | ✓ | | | |
| **គោលដៅទី ៧: ប្រព័ន្ធស្ថិតិជាតិដែលទាន់ពេលវេលា មានទំនាក់ទំនងគ្នា និងមានការឆ្លើយតប** | | | | | | | |
| ***ចំណុចដៅទី ១៧: ធ្វើឱ្យប្រសើរឡើងនូវសេវាស្ថិតិ ទំហំស្ថិតិ និងនិយមន័យទិន្នន័យថ្នាក់ជាតិ របស់វិទ្យាស្ថានជាតិស្ថិតិ*** | **១៧.១** ធ្វើជំរឿនទូទៅនូវប្រជាជន ឆ្នាំ២០០៨ | ✓ | ✓ | ✓ | ✓ | ✓ | ៦,០០០,០០០ |
| | **១៧.២** ទិន្នន័យ និងលទ្ធផលជំរឿននឹងត្រូវបានផ្សព្វផ្សាយទូលំទូលាយ តាមរយៈ គេហទំព័រ CDROM និងសៀវភៅស្ថិតិប្រចាំឆ្នាំ | ✓ | ✓ | ✓ | ✓ | ✓ | ២៥,០០០ |
| | **១៧.៣** បន្តធ្វើការអង្កេតគ្រួសារ ដើម្បីប៉ាន់ស្មានការចំណាយឯកជនសំរាប់ គណនេយ្យជាតិ និងប៉ាន់ស្មានអត្រាប្រចាំឆ្នាំនៃបន្ទាត់ភាពក្រីក្រ | ✓ | ✓ | ✓ | ✓ | ✓ | ២,១០០,០០០ |
| | **១៧.៤** បោះពុម្ពទិន្នន័យគណនេយ្យជាតិ ប្រចាំត្រីមាស និងប្រចាំឆ្នាំ | ✓ | ✓ | ✓ | ✓ | ✓ | ១២៥,០០០ |
| | **១៧.៥** សន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់ | ✓ | ✓ | ✓ | ✓ | ✓ | ២៥០,០០០ |
| | **១៧.៦** សន្ទស្សន៍ផលិតផលកសិកម្ម ឧស្សាហកម្ម និងថ្លៃលក់រាយ | ✓ | ✓ | ✓ | ✓ | ✓ | ៥៥០,០០០ |
| | **១៧.៧** ស្ថិតិកម្លាំងពលកម្ម និងថ្លៃពលកម្ម | ✓ | ✓ | ✓ | ✓ | ✓ | ២០០,០០០ |
| | **១៧.៨** បោះពុម្ពការប៉ាន់ស្មានអត្រាប្រចាំឆ្នាំនៃភាពក្រីក្រ | | ✓ | ✓ | ✓ | ✓ | ៨០,០០០ |
| | **១៧.៩** សន្ទស្សន៍ថ្លៃផលិតករ និងសំភារៈកសិកម្ម | | ✓ | ✓ | ✓ | ✓ | ២២៥,០០០,០០ |
| | **១៧.១០** អង្កេតសេដ្ឋកិច្ច សង្គមកិច្ច ប្រចាំ ៥ ឆ្នាំ | | | | ✓ | ✓ | ១,៤០០,០០០ |
| | **១៧.១១** អង្កេតសហគ្រាស | ✓ | ✓ | ✓ | ✓ | ✓ | ១,៥០០,០០០ |

| គោលដៅ/ចំណុចដៅ | សកម្មភាព | ពេលវេលាអនុវត្ត | | | | | ថវិកាប៉ាន់ស្មាន (ដុល្លា) |
|---|---|---|---|---|---|---|---|
| | | ២០០៦ | ២០០៧ | ២០០៨ | ២០០៩ | ២០១០ | |
| | **១៧.១២** អង្កេតប្រជាសាស្ត្រ និងសុខភាព ឆ្នាំ ២០១០ | | | | ✓ | ✓ | ១,២០០,០០០ |
| | **១៧.១៣** ប្រមូលទិន្នន័យសេដ្ឋកិច្ច និងសង្គមកិច្ច | ✓ | ✓ | ✓ | ✓ | ✓ | ៧៥០,០០០ |
| | **១៧.១៤** ដំណើរការទិន្នន័យ CAMinfo | ✓ | ✓ | ✓ | ✓ | ✓ | ២៥០,០០០ |
| | **១៧.១៥** ជំរឿនកសិកម្ម | | | | ✓ | ✓ | ៣០០,០០០ |
| **គោលដៅទី ៨: ធ្វើឱ្យប្រសើរឡើង ផ្សព្វផ្សាយ និងបង្កើនការប្រើប្រាស់ស្ថិតិផ្លូវការ** | | | | | | | |
| **ចំណុចដៅទី ១៨:** ***បង្កើនការទទួលបានទូវ ស្ថិតិផ្លូវការជាតិ*** | **១៨.១** បង្កើតឃ្លាំងទិន្នន័យស្ថិតិជាតិ | ✓ | ✓ | ✓ | | | ១០០,០០០ |
| | **១៨.២** ការទទួលបានទិន្នន័យដែលមានក្នុងឃ្លាំងទិន្នន័យស្ថិតិជាតិ តាមរយៈ កម្មវិធី Superstar និង CAMinfo និងមជ្ឈមណ្ឌលអ្នកប្រើប្រាស់ទិន្នន័យ | ✓ | ✓ | ✓ | | | ២៥០,០០០ |
| | **១៨.៣** បង្កើនការផ្សព្វផ្សាយម៉េតាទិន្នន័យ និងរបាយការណ៍ តាមរយៈវេបសាយ របស់វិទ្យាស្ថានជាតិស្ថិតិ | ✓ | ✓ | ✓ | | | ១០០,០០០ |
| **ចំណុចដៅទី ១៩:** ***បង្កើនការយល់ដឹងនៃទិន្នន័យ ស្ថិតិ និងការប្រើប្រាស់ និងណែនាំការបង្កើត គោលនយោបាយ ចំណុចដៅ និងអាទិភាព*** | **១៩.១** ពង្រីកបណ្តាញមូលដ្ឋានរបស់វិទ្យាស្ថានជាតិស្ថិតិ ដល់អង្គភាពស្ថិតិនៅតាម បណ្តាក្រសួង ដោយផ្តល់ Internet ដើម្បីអាចទទួលបានពីឃ្លាំងទិន្នន័យស្ថិតិជាតិ | | ✓ | ✓ | | | ២០០,០០០ |
| | **១៩.២** បណ្តុះបណ្តាលមន្ត្រីតាមបណ្តាក្រសួង និងអង្គការក្រៅរដ្ឋាភិបាលនានា អំពីការប្រើប្រាស់កម្មវិធី Superstar និង CAMinfo 3 | ✓ | ✓ | ✓ | | | ១៦០,០០០ |
| | **១៩.៣** ជ្រើសរើសមន្ត្រី និងបណ្តុះបណ្តាល សម្រាប់នាយកដ្ឋានវិភាគស្ថិតិ នៅវិទ្យាស្ថានជាតិស្ថិតិ | ✓ | ✓ | ✓ | | | ៣០០,០០០ |

ឧបសម្ព័ន្ធ ២

# បញ្ជីឈ្មោះអ្នកចូលរួមសិក្ខាសាលារបស់ក្រសួងផែនការដើម្បីពិភាក្សាពីការរៀបចំ ផយផត (ក្រុងព្រះសីហនុ ខែតុលា ឆ្នាំ ២០០៦)

## តំណាងក្រសួងផែនការ

- ឯកឧត្តម អ៊ូ ឱហាត — រដ្ឋលេខាធិការ ក្រសួងផែនការ
- ឯកឧត្តម ទូន ថាវរ: — អគ្គនាយកអគ្គនាយដ្ឋានផែនការ ក្រសួងផែនការ
- លោកស្រី ហ៊ាង សៀកលី — អគ្គនាយករងផែនការ ក្រសួងផែនការ
- លោកស្រី ខៀវ បូរី — អគ្គនាយករងផែនការ ក្រសួងផែនការ
- លោក ជា ចាន់ទុំ — ប្រធាននាយកដ្ឋានផែនការសង្គមកិច្ច ក្រសួងផែនការ
- លោក ថេង បញ្ញាធន — ប្រធាននាយកដ្ឋានផែនការវិនិយោគ ក្រសួងផែនការ
- លោក វី ហៀង — ប្រធាននាយកដ្ឋាន វិទ្យាស្ថានជាតិស្ថិតិ ក្រសួងផែនការ
- លោក ម៉ម ម៉ារ៉ាឌី — ប្រធាននាយកដ្ឋានផែនការទូទៅ ក្រសួងផែនការ
- លោក ហួយ សិទ្ធិគុណ — អនុប្រធាននាយកដ្ឋានផែនការសេដ្ឋកិច្ច ក្រសួងផែនការ
- លោក រ៉េត រ៉ុងរក្សា — អនុប្រធាននាយកដ្ឋានទំនាក់ទំនងអន្តរជាតិ ក្រសួងផែនការ
- លោក ប៉ូច សុវណ្ណឌី — អនុប្រធាននាយកដ្ឋានផែនការទូទៅ ក្រសួងផែនការ
- លោកស្រី ជូ ពុទ្ធានី — អនុប្រធាននាយកដ្ឋានផែនការសង្គមកិច្ច ក្រសួងផែនការ
- លោក វ៉ា សុផល — អនុប្រធានការិយាល័យ នាយកដ្ឋានផែនការសង្គមកិច្ច ក្រសួងផែនការ
- បណ្ឌិត Hildegard LINGNAU ទីប្រឹក្សា ក្រសួងផែនការ

## តំណាងដៃគូអភិវឌ្ឍន៍ក្រៅប្រទេស

- Dr. Tim CONWAY — ធនាគារពិភពលោក
- លោក ហុង សុខ ឃាង — កម្មវិធីអភិវឌ្ឍន៍អង្គការសហប្រជាជាតិ
- លោក សុខ វណ្ណា — កម្មវិធីសហប្រជាជាតិសម្រាប់ប្រជាជន

**ឧបសម្ព័ន្ធ ៣**

## អនុក្រឹត្យលេខ ៥៥ អនក្រ.បក ស្តីពីការរៀបចំ និងប្រព្រឹត្តទៅនៃក្រសួងផែនការ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ** ៥៥ អនក្រ.បក

### អនុក្រឹត្យ
### ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅ
### របស់ក្រសួងផែនការ

### រាជរដ្ឋាភិបាលកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ១៩៩៣ ស្តីពីការតែងតាំងនាយករដ្ឋមន្ត្រីទី១ និងនាយករដ្ឋមន្ត្រីទី២
- បានឃើញព្រះរាជក្រឹត្យចុះថ្ងៃទី០១ ខែវិច្ឆិកា ឆ្នាំ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១០៩៤/៨៣ ចុះថ្ងៃទី២៤ ខែតុលា ឆ្នាំ១៩៩៤ និងព្រះរាជក្រឹត្យលេខ នស/រកត/១០៩៤/៩០ ចុះថ្ងៃទី៣១ ខែតុលា ឆ្នាំ១៩៩៤ ស្តីពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១១ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ស្តីពីការបង្កើតក្រសួងផែនការ
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/០៨៩៧/១៤៧ ចុះថ្ងៃទី ០៧ ខែសីហា ឆ្នាំ១៩៩៧ ស្តីពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា

- បានឃើញអនុក្រឹត្យលេខ ២០ អនក្រ.បក ចុះថ្ងៃទី៣០ ខែមេសា ឆ្នាំ១៩៩៦ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួង និងរដ្ឋលេខាធិការដ្ឋាន
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងផែនការ
- តាមការឯកភាពរបស់គណៈរដ្ឋមន្ត្រីនាសម័យប្រជុំថ្ងៃទី១៨ ខែកញ្ញា ឆ្នាំ១៩៩៧

## សំរេច :

## ជំពូក ១

## បទបញ្ញត្តិទូទៅ

**មាត្រា ១:** អនុក្រឹត្យនេះរៀបចំអង្គភាពនានារបស់ក្រសួងផែនការ និងកំណត់បេសកកម្មរបស់ក្រសួង និងមុខការនៃបណ្តាអគ្គនាយកដ្ឋាន និង នាយកដ្ឋាននានា ។

## ជំពូក ២

## បេសកកម្ម និង រចនាសម្ព័ន្ធ

**មាត្រា ២:** ក្រសួងផែនការត្រូវបានរាជរដ្ឋាភិបាលកម្ពុជាប្រគល់ឱ្យទទួលបន្ទុកបេសកកម្មដឹកនាំ និងគ្រប់គ្រងលើ វិស័យផែនការស្តីពីការអភិវឌ្ឍន៍សេដ្ឋកិច្ច សង្គមកិច្ច និងលើការអនុវត្តន៍ស្ថិតិនៃព្រះរាជាណាចក្រកម្ពុជា។

**មាត្រា ៣:** ក្រសួងផែនការមានមុខងារនិងភារកិច្ចដូចតទៅ :

- ធ្វើសេនាធិការរបស់រាជរដ្ឋាភិបាលក្នុងការរៀបចំ ទស្សនាទាន យុទ្ធសាស្ត្រ គោលនយោបាយ និងកំណត់អាទិភាពសំរាប់ការអភិវឌ្ឍន៍ប្រទេសជាតិដោយឈរលើមូលដ្ឋាននៃការបង្កើតឱ្យមាននិរន្តរភាព និង តុល្យភាពរវាងកិច្ចអភិវឌ្ឍន៍ និងសមភាព យុត្តិធម៌ក្នុងសង្គម រវាងកិច្ចអភិវឌ្ឍន៍ខាងសេដកិច្ច និងកិច្ចអភិវឌ្ឍន៍ខាងសង្គមកិច្ចនិងវប្បធម៌ រវាងទីក្រុងនិងជនបទ រវាងការធ្វើអាជីវកម្មនិងការកកើតឡើងវិញនៃធនធានធម្មជាតិ និងរវាងកិច្ចអភិវឌ្ឍន៍ និងការការពារបរិស្ថាន ។
- ដឹកនាំនិងគ្រប់គ្រងវិធីសាស្ត្រ និងបែបបទក្នុការរៀបចំផែនការ ស្តីពីការអភិវឌ្ឍន៍សេដ្ឋកិច្ច សង្គមកិច្ចតាមប្រព័ន្ធវិមជ្ឈការក្នុងក្របខ័ណ្ឌទូទាំងប្រទេស។
- រៀបចំផែនការ និងកម្មវិធីជាតិសំរាប់កិច្ចអភិវឌ្ឍន៍រយៈពេលវែង មធ្យម និងរយៈពេលខ្លីដោយសំរបសំរួលជាមួយបណ្តាក្រសួង ស្ថាប័នដែលពាក់ព័ន្ធ ដើម្បីឱ្យផែនការនិងកម្មវិធីជាតិទាំងនោះស៊ីសង្វាក់គ្នារវាងបណ្តាផ្នែកនិងសាខាសេដ្ឋកិច្ច សង្គមកិច្ច ព្រមទាំងខេត្ត ក្រុង និងតំបន់នានាក្នុងក្របខ័ណ្ឌទូទាំងប្រទេស ។

- តាមដានត្រួតពិនិត្យ ការអនុវត្តន៍ផែនការ កម្មវិធីជាតិ និងបណ្តាគំរោងពីគ្រប់ផ្នែកទាំងអស់ ហើយវាយតំលៃលទ្ធផលនៃការអនុវត្តន៍ និងលើកឡើងពីវិធានការកែតំរូវផែនការកម្មវិធីជាតិទាំងនោះក្នុងករណីចាំបាច់ ។
- រួមជាមួយក្រសួងនិងស្ថាប័នពាក់ព័ន្ធដើម្បីរៀបចំយុទ្ធសាស្ត្រ គោលនយោបាយ និងកំណត់អាទិភាពក្នុងការវិនិយោគទាំងឯកជន និងសាធារណៈ ដើម្បីប្រើប្រាស់ឱ្យអស់លទ្ធភាព និងមានប្រសិទ្ធិភាពនូវសក្តានុពលនៃប្រភពធនធានទាំងក្នុង និងក្រៅប្រទេស ។
- សហការជាមួយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដើម្បីកំណត់និងបែងចែកទុនវិនិយោគសាធារណៈប្រចាំឆ្នាំ ។
- រួមជាមួយក្រសួងនិងស្ថាប័នពាក់ព័ន្ធដើម្បីរៀចំយុទ្ធសាស្ត្រគោលនយោបាយ និងកំណត់អាទិភាពក្នុងផែនការសហប្រតិបត្តិការសេដ្ឋកិច្ច-សង្គមកិច្ច វប្បធម៌និងវិទ្យាសាស្ត្របច្ចេកទេសជាមួយបរទេសឱ្យស៊ីសង្វាក់គ្នាជាមួយនឹងទិសដៅនិងគោលនយោបាយអភិវឌ្ឍន៍ជាតិ ។
- រួមជាមួយក្រសួងនិងស្ថាប័នពាក់ព័ន្ធ ដើម្បីរៀបចំគោលនយោបាយ ប្រជាសាស្ត្រ និងផែនការសកម្មភាពស្តីពី ការបែងចែកកំលាំងពលកម្មសង្គមឱ្យមានតុល្យភាព ធានាដល់កិច្ចអភិវឌ្ឍន៍សេដ្ឋកិច្ច-សង្គមកិច្ច និងការពារជាតិ ។
- ធ្វើការអង្កេត និងការសិក្សាស្រាវជ្រាវដែលចាំបាច់ក្នុងការបំពេញមុខងារ និងភារកិច្ចរបស់ខ្លួន ។
- គ្រប់គ្រងព័ត៌មានស្ថិតិសេដ្ឋកិច្ច សង្គមកិច្ច និងប្រជាសាស្ត្រក្នុងក្របខ័ណ្ឌទូទាំងប្រទេស ។
- គ្រប់គ្រងប្រព័ន្ធស្ថិតិជាតិកម្ពុជាតាមការចងក្រង ណែនាំអនុវត្តវិធីប្រើចំណាត់ថ្នាក់ស្ថិតិ និងគំរូតារាងឯកភាព ក្នុងការបំពេញនិងការប្រមូលយកព័ត៌មានស្ថិតិ ណែនាំអនុវត្តវិធីសាស្ត្រ និងរូបមន្តគណនាទិន្នន័យស្ថិតិឯកភាពក្នុងទូទាំងប្រទេស ។
- រៀបចំវិធីសាស្ត្រធ្វើជំរឿន ធ្វើអង្កេត និងអនុវត្តការធ្វើជំរឿន ការធ្វើអង្កេតប្រជារាស្ត្រសេដ្ឋកិច្ច-សង្គមកិច្ចកម្ពុជា ។
- ផ្តល់ជំនួយខាងផ្នែកបច្ចេកទេសនិងវិធីសាស្ត្រ ឬអនុវត្តការធ្វើជំរឿននិងអង្កេតក្នុងវិស័យ និងប្រធានបទនានាតាមសំណូមពររបស់អ្នកប្រើប្រាស់ទិន្នន័យស្ថិតិ ។
- ចងក្រងគណនេយ្យជាតិ សន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់និងសេវាកម្ម និងកម្រងតួលេខស្ថិតិរបស់កម្ពុជាឡើងទាត់ជាប្រចាំ ។
- សហការដោះដូរព័ត៌មានជាមួយអង្គភាពស្ថិតិជាតិនៃប្រទេសក្នុងតំបន់ក្នុងពិភពលោក និងបណ្តាអង្គការជាតិ អង្គការអន្តរជាតិ ។
- បំពេញមុខងារនិងភារកិច្ចចាំបាច់ផ្សេងទៀតតាមការទុកចិត្តនិងការប្រគល់សិទ្ធិពីនាយករដ្ឋមន្ត្រី ។

**មាត្រា ៩:** ក្រសួងផែនការមានរចនាសម្ព័ន្ធដូចតទៅ :

ក. នៅថ្នាក់កណ្តាល

- អគ្គនាយកដ្ឋានផែនការរួមមាន :

- ❖ នាយកដ្ឋានផែនការទូទៅ
- ❖ នាយកដ្ឋានផែនការសេដ្ឋកិច្ច
- ❖ នាយកដ្ឋានផែនការសង្គមកិច្ច
- ❖ នាយកដ្ឋានផែនការវិនិយោគ
- ❖ នាយកដ្ឋានទំនាក់ទំនងអន្តរជាតិ

- វិទ្យាស្ថានជាតិស្ថិតិដែលមានឋានានុក្រមស្មើថ្នាក់អគ្គនាយកដ្ឋានរួមមាន:
  - ❖ នាយកដ្ឋានស្ថិតិទូទៅ
  - ❖ នាយកដ្ឋានស្ថិតិសេដ្ឋកិច្ច
  - ❖ នាយកដ្ឋានស្ថិតិសង្គមកិច្ច
  - ❖ នាយកដ្ឋានប្រជាសាស្ត្រ ជំរឿន និងអង្កេត
- អគ្គាធិការដ្ឋាន
- ខុទ្ទកាល័យរដ្ឋមន្ត្រី
- នាយកដ្ឋានបុគ្គលិក
- នាយកដ្ឋានរដ្ឋបាលទូទៅ
- នាយកដ្ឋានផ្គត់ផ្គង់ និង ហិរញ្ញវត្ថុ

ខ. អង្គភាពមូលដ្ឋាន

មន្ទីរផែនការខេត្ត ក្រុង

អង្គការលេខរបស់ក្រសួងផែនការជាឧបសម្ព័ន្ធរបស់អនុក្រឹត្យនេះ ។

## ជំពូក ៣

## អគ្គនាយកដ្ឋានផែនការ

**មាត្រា ៥:** អគ្គនាយកដ្ឋានផែនការមានមុខងារអនុវត្តនូវរាល់បេសកកម្មរបស់ក្រសួងក្នុងការ :

- ធានាភាពស៊ីសង្វាក់គ្នាក្នុងកិច្ចអភិវឌ្ឍន៍សេដ្ឋកិច្ច-សង្គមកិច្ច ដោយសំរបសំរួលផែនការ កម្មវិធីនិងគំរោងអភិវឌ្ឍន៍តាមផ្នែកនិងសាខាសេដ្ឋកិច្ច ដែលរៀបចំឡើងដោយបណ្តាក្រសួង រដ្ឋលេខាធិការដ្ឋានស្ថប័នដែលពាក់ព័ន្ធ និងខេត្ត-ក្រុង ។
- តាមដានត្រួតពិនិត្យការអនុវត្តន៍ផែនការ និងកម្មវិធីជាតិ ដោយសហការជាមួយក្រសួង រដ្ឋលេខាធិការដ្ឋានស្ថាប័នដែលពាក់ព័ន្ធ និងខេត្ត ក្រុង ហើយធ្វើរបាយការណ៍បូកសរុប និងលើកយោបល់ជូនរដ្ឋមន្ត្រីដើម្បីរាយការណ៍ជូនរាជរដ្ឋាភិបាលពិនិត្យ សំរេច ។

- រៀបចំរបាយការណ៍ស្តីពីសភាពការណ៍សេដ្ឋកិច្ច-សង្គមកិច្ច ប្រចាំត្រីមាសទី១ ឆមាសទី១ ៩ខែដើមឆ្នាំ និងប្រចាំឆ្នាំជូនរាជរដ្ឋាភិបាល ដោយសំរបសំរួលជាមួយក្រសួងរដ្ឋលេខាធិការដ្ឋាន ស្ថាប័នដែលពាក់ព័ន្ធ ខេត្ត ក្រុង និងវិជ្ជាស្ថានជាតិស្ថិតិ ។

អគ្គនាយកដ្ឋានផែនការត្រូវដឹកនាំដោយអគ្គនាយកមួយរូប និងអមដោយអគ្គនាយករងមួយចំនួនជួយធ្វើការតាមការចាំបាច់ ។

អគ្គនាយកដ្ឋានផែនការមាននាយកដ្ឋានចំណុះចំនួន ៥ ដូចខាងក្រោម ហើយនាយកដ្ឋាននីមួយៗ ដឹកនាំដោយប្រធានមួយរូប និងអមដោយអនុប្រធានមួយចំនួនជួយធ្វើការតាមការចាំបាច់ ។

**មាត្រា ៦:** នាយកដ្ឋានផែនការទូទៅទទួលបន្ទុក :

- កសាងទស្សនាទាន យុទ្ធសាស្ត្រផែនការនិងកម្មវិធិអភិវឌ្ឍន៍សេដ្ឋកិច្ច-សង្គមកិច្ចជាតិរយៈពេលខ្លី មធ្យម និងរយៈពេលវែង ដោយសំរបសំរួលជាមួយនាយកដ្ឋាននានាចំណុះអគ្គនាយកដ្ឋានផែនការ
- វិភាគនិងព្យាករណ៍ពីស្ថានភាពរួមនៃការវិវត្តន៍ ខាងផ្នែកម៉ាក្រូសេដ្ឋកិច្ចនៅក្នុងប្រទេសព្រមទាំងលើកឡើងនូវយោបល់និងវិធានការចាំបាច់ ដើម្បីកែតំរង់ទិសដៅនៃការអភិវឌ្ឍន៍ប្រទេស ឱ្យបានទាន់ពេលវេលា ។
- រៀបចំយុទ្ធសាស្ត្រ គោលនយោបាយ និងផែនការក្នុងវិស័យម៉ាក្រូសេដ្ឋកិច្ចរួមមានគណនេយ្យជាតិ សារពើពន្ធ ជញ្ជីងទូទាត់ រូបិយវត្ថុ និងស្ថាប័នហិរញ្ញវត្ថុ ។

**មាត្រា ៧:** នាយកដ្ឋានផែនការសេដ្ឋកិច្ចទទួលបន្ទុក :

- វិភាគនិងព្យាករណ៍អំពីស្ថានភាពរួម នៃការវិវត្តន៍ខាងផ្នែកសេដ្ឋកិច្ចនានានៅក្នុងប្រទេស ព្រមទាំងលើកឡើងនូវយោបល់និងវិធានការចាំបាច់ដើម្បីកែតំរង់ទិដៅនៃការអភិវឌ្ឍន៍ប្រទេស ឱ្យបានទាន់ពេលវេលា ។
- រៀបចំយុទ្ធសាស្ត្រ គោលនយោបាយ និងផែនការក្នុងវិស័យសេដ្ឋកិច្ចនានារួមមានជាអាទិ៍ កសិកម្ម រុក្ខកម្ម នេសាទ ឧស្សាហកម្ម គមនាគមន៍ ដឹកជញ្ជូន ពាណិជ្ជកម្ម ទេសចរណ៍ សំណង់ និងបរិស្ថាន ។

**មាត្រា ៨:** នាយកដ្ឋានផែនការសង្គមកិច្ចទទួលបន្ទុក :

- វិភាគនិងព្យាកណ៍អំពីស្ថានភាពរួមនៃការវិវត្តន៍ខាងផ្នែកសង្គមកិច្ចនិងស្ថានភាពប្រជាសាស្ត្រ នៅក្នុងប្រទេស ព្រមទាំងលើកឡើងនូវយោបល់និងវិធានការចាំបាច់ដើម្បីកែតំរង់ទិសដៅនៃការអភិវឌ្ឍន៍ ឱ្យបានទាន់ពេលវេលា ។
- រៀបចំយុទ្ធសាស្ត្រ គោលនយោបាយ និងផែនការក្នុងវិស័យសង្គមកិច្ចរួមមាន ការងារប្រជាសាស្ត្រ អប់រំ បណ្តុះបណ្តាល អភិវឌ្ឍន៍ធនធានមនុស្ស អភិវឌ្ឍន៍សហគមន៍ ការកាត់បន្ថយភាពក្រីក្រ ផ្ទះសំបែង សុខាភិបាល អាហារូបត្ថម្ភ សង្គមកិច្ច-ការងារ វប្បធម៌ តួនាទីបុរសស្ត្រី សាសនា និងព័ត៌មាន ។

**មាត្រា ៩:** នាយកដ្ឋានផែនការវិនិយោគទទួលបន្ទុក :

- វិភាគនិងព្យាករណ៍អំពី ស្ថានភាពរួមនៃការវិវត្តន៍ ខាងផ្នែកវិនិយោគនៅក្នុងប្រទេស ទាំងវិនិយោគសាធារណៈ និងឯកជន ព្រមទាំងលើកឡើងនូវយោបល់និងវិធានការចាំបាច់ ដើម្បីតំរង់ទិសវិនិយោគឱ្យសមស្របតាមទិសដៅនៃការអភិវឌ្ឍន៍ប្រទេស ។
- រៀបចំយុទ្ធសាស្ត្រវិនិយោគរយៈពេលខ្លី មធ្យម និងវែង ។
- កំណត់អាទិភាពក្នុងការបែងចែកទុនតាមវិស័យ ។
- ពិនិត្យសេចក្តីព្រាងគំរោងវិនិយោគសាធារណៈរបស់បណ្តាក្រសួងនិងស្ថាប័ននានា ។
- រៀបចំកម្មវិធីវិនិយោគសាធារណៈប្រចាំឆ្នាំ ។
- ចូលរួមក្នុងគណៈកម្មការដេញថ្លៃលើគ្រប់គំរោងការងារវិនិយោគសាធារណៈ ។
- តាមដាននិងវាយតំលៃលទ្ធផលនៃការអនុវត្តន៍កម្មវិធីវិនិយោគសាធារណៈ ។

**មាត្រា ១០:** នាយកដ្ឋានទំនាក់ទំនងអន្តរជាតិទទួលបន្ទុក :

- វិភាគនិងព្យាករណ៍ពីស្ថានភាពរួមនៃការងារសហប្រតិបត្តិការសេដ្ឋកិច្ចជាមួយបរទេស អង្គការអន្តរ-ជាតិ និងអង្គការក្រៅរដ្ឋាភិបាល ព្រមទាំងលើកឡើងនូវយោបល់និងវិធានការចាំបាច់ ដើម្បីតំរង់ទិសការងារសហប្រតិបត្តិការសេដ្ឋកិច្ច-សង្គមកិច្ច វប្បធម៌និងវិទ្យាសាស្ត្របច្ចេកទេស ជាមួយបរទេសឱ្យស្របតាមទិសដៅនៃការអភិវឌ្ឍន៍ប្រទេស ។
- ធ្វើសហប្រតិបត្តិការផ្លាស់ប្តូរព័ត៌មាន និងសំរបសំរួលក្នុងក្រុមខ័ណ្ឌការងារផែនការអភិវឌ្ឍន៍សេដ្ឋកិច្ចសង្គមកិច្ចជាមួយបរទេសតាមការចាំបាច់ ។
- សំរបសំរួលការងារសហប្រតិបត្តិការសេដ្ឋកិច្ច-សង្គមកិច្ច វប្បធម៌និងវិទ្យាសាស្ត្របច្ចេកទេសជាមួយបរទេសផ្សេងទៀតតាមការចាំបាច់ និងតាមការប្រគល់ភារកិច្ចពីរាជរដ្ឋាភិបាល ជាអាទិ៍ដូចជា ការងារក្នុងក្របខ័ណ្ឌ នៃកិច្ចសហប្រតិបត្តិការសេដ្ឋកិច្ចរវាងបណ្តាប្រទេសក្នុងអនុតំបន់វិសាលភាពទន្លេមេគង្គ (GMS) ជាដើម ។

## ជំពូក ៤

## វិទ្យាស្ថានជាតិស្ថិតិ

**មាត្រា ១១:** វិទ្យាស្ថានជាតិស្ថិតិមានមុខងារអនុវត្តរាល់បេសកកម្មរបស់ក្រសួងក្នុងការធ្វើជំរឿន អង្កេតអំពីសេដ្ឋកិច្ច-សង្គមកិច្ចនិងប្រជាសាស្ត្រ ។ ចងក្រងនិងណែនាំវិធីប្រើប្រាស់ចំណោត់ថ្នាក់ស្ថិតិតារាងឯកភាព និងវិធីសាស្ត្រគណនាទិន្នន័យស្ថិតិប្រមែប្រមូល ចងក្រងនិងផ្សព្វផ្សាយទិន្នន័យស្ថិតិស្តីពីស្ថានភាពនៃការវិវត្តន៍ក្នុងផ្នែកសេដ្ឋកិច្ច សង្គមកិច្ចនៅក្នុងប្រទេស ។

សហការជាមួយអង្គភាពស្ថិតិជាតិនៃប្រទេសនានាក្នុងតំបន់ និងពិភពលោក ក្នុងការដោះដូរព័ត៌មានស្ថិតិ បណ្តុះបណ្តាលមន្ត្រីជំនាញការងារស្ថិតិដើម្បីការអភិវឌ្ឍន៍ប្រព័ន្ធស្ថិតិជាតិកម្ពុជា ។ វិទ្យាស្ថានជាតិស្ថិតិត្រូវដឹកនាំដោយនាយកមួយរូប ដែលតែងតាំងដោយព្រះរាជក្រឹត្យ និងនាយករងមួយចំនួនជួយធ្វើការតាមការចាំបាច់ ។

វិទ្យាស្ថានជាតិស្ថិតិមាននាយកដ្ឋានចំណុះចំនួយ ៤ ដូចខាងក្រោម ហើយនាយកដ្ឋាននីមួយៗដឹកនាំដោយប្រធានមួយរូបនិងអមដោយអនុប្រធានមួយចំនួនជួយធ្វើការតាមការចាំបាច់ ។

**មាត្រា ១៧:** នាយកដ្ឋានស្ថិតិទូទៅទទួលបន្ទុក :

- សំរបសំរួលទិន្នន័យស្ថិតិជាមួយនាយកដ្ឋាននានាចំណុះវិទ្យាស្ថានជាតិស្ថិតិ ដើម្បីចងក្រងចេញនូវគណនេយ្យជាតិរបស់កម្ពុជា ។
- ប្រមូលយកព័ត៌មានអំពីថ្លៃទំនិញប្រើប្រាស់ និងសេវាកម្ម តាមកាលកំណត់ និងចងក្រងសន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់ និងសេវាកម្ម ប្រចាំខែ ត្រីមាស ឆមាស ៩ខែដើមឆ្នាំ និងប្រចាំឆ្នាំរបស់កម្ពុជា ។
- ចងក្រង ផ្សព្វផ្សាយ និងណែនាំអនុវត្តដោយឯកភាពនូវចំណាត់ថ្នាក់ ព័ត៌មានស្ថិតិ បណ្តាតារាងគំរូ ប្រមូលយកព័ត៌មានស្ថិតិពីអង្គភាពរដ្ឋ ឯកជន គ្រឹះស្ថានសាធារណៈនានាសំរាប់ចងក្រងទិន្នន័យស្ថិតិជាតិ ។

**មាត្រា ១៨:** នាយកដ្ឋានស្ថិតិសេដ្ឋកិច្ចទទួលបន្ទុក :

- ប្រមូល ចងក្រងព័ត៌មានបឋមស្តីពីស្ថិតិកសិកម្ម វុក្ខកម្ម នេសាទ ស្ថិតិឧស្សាហកម្ម ពាណិជ្ជកម្ម ស្ថិតិសំណង់ ស្ថិតិគមនាគមន៍ ដឹកជញ្ជូន ស្ថិតិទេសចរណ៍ និងស្ថិតិបរិស្ថាន ។
- សិក្សា និងសហការជាមួយអង្គភាពពាក់ព័ន្ធ រៀបចំនិងធ្វើជំរឿន អង្កេត ប្រមូលចងក្រង និងវិភាគព័ត៌មានស្ថិតិកសិកម្ម វុក្ខកម្ម នេសាទ ស្ថិតិឧស្សាហកម្ម ពាណិជ្ជកម្ម ស្ថិតិសំណង់ ស្ថិតិគមនាគមន៍ ដឹកជញ្ជូន ស្ថិតិទេសចរណ៍ និងស្ថិតិបរិស្ថាន ។

**មាត្រា ១៩:** នាយកដ្ឋានស្ថិតិសង្គមកិច្ចទទួលបន្ទុក :

- ប្រមូលចងក្រងព័ត៌មានបឋមស្តីពីស្ថិតិសង្គមកិច្ច-ការងារ ស្ថិតិអប់រំសិក្សា ស្ថិតិសុខាភិបាល ស្ថិតិព័ត៌មាន និងស្ថិតិវប្បធម៌ ។

- សិក្សា និងសហការជាមួយអង្គភាពពាក់ព័ន្ធ រៀបចំនិងធ្វើជំរឿន អង្កេតប្រមូលចងក្រង និងវិភាគព័ត៌មានស្ថិតិសង្គមកិច្ច-ការងារ ស្ថិតិអប់រំសិក្សា ស្ថិតិសុខភិបាល ស្ថិតិព័ត៌មាន និងស្ថិតិវប្បធម៌ ។

**មាត្រា ១៥:** នាយកដ្ឋានស្ថិតិប្រជាសាស្ត្រ ជំរឿន អង្កេត ទទួលបន្ទុក :

- ធ្វើជំរឿន អង្កេត ប្រមូល ចងក្រង និងគ្រប់គ្រងស្ថិតិប្រជាសាស្ត្រ ។
- សហការធ្វើការរៀបចំ អនុវត្តការធ្វើជំរឿន អង្កេតតាមប្រធានបទនានា ក្នុងសំណូមពររបស់បណ្ដាអង្គភាព និងអ្នកប្រើប្រាស់ទិន្នន័យស្ថិតិ ។
- ធ្វើការបណ្ដុះបណ្ដាលបំពេញសមត្ថភាពជំនាញស្ថិតិ ពីថ្នាក់កណ្ដាលរហូតដល់មូលដ្ឋានតាមតំរូវការការងារ ។

## ជំពូក ៥

## អគ្គាធិការដ្ឋាន

**មាត្រា ១៦:** អគ្គាធិការដ្ឋានរបស់ក្រសួងផែនការទទួលបន្ទុក :

- ធ្វើអធិការកិច្ចជាប្រចាំទៅលើគ្រប់អង្គភាពក្រោមឱវាទក្រសួងផែនការ ។
- ធ្វើរបាយការណ៍ជូនរដ្ឋមន្ត្រី ពីការប្រព្រឹត្តិទៅរបស់អង្គភាពដែលបានធ្វើអធិការកិច្ចហើយនោះនិងពីមធ្យោបាយកែលំអការប្រព្រឹត្តិទៅរបស់អង្គភាពទាំងនេះ ។
- ប្រតិបត្តិភារកិច្ចតាមកាលដែលរដ្ឋមន្ត្រីបានប្រគល់ការទុកចិត្ត ។

អគ្គាធិការដ្ឋានដឹកនាំដោយអគ្គាធិការមួយរូប អមដោយអគ្គាធិការរងមួយ ឬច្រើនរូបជួយធ្វើការទៅតាមការចាំបាច់ ។

## ជំពូក ៦

## ខុទ្ទកាល័យរដ្ឋមន្ត្រី

**មាត្រា ១៧:** ខុទ្ទកាល័យរដ្ឋមន្ត្រីទទួលបន្ទុកបេសកកម្មទាំងឡាយដែលកំណត់តាមបទបញ្ញត្តិនៃអនុក្រឹត្យលេខ ២០ អនក្រ.បក ចុះថ្ងៃទី ៣០ ខែមេសា ឆ្នាំ ១៩៩៦ ដូចមានយោងក្នុងមូលបទខាងលើ ស្ដីពី ការរៀបចំនិងការប្រព្រឹត្តិទៅរបស់ក្រសួង និងរដ្ឋលេខាធិការដ្ឋាន ។

# ជំពូក ៧

# ការងាររដ្ឋបាល និង ហិរញ្ញវត្ថុ

**មាត្រា ១៨:** នាយកដ្ឋានរដ្ឋបាលទូទៅទទួលបន្ទុក :

- សំរបសំរួលសកម្មភាពគ្រប់ផ្នែករបស់ក្រសួងនៅថ្នាក់កណ្តាល និងរវាងថ្នាក់កណ្តាល និងអង្គភាពមូលដ្ឋានក្រោមឱវាទ ។
- គ្រប់គ្រង និងចរាចរឯកសាររដ្ឋបាលផ្សេងៗរបស់ក្រសួង ។
- ធានាប្រសិទ្ធភាព សុវត្ថិភាពរដ្ឋបាល ។
- សរុប និងធ្វើរបាយការណ៍ការងារ និងសកម្មភាពផ្សេងៗរបស់ក្រសួង ។
- តំកល់ឯកសារ និងគ្រប់គ្រងបណ្ណាល័យ ។

**មាត្រា ១៩:** នាយកដ្ឋានផ្គត់ផ្គង់ និងហិរញ្ញវត្ថុទទួលបន្ទុក :

- ប្រមូលផ្តុំតំរូវការ ធ្វើកម្មវិធីចំណាយ គ្រប់គ្រងការរៀបចំជួសជុលសំភារៈ និងបរិក្ខាររបស់ក្រសួង ។
- គ្រប់គ្រងចលនទ្រព្យ អចលនទ្រព្យ សន្និធិសំភារៈ និងធ្វើបញ្ជីសារពើភ័ណ្ឌ
- គ្រប់គ្រងយានដ្ឋាន និងយានយន្តរបស់រដ្ឋដែលប្រគល់ជូនក្រសួង ។ ព្រមទាំងធ្វើកម្មវិធីចំណាយ និងបែងចែកប្រេងឥន្ធនៈ និងគ្រឿងបន្លាស់ ។
- ទទួល និងបែងចែកបរិក្ខារជូនដល់បណ្តាអង្គភាពខេត្ត ក្រុងនានា ។
- កាន់បញ្ជីជាប្រចាំនូវសាលាប័ត្រ និងគណនេយ្យរូបធាតុ ។
- ព័ត៌មានវិទ្យា សកម្មភាពខាងហិរញ្ញវត្ថុ និងបន្ទុកគណនី ។
- ត្រួតពិនិត្យបច្ចេកទេសនៃការប្រតិបត្តិលទ្ធកម្មសាធារណៈ ។
- លើកគំរោងថវិការក្រសួង និងតាមដានរំលឹកពីការប្រតិបត្តិ ។
- ប្រមូលផ្តុំ និងសំរបសំរួលជំពូកថវិកា ។
- តាមដានរំលឹកការគ្រប់គ្រងគណនីពិសេស ។
- ប្រមូលផ្តុំ និងសំរបសំរួលរាល់ចំណាយរបស់ក្រសួង ។
- គ្រប់គ្រងបន្ទុកគណនីនៃការអនុវត្តន៍លទ្ធកម្មសាធារណៈ ។
- ប្រមូលចំណូលឱ្យបានសមស្របតាមច្បាប់ហិរញ្ញវត្ថុដែលបានកំណត់ ។

**មាត្រា ២០:** នាយកដ្ឋានបុគ្គលិកទទួលបន្ទុក ៖

ក. ក្នុងវិស័យបុគ្គលិក

- គ្រប់គ្រងផ្នែករដ្ឋបាល មន្ត្រីរាជការ និងភ្នាក់ងាររាជការរបស់ក្រសួង ដោយទំនាក់ទំនងនឹងរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ ។
- រៀបចំរាល់លិខិតរដ្ឋបាលសំរាប់ការគ្រប់គ្រងអាជីព ។
- ធ្វើកម្មវិធីតំណែងឯកទេស និង ធនធានមនុស្សរបស់ក្រសួង ។
- វាយតំលៃតំរូវការក្នុងការបណ្តុះបណ្តាលបុគ្គលិក ។
- រៀបចំនយោបាយបណ្តុះបណ្តាលដំបូង និងបន្តដោយទំនាក់ទំនងនឹងរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ និងអនុវត្តនយោបាយនោះ ។
- រៀបចំស្ថិតិលើការគ្រប់គ្រងបុគ្គលិក និងតារាងព័តិមានប្រតិបត្តិ ។
- គ្រប់គ្រងការងារសង្គមរបស់ក្រសួង ។

ខ. ក្នុងវិស័យបណ្តុះបណ្តាល

មជ្ឈមណ្ឌលបណ្តុះបណ្តាលក្របខ័ណ្ឌផែនការ-ស្ថិតិ ទទួលបន្ទុក ៖

- រៀបចំការប្រឡងជ្រើសរើសនិងធ្វើការបណ្តុះបណ្តាលនូវមុខវិជ្ជាជំនាញចាំបាច់ក្នុងវិស័យផែនការនិងស្ថិតិ
- រៀបចំធ្វើវិក្រឹតការ និងសុក្រឹតការចំពោះមន្ត្រីរាជការរបស់ក្រសួង ។

## ជំពូក ៨

## អង្គភាពមូលដ្ឋាន

**មាត្រា ២១:** នៅតាមខេត្ត ក្រុងនីមួយៗមានមន្ទីរផែនការខេត្ត ក្រុង ទទួលបន្ទុកអនុវត្ត និងសំរបសំរួលសកម្មភាព របស់ក្រសួង ។

## ជំពូក ៩

## អង្គភាពត្រួតពិនិត្យហិរញ្ញវត្ថុ

**មាត្រា ២២:** អង្គភាពត្រួតពិនិត្យហិរញ្ញវត្ថុត្រូវបានបង្កើតដោយរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ តាមលក្ខខ័ណ្ឌ នៃបទបញ្ញាកំណត់ក្នុងអនុក្រឹត្យលេខ ៨១ ចុះថ្ងៃទី ១៦ ខែវិច្ឆិកា ឆ្នាំ១៩៩៥ ស្តីពីការបង្កើតស្ថាប័នត្រួតពិនិត្យហិរញ្ញវត្ថុលើការចំណាយថវិកាក្នុងបណ្តាក្រសួង ។

# ជំពូក ១០

## អវសានបញ្ញត្តិ

**មាត្រា ២៣:** ការរៀបចំ និងការប្រព្រឹត្តិទៅរបស់ក្រសួងនៅរដ្ឋបាលកណ្តាល ចាប់ពីថ្នាក់ក្រោមនាយកដ្ឋានចុះ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងផែនការ ។

**មាត្រា ២៤:** បទបញ្ញត្តិទាំងឡាយណាដែលផ្ទុយពីអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា ២៥:** សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងផែនការ រដ្ឋមន្ត្រីនិងរដ្ឋលេខាធិការទាំងអស់ដែលមានការពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀងៗខ្លួន ។

**មាត្រា ២៦:** អនុក្រឹត្យនេះចូលជាធរមានចាប់ពីថ្ងៃ ចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ, ថ្ងៃទី២៣ ខែកញ្ញា ឆ្នាំ ១៩៩៧

នាយករដ្ឋមន្ត្រីទី១ នាយករដ្ឋមន្ត្រីទី២

**អ៊ុង ហួត** **ហ៊ុន សែន**

ជំរាបជូន

- នាយករដ្ឋមន្ត្រីទី ១
- នាយករដ្ឋមន្ត្រីទី ២

រដ្ឋមន្ត្រីក្រសួងផែនការ

**ជា ចាន់តូ**

ចម្លងជូន

- ខុទ្ទកាល័យព្រះមហាក្សត្រ
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យនាយករដ្ឋមន្ត្រីទី១
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រីទី ២
- គ្រប់ក្រសួងស្ថាប័នកណ្តាល
- គ្រប់សាលាខេត្ត ក្រុង
- ដូចមាត្រា ២៥
- ឯកសារ កាលប្បវត្តិ

# អង្គការលេខរបស់ក្រសួងផែនការ



**ឧបសម្ព័ន្ធ ៥**

# សូចនាករតាមដានត្រួតពិនិត្យ ផយអវ

| | សូចនាករសំខាន់ៗ | បញ្ចូល (មាន ឬគ្មាន) | ក្រសួង-ស្ថាប័ន ទទួលខុសត្រូវ | ប្រភព* |
|---|---|---|---|---|
| | ***លុបបំបាត់ភាពក្រីក្រនិងភាពអត់ឃ្លានធ្ងន់ធ្ងរ*** | | | |
| ១ | ភាគរយនៃប្រជាជនរស់នៅក្រោមបន្ទាត់ភាពក្រីក្រ ២០០៤ បើគិតតាមភាពគ្របដណ្តប់នៃអង្កេតឆ្នាំ១៩៩៣-១៩៩៤ (៥៩%នៃផ្ទៃដីទូទាំងប្រទេស) | គ្មាន | | |
| ២ | ភាគរយនៃប្រជាជននៅតំបន់ជនបទ រស់នៅក្រោមបន្ទាត់ភាពក្រីក្រ ២០០៤ បើគិតតាមភាពគ្របដណ្តប់នៃអង្កេតឆ្នាំ១៩៩៣-១៩៩៤ (៥៦%នៃផ្ទៃដីទូទាំងប្រទេស) | គ្មាន | | |
| ៣ | ប្រជាជនរស់នៅក្រោមបន្ទាត់ភាពក្រីក្រស្បៀងអាហារ ២០០៤ បើគិតតាមភាពគ្របដណ្តប់នៃអង្កេតឆ្នាំ១៩៩៣-១៩៩៤ (៥៦%នៃផ្ទៃដីទូទាំងប្រទេស) | គ្មាន | | |
| | ***លើកកម្ពស់ផលិតភាពនិងផលិតកម្មកសិកម្ម*** | | | |
| ៤ | ទិន្នផលស្រូវក្នុងមួយហិកតា (តោន) | មាន | ក្រ.កសិកម្ម | ប្រ.ព័ត៌.រដ្ឋ.ក្រ-ស |
| ៥ | ផ្ទៃដីស្រោចស្រព (រួមទាំងការស្រោចស្រពដោយប្រព័ន្ធ ធារាសាស្ត្រ) (%នៃផ្ទៃដាំស្រូវ) | មាន | ក្រ.កសិកម្ម | ប្រ.ព័ត៌.រដ្ឋ.ក្រ-ស |
| ៦ | កំណែទម្រង់ដីធ្លី : ចំនួនប័ណ្ណកម្មសិទ្ធិដីធ្លីដែលផ្តល់ជូនកសិករ (%នៃផ្ទៃដីសរុប) | មាន | ក្រ.រៀបចំដែនដី | ប្រ.ព័ត៌.រដ្ឋ.ក្រ-ស |
| | ***លើកកម្ពស់ក្នុងវិស័យសុខាភិបាល*** | | | |
| ៧ | អត្រាមរណភាពទារក ក្នុង១.០០០កំណើតរស់ | គ្មាន | | |
| ៨ | អត្រាមរណភាពកុមារអាយុក្រោម៥ឆ្នាំ ក្នុង១.០០០កំណើតរស | គ្មាន | | |
| ៩ | មរណភាពមាតា ក្នុង១០០.០០០កំណើតរស់ | គ្មាន | | |
| ១០ | ការសម្រាលកូនដោយបុគ្គលិកសុខាភិបាលមានជំនាញ (%) | មាន | ក្រ.សុខាភិបាល | ប្រ.ព័ត៌.រដ្ឋ.ក្រ-ស |
| ១១ | អត្រាប្រេវ៉ាឡង់ហ៊ីវ/អេដស៍ក្នុងចំណោមមនុស្ស ពេញវ័យអាយុពី១៥-៤៩ឆ្នាំ | មាន | អាជ្ញាធរអេដស៍ | ប្រ.ព័ត៌.រដ្ឋ.ក្រ-ស |
| ១២ | ករណីជម្ងឺគ្រុនចាញ់ (អត្រាស្លាប់) | មាន | ក្រ.សុខាភិបាល | ប្រ.ព័ត៌.រដ្ឋ.ក្រ-ស |
| ១៣ | ករណីអ្នកផ្ទុកជម្ងឺរបេង ក្នុង ១០០.០០០នាក់ | មាន | ក្រ.សុខាភិបាល | ប្រ.ព័ត៌.រដ្ឋ.ក្រ-ស |
| ១៤ | ស្ត្រីរៀបការ ប្រើប្រាស់វិធីសាស្ត្រពន្យារកំណើតទំនើប (%) | មាន | ក្រ.សុខាភិបាល | ប្រ.ព័ត៌.រដ្ឋ.ក្រ-ស |
| ១៥ | មណ្ឌលសុខភាពដែលផ្តល់សេវាសុខភាពបន្តពូជ | មាន | ក្រ.សុខាភិបាល | ប្រ.ព័ត៌.រដ្ឋ.ក្រ-ស |
| | ***លើកកម្ពស់វិស័យអប់រំ (*)*** | | | |
| ១៦ | អត្រាពិតនៃការសិក្សា : បឋមសិក្សា (សរុប-ប្រុស-ស្រី) | មាន | ក្រ.អបរំ | ប្រ.ព័ត៌.រដ្ឋ.ក្រ-ស |
| ១៧ | អត្រាពិតនៃការសិក្សា : មធ្យមសិក្សាបឋមភូមិ ( សរុប-ប្រុស-ស្រី) | មាន | ក្រ.អបរំ | ប្រ.ព័ត៌.រដ្ឋ.ក្រ-ស |
| ១៨ | អត្រាគង់វង្ស : ថ្នាក់១-៦ | មាន | ក្រ.អបរំ | ប្រ.ព័ត៌.រដ្ឋ.ក្រ-ស |
| ១៩ | អត្រាគង់វង្ស : ថ្នាក់១-៩ | មាន | ក្រ.អបរំ | |

| | សូចនាករសំខាន់ៗ | បញ្ចូល (មាន ឬគ្មាន) | ក្រសួង-ស្ថាប័ន ទទួលខុសត្រូវ | ប្រភព* |
|---|---|---|---|---|
| ២០ | កុមារអាយុ ៦-១៤ឆ្នាំ មិនបានចូលរៀន (%) | គ្មាន | | |
| | ***ការអភិវឌ្ឍជនបទ*** | | | |
| ២១ | ផ្លូវជនបទដែលបានស្តារ លើប្រវែងផ្លូវសរុប ២៨.០០០ គម | មាន | ក្រ.អភិ.ជនបទ | ប្រ.ព័ត៌.រដ្ឋ.ក្រ-ស |
| ២២ | លទ្ធភាពមានទឹកស្អាតបរិភោគ (%នៃប្រជាជនជនបទ) | គ្មាន | | |
| ២៣ | លទ្ធភាពប្រើប្រាស់សេវាអនាម័យ (%នៃប្រជាជនជនបទ) | គ្មាន | | |
| | ***ចីរភាពបរិស្ថាន (*)*** | | | |
| ២៤ | ផ្ទៃដីគ្របដណ្តប់ដោយព្រៃឈើ (%នៃផ្ទៃដីសរុប) | មាន | ក្រ.កសិកម្ម | ប្រ.ព័ត៌.រដ្ឋ.ក្រ-ស |
| ២៥ | ការប្រើប្រាស់អុស-ធ្យូង : គ្រួសារ (%) | គ្មាន | | |
| ២៦ | ការទទួលបានការផ្គត់ផ្គង់ទឹកស្អាត (%នៃប្រជាជនទីប្រជុំជន) | មាន | ក្រ.ឧស្សាហកម្ម | ប្រ.ព័ត៌.រដ្ឋ.ក្រ-ស |
| ២៧ | ការទទួលបានការកែលម្អអនាម័យ (%នៃប្រជាជនទីប្រជុំជន) | មាន | ក្រ.ឧស្សាហកម្ម | ប្រ.ព័ត៌.រដ្ឋ.ក្រ-ស |
| | ***សមធម៌យេនឌ័រ (*)*** | | | |
| ២៨ | បញ្ជ្រាបយេនឌ័រនៅគ្រប់មជ្ឈដ្ឋាន | មាន | ក្រ.កិច្ចការនារី | ប្រ.ព័ត៌.រដ្ឋ.ក្រ-ស |
| ក) | ក្រសួង-ស្ថាប័នពាក់ព័ន្ធដែលបានបង្កើតផែនការសកម្មភាពបញ្ជ្រាបយេនឌ័ររបស់ខ្លួនផ្ទាល់ | មាន | ក្រ.កិច្ចការនារី | ប្រ.ព័ត៌.រដ្ឋ.ក្រ-ស |
| ខ) | ក្រសួង-ស្ថាប័នពាក់ព័ន្ធដែលបានអនុវត្តផែនការសកម្មភាពបញ្ជ្រាបយេនឌ័ររបស់ខ្លួនផ្ទាល់ | មាន | ក្រ.កិច្ចការនារី | ប្រ.ព័ត៌.រដ្ឋ.ក្រ-ស |
| ២៩ | ការចូលរួមរបស់ស្ត្រីក្នុងការងារទទួលកម្រៃ (កសិកម្ម ឧ.កម្ម សេវាកម្ម) % | គ្មាន | | |
| ៣០ | កម្រិតយល់ដឹងថា អំពីអំពើហិង្សាប្រឆាំងនឹងស្ត្រីជាអត្តចរិក ខុសឆ្គង និងឧក្រិដ្ឋកម្ម % | មាន | ក្រ.កិច្ចការនារី | ប្រ.ព័ត៌.រដ្ឋ.ក្រ-ស |
| | ***កំណែទម្រង់*** | | | |
| ៣១ | បង្កើនល្បឿនកំណែទម្រង់អភិបាលកិច្ច | គ្មាន | | |
| ក) | បញ្ចប់ និងពង្រឹងច្បាប់ប្រឆាំងអំពើពុករលួយ ផ្អែកលើការអនុវត្តជាក់ស្តែងពីបរទេសដ៏ប្រសើរ | មាន | ក្រ.ទំ.សភា ព្រឹទ្ធ. តរម | ប្រ.ព័ត៌.រដ្ឋ.ក្រ-ស |
| ខ) | រៀបចំដាក់ទៅរដ្ឋសភាអនុម័ត *ច្បាប់អង្គការ* ដើម្បីអភិវឌ្ឍន៍ប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ | មាន | គណៈកម្មាធិការអន្តរក្រសួង | ប្រ.ព័ត៌.រដ្ឋ.ក្រ-ស |
| | ***ធ្វើឱ្យមានស្ថេរភាពកំណើនម៉ាក្រូសេដ្ឋកិច្ចខ្ពស់ (*)*** | | | |
| ៣២ | កំណើន *ផសស* ប្រចាំឆ្នាំ គិតតាមថ្លៃថេរ (%) | មាន | វជស | ប្រ.ព័ត៌.រដ្ឋ.ក្រ-ស |
| ៣៣ | *ផសស* សម្រាប់មនុស្សម្នាក់ គិតតាមថ្លៃថេរ (ពាន់រៀល) | មាន | វជស | ប្រ.ព័ត៌.រដ្ឋ.ក្រ-ស |
| ៣៤ | អត្រាអតិផរណា | មាន | វជស | ប្រ.ព័ត៌.រដ្ឋ.ក្រ-ស |
| | ***កែលម្អការប្រើប្រាស់ថវិកា*** | | | |
| ៣៥ | ចំណូលថវិការដ្ឋសរុប : (%នៃ *ផសស*) | មាន | ក្រ.សហវ | ប្រ.ព័ត៌.រដ្ឋ.ក្រ-ស |
| ៣៦ | ចំណាយថវិការដ្ឋសរុប : (%នៃ *ផសស*) | មាន | ក្រ.សហវ | ប្រ.ព័ត៌.រដ្ឋ.ក្រ-ស |

| សូចនាករសំខាន់ៗ | | បញ្ជូល (មាន ឬគ្មាន) | ក្រសួង-ស្ថាប័នទទួលខុសត្រូវ | ប្រភព* |
|---|---|---|---|---|
| | **បង្កើនល្បឿនកំណើនក្នុងវិស័យឧស្សាហកម្មនិងការងារ** | | | |
| ៣៧ | កំណើនប្រចាំឆ្នាំក្នុងផ្នែកកម្មន្តសាល គិតតាមថ្លៃថេរ (%) | មាន | ក្រ.ឧស្សាហកម្ម | ប្រ.ព័ត៌.រដ្ឋ.ក្រ-ស |
| ៣៨ | ពលកម្មកុមារអាយុ ៥-១៧ឆ្នាំ (%) | គ្មាន | | |
| | **ទេសចរណ៍** | | | |
| ៣៩ | ចំនួនភ្ញៀវទេសចរណ៍ប្រចាំឆ្នាំ (ពាន់នាក់) | មាន | ក្រ.ទេសចរណ៍ | ប្រ.ព័ត៌.រដ្ឋ.ក្រ-ស |
| | **ការបោសសម្អាតមីន ការជួយសង្គ្រោះជនរងគ្រោះ (*)** | | | |
| ៤០ | ចំនួនអ្នករងគ្រោះ (ស្លាប់ និងរបួស) | មាន | អាជ្ញាធរមីន | ប្រ.ព័ត៌.រដ្ឋ.ក្រ-ស |
| ៤១ | តំបន់ដែលបានបោសសម្អាតមីននិងយុទ្ធភ័ណ្ឌមិនទាន់ផ្ទុះ (%) | មាន | អាជ្ញាធរមីន | ប្រ.ព័ត៌.រដ្ឋ.ក្រ-ស |
| | **ហេដ្ឋារចនាសម្ព័ន្ធ** | | | |
| ៤២ | ផ្លូវក្រាលកៅស៊ូ (ផ្លូវជាតិនិងផ្លូវខេត្ត) លើប្រវែងផ្លូវសរុប ១១.៣១០ គម | មាន | ក្រ.ដឹកជញ្ជូន | ប្រ.ព័ត៌.រដ្ឋ.ក្រ-ស |
| | **ថាមពល** | | | |
| ៤៣ | ការប្រើប្រាស់អគ្គិសនីក្នុងមនុស្សម្នាក់ (គីឡូវ៉ាត់ម៉ោង) | មាន | ក្រ.ឧស្សាហកម្ម | ប្រ.ព័ត៌.រដ្ឋ.ក្រ-ស |

**ឧបសម្ព័ន្ធ ៦**

# ពាក្យបំព្រួញ

| | |
|---|---|
| ផយអជ | ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ |
| ផយផក | ផែនការយុទ្ធសាស្ត្ររបស់ក្រសួងផែនការ |
| គអសក | គោលដៅអភិវឌ្ឍសហស្សវត្សរ៍កម្ពុជា *គអសក* មាន ៩ គោលដៅ និង ២៥ ចំណុចដៅរួម ។ |
| កវស | កម្មវិធីវិនិយោគសាធារណៈ |
| ផអសស | ផែនការអភិវឌ្ឍន៍សេដ្ឋកិច្ចសង្គមកិច្ច ទី១ (១៩៩៦-២០០០) និង ទី២ (២០០១-២០០៥) |
| ក.អ.ក/គ.ជ.នា | ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា/គណៈកម្មាធិការនីតិសម្បទានិងអភិវឌ្ឍន៍កម្ពុជា |